ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2012, 15:28
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០៤នាទី**

**សវនាការលើកទី១៣៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោកស្រី អ៊ីស្សាបែល ដៀរ៉ង់

*(Ms.Isabelle DURAND)*

លោក អេម៉ានូអ៊ែល ហ្សាកូមី

*(Mr.Emanuel JACOMY)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី អ៊ីស្សាបែល ដៀរ៉ង់ | បារាំង |
| លោក អេម៉ានូអ៊ែល ហ្សាកូមី | បារាំង |
| លោក ផាន វ៉ាន (TCW-307) | ខ្មែរ |
| លោកស្រី ដេនីស អាហ្វុងសូ (TCCP-01) | បារាំង |
| លោក ជូល្យាន រីវ៉េ (មេធាវីប្រឹក្សា) | បារាំង |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅ សាក្សី៖ លោក ខាំ ផាន់ ហៅ ផាន វ៉ាន** (TCW-307)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី៖....................ទំព័រ ៥
សួរដោយលោកលោក សំ សុគង់ ផ្ដើមពី៖....................ទំព័រ ២៣
សួរដោយលោកស្រី អ៊ីស្សាបែល ដៀរ៉ង់ ផ្ដើមពី៖....................ទំព័រ ៣១
សួរដោយលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖ ....................ទំព័រ ៣៨

**ការសួរសំណួរទៅ ដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី ដេនីស អាហ្វុនសូ** (TCCP-01)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖....................ទំព័រ ៤៥
សួរដោយលោក សំ សុគង់ ផ្ដើមពី៖....................ទំព័រ ៥០
សួរដោយលោក អេម៉ានូអ៊ែល ហ្សាកូមី ផ្ដើមពី៖ ....................ទំព័រ ៥៩
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី៖....................ទំព័រ ៧៦
សួរដោយលោក ច័ន្ទ តារាស្មី ផ្ដើមពី៖ ....................ទំព័រ ៨៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សូមលោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៥:១៣]

*(មានបញ្ហាបច្ចេកទេស)*

[០៩:១២:៥១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ផារី!

**ក្រឡាបញ្ជី៖**

សូមគោរព និងជម្រាបលោកប្រធាន។ ក្នុងសវនាការថ្ងៃនេះ គឺថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមានពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។

នាព្រឹកនេះអង្គជំនុំជម្រះនឹងបន្តស្តាប់នូវសក្ខីកម្មរបស់សាក្សីលោក ខាំ ផាន់ ហៅ ផាន វ៉ាន។ ចំពោះសវនាការពេលរសៀល អង្គជំនុំជម្រះនឹងស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលមានរហស្សនាម TCCP-01 តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង ទីដែលដើមបណ្តឹងរដ្ឋប្បវេណីនោះតាំងនៅ។

តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្តាប់សក្ខីកម្មនៅពេលរសៀលនេះបានរៀបចំរួចហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជ

អាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរសាធារណជនក្នុងសាលខាងក្រៅ ជម្រាបសួរលោកសាក្សី។

[០៩:១៤:៤០]

លោកប្រធាន ខ្ញុំសូមការបំភ្លឺបន្តិចពាក់ព័ន្ធទៅនឹងពេលវេលាដែលបានផ្តល់យើងខ្ញុំ។ កាលពីម្សិលមិញ នៅវេលាម៉ោងដប់មួយដប់ប្រាំនាទី យើងថាយើងមានរយៈពេលមួយថ្ងៃជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី។ សាក្សីនេះ គឺដឹងអំពីទិដ្ឋភាពផ្សេងៗជាច្រើននៃរបបខ្មែរក្រហម ដូចជារចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង គោលនយោបាយពាក់ព័ន្ធនឹងខ្មាំង ហើយនិងតួនាទីរបស់ជនជាប់ចោទ។ កាលពីម្សិលមិញពេលរសៀលនោះ យើងបានយឺតពេលបន្តិច បន្ទាប់ពីមានការអានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ គឺប្រហែលជា១៥នាទី យឺតពេល។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបន្តរហូតទៅដល់ម៉ោងដប់មួយសាមសិបនាទីនៅព្រឹកនេះ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបន្តរហូតទៅដល់ម៉ោងដប់មួយកន្លះនៅព្រឹកនេះជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី គឺយើងមិនចង់ឈប់សម្រាកត្រឹមតែពេលសម្រាកព្រឹកនេះនោះទេ យើងចង់បន្តរហូតដល់ម៉ោងដប់មួយកន្លះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវ៉ាស!

[០៩:១៥:៥២]

**លោក ម៉ៃខល កាណាវ៉ាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រម និងអស់លោក លោកស្រីទាំងអស់។ កាលពីម្សិលមិញ យើងបន្តរហូតទៅដល់បួនដប់នាទី លើស១០នាទី ដូច្នេះហើយគឺថាវាអាចបំពេញពេលវេលាដែលបានបាត់បង់រួចទៅហើយនៅក្នុងការអានសេចក្តីសម្រេចដោយផ្ទាល់មាត់នោះ គឺយើងអាចយកពេលនេះជំនួសបាន។ ហេតុដូច្នេះហើយគ្មានមូលដ្ឋានអីដែលត្រូវលើកយកមកធ្វើជាមូលដ្ឋាននៃពាក្យសុំពេលវេលាបន្ថែមនោះទេ។ ហើយដោយគេលើកឡើងថា គេមិនមានពេលវេលាគ្រប់គ្រាន់ ឬក៏សេចក្តីសម្រេចដោយផ្ទាល់មាត់នោះបានអាន ចំណាយពេលអាន ដូច្នេះហើយគឺយើងតាមសំណើរបស់គេថា សុំបន្ថែម

E1/152.1

ពេលវេលាបន្ថែមនេះ គឺថាមិនអាចទទួលយកបានទេលោកប្រធាន។ សូមអរគុណ។

[០៩:១៦:៥៦]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។ បាទ ពិតណាស់ គឺយើង -- ខ្ញុំបានប្រាប់ហើយថា យើងមានប្រធានបទជាច្រើនដែលត្រូវពិភាក្សាគ្នា ហើយយើងមានការយឺតពេលបន្តិចហើយ នៅពេលដែលសួរសំណួរកាលពីម្សិលមិញនោះ។ ដូច្នេះយើងនៅសល់ពេលវេលាសម្រាប់និយាយអំពីពេលវេលាក្រោយពីសាក្សីធ្វើការនៅ១០៥ គឺនៅមជ្ឈិម។ ដូច្នេះខ្ញុំមានសំណួរជាច្រើនទៀត ដើម្បីចោទសួរ ដើម្បីស្វែងរកការពិត ពីព្រោះថាសាក្សីនេះ អាចដឹងអំពីប្រធានបទជាច្រើនដែលគាត់បានផ្ដល់ចម្លើយនៅមុខសហចៅក្រមស៊ើបអង្កេតនោះ។ ដូច្នេះ ខ្ញុំស្នើសុំការអនុញ្ញាតពីលោកប្រធាន ដើម្បីអាចបន្តការសួរសំណួររហូតដល់ម៉ោងដប់មួយកន្លះ គឺមិនមែនម៉ោងដប់មួយ ឬក៏ម៉ោងដប់មួយដប់ប្រាំនាទីដូចដែលលោកប្រធានបានផ្ដល់ជូននោះទេ គឺខ្ញុំសូមស្នើសុំដោយការគោរព សូមរហូតដល់ម៉ោងដប់មួយកន្លះ។

[០៩:១៨:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីនាំមុខ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន យើងខ្ញុំគាំទ្រអ្វីដែលស្នើឡើងដោយតំណាងសហព្រះរាជអាជ្ញាពីមុនៗមកសាក្សីដែលមានព័ត៌មានស្រដៀងគ្នានេះ គឺត្រូវផ្ដល់ពេលវេលាឲ្យច្រើនណាស់ ប្រហែលជា២ថ្ងៃសម្រាប់ភាគីទាំងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ក៏ប៉ុន្តែករណីនេះខ្លីជាង។ ក៏ប៉ុន្តែទោះជាយ៉ាងណាយើងខ្ញុំគិតថា ជាការសមស្របនៅក្នុងការផ្ដល់ពេលវេលាបន្ថែមនេះ ហើយចំណែកដើមបណ្ដឹងរដ្ឋប្បវេណីយើងខ្ញុំក៏ត្រូវការរយៈពេលមួយម៉ោងនៅក្នុងនោះដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន សួស្ដីភាគីទាំងអស់។ ខ្ញុំលើកឡើងចំណុចនេះ ដោយសារតែខ្ញុំបាន

និយាយជាមួយនឹងភាគីខាងសហព្រះរាជអាជ្ញាថា យើងមិនជំទាស់ការពន្យារពេលបន្តិចបន្តួចនោះទេ។ ដរាបណាមេធាវីការពារក្ដីនោះ ផ្ដល់ឱកាសដូចគ្នា។ ដូច្នេះហើយនេះគឺជំហររបស់យើងគួរតែកត់ត្រានៅក្នុងប្រតិចារឹក។ កាលពីអតីតកាល គឺថាយើងមិនជំទាស់ទេចំពោះការផ្ដល់ពេលវេលាបន្ថែម ដរាបណាយើងខ្ញុំបានទទួលឱកាសនេះដូចគ្នា។ ខ្ញុំលើកឡើងចំណុចនេះ នៅក្នុងថ្ងៃនេះដោយសារតែខ្ញុំបាននិយាយជជែកជាមួយនឹងខាងសហព្រះរាជអាជ្ញាផងដែរ កាលពីម្សិលមិញ។ សូមអរគុណលោកប្រធាន។

[០៩:១៩:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៤:២៤]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះលើបញ្ហាសំណើសុំរបស់លោកតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះនឹងពិនិត្យពិចារណាតាមស្ថានភាពជាក់ស្ដែងនៅចុងពេលវេលានៃការឈប់សម្រាកនៅម៉ោងទី១ នេះ ដោយពិនិត្យលទ្ធភាពជាក់ស្ដែងទៅតាមសំណួរដែលសំខាន់ដែលមានភាពពាក់ព័ន្ធ ឬក៏មិនសូវពាក់ព័ន្ធ។ បញ្ហាទី២ គឺអង្គជំនុំជម្រះសូមជម្រាបថា នៅថ្ងៃនេះ គឺទាំងពេលវេលាថ្ងៃត្រង់ ក៏ដូចនៅរសៀល គឺអង្គជំនុំជម្រះនៅសាលនេះគឺត្រូវរៀបចំនូវ*ថោនហលមិទ្ទីង* មួយ ដែលនឹងធ្វើចាប់ផ្ដើមពីម៉ោងដប់ពីរទៅម៉ោងមួយ។ ដូច្នេះត្រូវខាងរដ្ឋបាលត្រូវការពេលវេលាមុនប្រហែលជា២០នាទី ដើម្បីរៀបចំនៅទីនេះសម្រាប់កិច្ចប្រជុំហើយនៅរសៀលនេះក៏នឹងចាប់ផ្ដើមធ្វើសវនាការតាមប្រព័ន្ធវីដេអូផងដែរ។ ហើយម៉្យាងទៀត នៅឌីវីឌីមិនអានបន្តដំណើរការរហូតបានទេ ត្រូវតែឈប់សម្រាកដើម្បីមានការផ្លាស់ប្ដូរ។

ហើយបញ្ហាមួយទៀតដែលមានការចាប់អារម្មណ៍ពីមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា អង្គជំនុំជម្រះគិតថាអ្វីៗដែលអង្គជំនុំជម្រះបានកំណត់នូវកាលបរិច្ឆេទក្នុងការធ្វើសវនាការពិភាក្សាដេញដោលនេះ គឺមានស្មើភាពគ្នារវាងភាគីទាំងសងខាង លើកលែងតែភាគីដែលមិនអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការតាំងសំណួរប៉ុណ្ណោះ ដែលនាំឲ្យវាមានបញ្ហា។ ហេតុខុសគ្នារវាងការប្រើប្រាស់ពេលវេលានោះ គឺយើងបានកំណត់ពេលវេលាយ៉ាងសមស្របទៅតាមអ្វីដែលមានការបែងចែក ហើយក៏មានការបំពេញបន្ថែមខ្វះចន្លោះនៅក្នុងអំឡុងពេលដែលភាគីណាមួយមានការបាត់បង់ដោយមូលហេតុផ្សេងៗ មានបច្ចេកទេស ខាងសំឡេង ឬក៏ខាងរូបភាពជាដើម ឬក៏អាចមានបញ្ហាផ្សេងទៀតដូចជាមានជំទាស់តវ៉ា ឬក៏អង្គជំនុំជម្រះបានចំណាយពេលវេលាមួយចំនួននៅក្នុងអំឡុងពេលនៃដំណើរការសម្របសម្រួលកិច្ច

រៀបចំ កិច្ចពិភាក្សាដេញដោល។ ហេតុដូច្នេះ គឺសូមភាគីជ្រាប។

អង្គជំនុំជម្រះសូមជូនទៅតំណាងសហព្រះរាជអាជ្ញា!

[០៩:២៦:៥៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីមុននឹងចាប់ផ្តើមសួរសំណួរឡើងវិញ អំពីការទំនាក់ទំនងរវាងតំបន់១០៥ និងមជ្ឈិម ខ្ញុំចង់បានការបំភ្លឺអំពីលោក ពាក់ព័ន្ធទៅនឹងរយៈពេលផ្សេងៗដែលលោកបានធ្វើការឲ្យឪពុកលោកជាអ្នកបកប្រែទូរលេខ។ កាលពីម្សិលមិញ លោកបានឆ្លើយថា "បន្ទាប់ពីចេញពីប-២០ លោកបានធ្វើជាអ្នកបកប្រែទូរលេខឲ្យឪពុករបស់លោកមុនពេលទៅដល់ភ្នំក្រោល"។ ក្រោយមកទៀត លោកក៏ឆ្លើយថា "លោកធ្វើជានីរសារ ជាអ្នកបើឡាន ក៏ដូចជាកងការពារឲ្យឪពុករបស់លោកនៅពេលដែលលោកនៅភ្នំក្រោល"។

[០៩:២៧:៥២]

នៅពេលដែលខ្ញុំសួរលោកអំពីទូរលេខពីរកាលពីម្សិលមិញនោះ ដែលចុះថ្ងៃខែតុលា ឆ្នាំ៧៦នោះ លោកបាននិយាយថា "បងស្រីរបស់លោកឈ្មោះ សុវណ្ណ ហាន ហៅ បូផាន់ ប្រហែលជាអ្នកបកប្រែទូរលេខទាំងពីរនេះ"។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់អំពីរយៈពេលផ្សេងៗដែលលោកបានធ្វើការជាអ្នកបកប្រែទូរលេខ និងជាពិសេសនោះថាតើលោកធ្វើការជាអ្នកបកប្រែទូរលេខមុនបងស្រីរបស់លោក ឬក៏ក្រោយបងស្រីរបស់លោក ឬក៏ធ្វើការក្នុងពេលដំណាលគ្នាជាមួយបងស្រីរបស់លោក?

**លោក ផាន វ៉ាន៖**

**ផ៖** សូមបញ្ជាក់ចំណុចហ្នឹង គឺខ្ញុំធ្វើការមុនបងស្រីរបស់ខ្ញុំបាទ។ តែបងស្រីខ្ញុំមកជំនួស ខ្ញុំជាប់ទៅបើកឡានជូនគាត់ចុះឡើងៗ។ តែប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ កាលម្សិលមិញលោកបានឆ្លើយថា បងស្រីរបស់លោកធ្វើការក្នុងរយៈពេលខ្លីទេជាមួយឪពុករបស់លោកជាអ្នកបកប្រែទូរលេខ។ ក្រោយពេលបងស្រីរបស់លោកបញ្ចប់ការងារនុ៎ង គឺលោកបន្តការងារពីគាត់តែម្តងនៅឆ្នាំ១៩៧៧។ តើអ៊ីចឹងមែនទេ?

**ផ៖** អត់ទេ អាហ្នឹងមុនៗ កាលមុនសង្គ្រាម -- កាលនៅសង្គ្រាមហ្នឹង ខ្ញុំរហូត។ រហូតដល់

រំដោះហើយហ្នឹងបងខ្ញុំគាត់មកជំនួស។ រហូតដល់ឪពុកខ្ញុំស្លាប់បាន១ បងខ្ញុំធ្វើការរហូតបាទ។ ឯខ្ញុំនៅបើកឡានឲ្យគាត់រហូត និងនៅការពារគាត់។ ដូចបានបញ្ជាក់ក្នុងការសាកសួររបស់ -- នៅក្នុងឯកសារហ្នឹង។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញនោះ នៅពេលដែលបង្ហាញទូរលេខនោះ លោកបានស្គាល់អំពីទម្រង់ និងខ្លឹមសារផ្សេងៗដែលមាននៅក្នុងទូរលេខនោះ គឺមានលោកបានបញ្ជាក់ថា វាដូចគ្នាទៅនឹងអ្វីដែលលោកបានបកប្រែនៅពេលនោះ។ ហើយលោកក៏ទទួលស្គាល់ផងដែរ អំពីរបៀបដែលឪពុករបស់លោកហៅអាជ្ញាធរមជ្ឈិមនោះ។

[០៩:៣១:០០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំមានទូរលេខមួយទៀតដើម្បីបង្ហាញជូនសាក្សី។ ទូរលេខនោះមានលេខ E3/1195 គឺទូរលេខ២២ ផ្ញើដោយ ឡាំង ជូនសមមិត្ត ប៉ង់ ថ្ងៃទី២៥ វិច្ឆិកា ៧៦ ចម្លងជូន នួន ជា។

មូលហេតុដែលខ្ញុំចង់បង្ហាញទូរលេខនេះជូនសាក្សី ពីព្រោះថាវាមានព័ត៌មានមួយចំនួននៅក្នុងទូរលេខនោះ គឺពាក់ព័ន្ធនឹងគ្រួសាររបស់គាត់ផ្ទាល់។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញជូនសាក្សីនូវទូរលេខមួយនេះ ហើយនិងសូមបញ្ចាំងនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ដើម្បីអាចចោទសួរសំណួរទៅសាក្សី ខ្ញុំសូមអានសម្រង់ជាភាសាអង់គ្លេស ពីព្រោះថាភាសាបារាំងបកប្រែមិនសូវបានល្អទេ ហើយមិនសូវច្បាស់លាស់។ ភាសាអង់គ្លេសដូចជាច្បាស់ជាង ដូច្នេះខ្ញុំសូមអានចំណុច ៣, ៤, ៥, ៦ នៃទូរលេខនេះដែលចុះហត្ថលេខាដោយ ឡាំង។

[០៩:៣២:៣៥]

ចំណុចទី៣ នៃជាភាសាអង់គ្លេស សូមអានដូចតទៅនេះ៖ "ខ្ញុំឲ្យក្មួយ បូផាន់ ចុះទៅរៀនឯកសារសម្ងាត់។ សូមជួយផង"។

ចំណុចទី៤ “ខ្ញុំឲ្យសមមិត្ត ខាន វិទ្យុទាក់ទង ចុះទៅរៀនឯកសារវិទ្យុទាក់ទង។ សូមសមមិត្តជួយដោះស្រាយផង”។ ចំណុចទី៥ “ម្ដាយខ្ញុំ គាត់ចុះទៅរវាងក្មួយៗគាត់។ ជាកូនខ្ញុំ មាន វ៉ាន់, ធី, ឡាន។ បងដា សូមមេត្តាជួយដោះស្រាយផង។ គាត់ចង់ឃើញភ្នំពេញទៀត គាត់ចាស់ហើយ”។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯលៈ**

**ស៖** លោកសាក្សី សំណួររបស់ខ្ញុំនោះ ខ្ញុំចង់ដឹងថា នៅពេលដែលទូរលេខ ដែលស៊ីញ៉េដោយ -- ចុះហត្ថលេខាដោយ ឡាំង ហើយនិយាយអំពី ឡាន ហើយនិង ប្អូនទាន់ នេះ តើឈ្មោះហ្នឹងជាឈ្មោះបងស្រីរបស់លោក ដែលឈ្មោះ សុវណ្ណ ហាន ដែលបានទៅរៀនសូត្រអំពីឯកសារសម្ងាត់ បើតាមទូរលេខនោះ។ តើមែនទេលោកសាក្សី។

**លោក ផាន វ៉ាន៖**

**ផ៖** បាទ មែន។

[០៩:៣៤:១២]

**ស៖** នៅក្នុងរបបខ្មែរក្រហម តើជារឿងធម្មតាទេឬនៅពេលដែលកម្មាភិបាលដូចជាឪពុកលោក គាត់ចាត់កូនគាត់ឲ្យទៅរៀន តែគាត់ប្រើពាក្យថាជាក្មួយទៅវិញនេះ តើវាជាទម្លាប់ធម្មតានៅសម័យនោះមែនទេ?

**ផ៖** ជំនាន់ហ្នឹងគេឲ្យហៅឪពុកម្ដាយ ឲ្យហៅក្មួយបាទ។

**ស៖** ដើម្បីឲ្យលោកបំភ្លឺឲ្យច្បាស់នោះ ខ្ញុំចង់ដឹងថា តើអ្នកណាជាសមមិត្ត ខាន ខាងវិទ្យុទាក់ទងនោះ ដែលនៅតំបន់១០៥ នៅក្នុងទូរលេខនេះនោះ?

**ផ៖** ខាន នុ៎ងប្រធានខាងវិទ្យុ ខាងវិទ្យុទាក់ទងនៅជាមួយខ្មោចឪពុកខ្ញុំដែរ។

**ស៖** តើលោកអាចប្រាប់បានទេ អ្នកណាជា វ៉ាន់, ធី, ឡាន និងបងដា នេះ គឺនៅចំណុចទី៥ នៃទូរលេខនេះ? តើអ្នកទាំងពីរហ្នឹងជាអ្នកណា?

**ផ៖** វ៉ាន់ ហ្នឹង វ៉ាន់នី ប្អូនខ្ញុំបង្កើត ហើយ ឡាន ប្អូនខ្ញុំបង្កើតដែរ។ ហើយ ធី ហ្នឹងក៏ប្អូនខ្ញុំបង្កើតដែរបាទ។

**ស៖** សូមអរគុណ។ តាមការអានទូរលេខនេះទៅលោកបញ្ជាក់អំពីព័ត៌មាន គឺថាលោកទទួលស្គាល់ថា ព័ត៌មានក្នុងនេះគឺត្រឹមត្រូវមែន គឺថាយាយរបស់លោក គឺគាត់ចង់ទៅលេងនៅភ្នំពេញនៅចុងឆ្នាំ៧៦ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អានេះត្រឹមត្រូវហើយ ក្រោយពីទៅពីភ្នំពេញទៅគាត់ស្លាប់ ម្ដាយខ្ញុំគាត់ស្លាប់បណ្ដោយ។

[០៩:៣៧:០១]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ។ មានទូរលេខមួយទៀតដែលខ្ញុំចង់បង្ហាញជូនសាក្សីលោកប្រធាន គឺឯកសារលេខ E3/877។ គឺទូរលេខ៥៤ ផ្ញើដោយឈ្មោះ ឆាន ដែលយើងបានឃើញកាលពីម្សិលមិញមក ហើយ ឈ្មោះ ឆាន នេះនៅក្នុងទូរលេខប៉ុន្មានដែលខ្ញុំបានបង្ហាញជូនកាលពីម្សិលនោះ។ ទូរលេខនេះចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ៧៦ ផ្ញើជូន ម៨៧០។ ការបកប្រែជាភាសាអង់គ្លេសមិនពេញលេញនោះទេ ក៏ប៉ុន្តែការបកប្រែជាភាសាបារាំងគឺមានលក្ខណៈពេញលេញ។ ដូច្នេះ ខ្ញុំសូមផ្ដល់ឯកសារនេះជូនសាក្សីគឺពាក់ព័ន្ធទៅនឹងតំបន់១០៥។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[០៩:៣៨:២០]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ទូរលេខនេះត្រូវបានផ្ញើដោយឈ្មោះ ឆាន ពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខនៅតំបន់១០៥។ ខ្ញុំសូមអាននូវសម្រង់មួយចំនួន “នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ៧៧ នៅមុខព្រួញដាកដាំកម្ទេចពួកយួនស្លាប់នៅនឹងកន្លែងម្នាក់។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ៧៧ កងពល២ បានចាប់ពួកយួនចំនួនពីរនាក់ ចាប់នៅខាងមុខព្រួញកែវសីមា និងស្រែព្រះ។ ពួកនេះខាងអាធីវទេ ពាក់ស័ក្តិ១ ស័ក្តិ២។ វាសុំទៅស្រុកបារាំង វាថាស្រុកយួនលំបាកអត់បាយខ្លាំងណាស់ ហើយនៅមានវាយគ្នារហូតទៀត”។ ចំណុចទី៣ “កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ៧៧ កងតំបន់មានពលីកម្មម្នាក់ និងរបួសម្នាក់ធ្ងន់ ខ្មាំងវាយជិតមន្ទីរ ត្នូជួយ ខាងត្នូស្រា ឆ្ងាយពីមន្ទីរ៥០ម៉ែត្រ តាមយើងពិនិត្យមិនមែនខ្មាំងក្រៅទេ។ ពួកយើងសង្ស័យខាងកងពលជាដៃជើង អាសោម, អាឈិន”។ បាទ នៅទីនេះ គឺយើងប្រើពាក្យ “អា” គឺ អាសោម និង អាឈិន។ បញ្ហានេះបានរាយការណ៍ ខាងសមមិត្ត សាន ហើយ ពួកកងពល៩២០ ចាប់នៅធ្វើសកម្មភាពបន្តបន្ទាប់ទៀតតែយើងចាប់បន្តបន្ទាប់ដែរ។ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៧ យើងខ្ញុំជូនសមមិត្ត ខាង អក្សរសម្ងាត់

ទៅរៀន។ សេចក្ដីបានទទួលហើយ អំពីកំណើតសហករណ៍។ បន្ថែម៖ អំពីបញ្ហាយួននេះបានសម្រេចហើយ"។

លោកសាក្សីតើលោកអាចប្រាប់យើងខ្ញុំបានទេថា នៅពេលដែលគេនិយាយអំពី "កងពល២" នៃតំបន់១០៥ នេះ តើមានន័យថាម៉េច "កងពល២" នេះ? តើជាក្រុមទ័ពនៅក្នុងតំបន់១០៥ ឬក៏ជាទ័ពរបស់កងពល៩២០?

**លោក ផាន វ៉ាន៖**

**ឆ៖** អត់យល់អត្ថន័យ ចង់ឲ្យបញ្ជាក់ម្ដងទៀតបាទ។

[០៩:៤១:១៩]

**ស៖** នៅក្នុងទូរលេខនេះយើងមានឃើញដាក់ថា "កងពល២"។ ដូច្នេះ ខ្ញុំចង់ដឹងថាតើ កងពល២ នេះជាទ័ពរបស់តំបន់១០៥ ដែលដឹកនាំដោយ សុភា ឬក៏កងពល២នេះ គឺជាទ័ពរបស់កងពលធំ៩២០ ដែលឈរជើងនៅមណ្ឌលគិរី?

**ឆ៖** កងពល៩២០ តាមខ្ញុំសន្និដ្ឋានទេ អត់ច្បាស់ប៉ុន្មានទេបាទ ពីព្រោះកងពល១០៥ គេហៅថាកង១០៥ហ្នឹងតែម្ដង របស់តំបន់ អត់មានជាកងពលទេ។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ក្នុងឯកសារនេះគេនិយាយអំពីការចាប់វៀតណាម ចាប់យួន ហើយនៅក្នុងសេចក្ដីបន្ថែមនេះបានបញ្ជាក់ថាបញ្ហាយួននេះបានសម្រេចហើយនៅតំបន់១០៥។ តើលោកដឹងទេថាការសម្រេចពាក់ព័ន្ធនឹងការចាប់យួននេះត្រូវបានធ្វើឡើងដោយថ្នាក់តំបន់១០៥ ឬក៏សម្រេចដោយថ្នាក់មជ្ឈិម?

[០៩:៤៣:០០]

**ឆ៖** សម្រេចយ៉ាងណា? អត់យល់ន័យទេ។

**ស៖** នៅក្នុងទូរលេខនេះ គេនិយាយអំពីការសម្រេចពាក់ព័ន្ធនឹងការចាប់ខ្លួនជនជាតិយួន គឺគេនិយាយអំពីចាប់បានយួននៅមុខព្រួញកែវសីមា និងស្រែព្រះ ដែលមានជាប់ពាក់ព័ន្ធនឹងខាងអាធីវ។ អ៊ីចឹងខ្ញុំចង់ដឹង លោកថាការសម្រេចពាក់ព័ន្ធទៅនឹងជោគវាសនារបស់ពួកយួនដែលចាប់ខ្លួនបាននោះ ត្រូវបានសម្រេចខាងតំបន់១០៥ ឬក៏សម្រេចពីថ្នាក់មជ្ឈិមមក?

**ឆ៖** បាទខ្ញុំសូមបញ្ជាក់ ព្រឹត្តិការណ៍ហ្នឹងវា ជំនាន់នោះមានមែនតាមខ្ញុំចាំខ្លះៗព្រោះមានការវ៉ៃគ្នាតាមព្រំដែនហូរហែ រហូត ហើយខ្ញុំក៏ជូនប៉ាខ្ញុំចុះឡើងៗអារឿងវ៉ៃគ្នាហ្នឹង បញ្ហាការវ៉ៃតាមព្រំដែន

ជំនាន់នោះ។ ហើយការចាប់អីហ្នឹង មានចាប់មែនជំនាន់ហ្នឹង ឯការសម្រេចស្អីៗហ្នឹងក៏មិនមែនតំបន់សម្រេចបានទេ អាហ្នឹងទាល់តែខាងលើសម្រេចយ៉ាងណាៗបានអនុវត្ត។ ហ្នឹងខាងតំបន់អត់មានសិទ្ធិទេបាទ។

**ស៖** ចុះនៅមជ្ឈិម អ្នកណាជាអ្នកសម្រេច? ហើយសម្រេចហើយអ្នកណាជាអ្នកបញ្ជូនសេចក្ដីសម្រេចនេះមកថ្នាក់តំបន់?

**ឆ៖** ខ្ញុំអត់យល់ដែរបាទ ដឹងតែថាខាងលើៗអ៊ីចឹង សម្រេច។

[០៩:៤៥:១៥]

**ស៖** បាទ សូមអរគុណ។ សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងទូរលេខមួយនេះ។ តើឈ្មោះ ឈិន នៅក្នុងទូរលេខនេះ តើជាមនុស្សតែមួយដែលលោកបាននិយាយកាលពីម្សិលមិញនោះថា "ជាលេខាកងពល៩២០"។ "អាឈិន" នៅទីនេះ តើជា ឈិន លេខាកងពល៩២០ មែនទេ?

**ឆ៖** បាទ មែនបាទ។

**ស៖** នៅក្នុងទូរលេខនេះមានការបញ្ជាក់ថា "ពួកកង៩២០ នៅតែធ្វើសកម្មភាពបន្តបន្ទាប់ទៀត ក៏ប៉ុន្តែយើងចាប់ពួកវាបានជាបន្តបន្ទាប់"។ តើលោកចាំទេក្នុងអំឡុងខែឧសភា មិថុនា ឆ្នាំ៧៧ នោះមានការចាប់ខ្លួនជាច្រើន ឬក៏មានការបោកសម្អាតមនុស្សជាច្រើននៅក្នុងកងពល៩២០?

[០៩:៤៦:២៤]

**ឆ៖** ខ្ញុំចាំមិនបានទេបាទ ប៉ុន្តែមនុស្សវាបាត់ច្រើន វាទៅបាត់ៗអ៊ីចឹង គ្រាន់តែដឹងថាចឹង។

**ស៖** សូមអរគុណ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សម្រាប់ជាប្រតិចារឹក លោកប្រធាន យើងមានចម្លើយសារភាពរបស់ ម៉ែន ម៉េង ហៅ ឈិន លេខាកងពល៩២០ ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅខែកុម្ភៈ ឆ្នាំ៧៧។ ចម្លើយសារភាពនេះមានលេខ D175/3.41 គឺ D175/3.41 ឬក៏ IS5.49។ មានបញ្ជីពីរសំខាន់ដែលខ្ញុំនឹងបញ្ជាក់គឺជា*លីស*អ្នកទោសស-២១។ គឺឯកសារ IS7.73 ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ៧៧ ជា*លីស* --ជាបញ្ជីសម្លាប់អ្នកទោស ហើយដែលមានមនុស្ស៨០នាក់មកពីកងពល៩២០។ ហើយមានបញ្ជីអ្នកទោសស-២១ ទៀតចុះថ្ងៃទី០៥ មិថុនា ៧៧ ដែលមានលេខ D175/3.30 ដែលមានឈ្មោះមនុស្ស ៩០នាក់ដែលត្រូវបានចាប់ខ្លួននៅក្នុងកងពល៩២០។

ខ្ញុំនៅសល់ទូរលេខមួយទៀតដែលត្រូវបង្ហាញជូនលោកប្រធាន គឺលេខ E3/1204 ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧ ផ្ញើដោយសមមិត្ត ឆាន ជូនម៨៧០ ជាទីគោរពស្នេហាពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ និងជាពិសេសការប្រមូលទស្សនាវដ្តីទង់បដិវត្ត។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញជូនទូរលេខនេះទៅឲ្យសាក្សី ដើម្បីឲ្យគាត់បានពិនិត្យមើល។

[០៩:៤៨:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ខ្ញុំសូមអានទូវចំណុចទី១ នៅក្នុងទូរលេខនេះ "បញ្ហាឯកសារទស្សនាវដ្តី និងទង់បដិវត្តចាប់ពីឆ្នាំ៧៥ ដល់ឆ្នាំ៧៦ នោះ បានប្រមូលទុកដាក់ស្រួលហើយសម្រាប់មើលទៀត"។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី លោកអាចបញ្ជាក់បានទេថា ទស្សនាវដ្តីទង់បដិវត្ត ឬយុវជនយុវនារីបដិវត្តនេះតំបន់១០៥ ទទួលបានពីមជ្ឈិមប៉ុន្មានច្បាប់ដែរ?

[០៩:៥០:០០]

**ឆ៖** ខ្ញុំអត់ចាំទេបាទ។

**ស៖** ចុះលោកផ្ទាល់ តើលោកបានទទួលទស្សនាវដ្តីទង់បដិវត្ត ឬយុវនារី -- យុវជនយុវនារីបដិវត្តនេះទេ?

**ឆ៖** អត់ទេបាទ គេដាក់នៅកន្លែងសហករណ៍ជំនាន់ហ្នឹងបាទ។

**ស៖** ខ្ញុំស្តាប់ឮអម្បាញ់មិញនេះគឺថា ទស្សនាវដ្តីនេះត្រូវបានចែកជូនសហករណ៍ដោយតំបន់១០៥។ តើលោកឆ្លើយអ៊ីចឹងមែនទេ អម្បាញ់មិញនេះ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ ចំណុចទី៤ នៃទូរលេខនេះបញ្ជាក់ថា "សភាពការណ៍ខ្មាំងនៅក្រចេះ មានរត់ពីរនាក់ចូលស្រុកកែវសីមា យើងចាប់បានហើយ បានប្រគល់ជូនខាងក្រចេះហើយ"។ ខ្ញុំចង់ដឹងថានៅសម័យនោះ លោកដឹងទេថា នេះគឺជាបែបបទធម្មតាក្នុងការប្រគល់ទៅឲ្យភូមិភាគមួយ នូវអ្នកដែលរត់

ចេញពីភូមិភាគនោះ ហើយត្រូវបានចាប់ខ្លួននៅតំបន់១០៥។ តើអ៊ីចឹងមែនទេ?

[០៩:៥១:៣៩]

**ផ៖** ខ្ញុំអត់បានដឹងដែរបញ្ហានេះបាទ។

**ស៖** ចំណុច៥ នោះបញ្ជាក់ថា "ពួកដែលរត់ពីស្ទឹងត្រែងបីនាក់នោះ ខ្លាំងច្បាស់ណាស់ ពួកនេះមានរូបសីហនុ"។ តើលោកអាចបញ្ជាក់បានទេថា នៅសម័យនោះការមានរូបសីហនុ តាមខ្លួននោះ គឺបញ្ជាក់ថា អ្នកនុ៎ងហើយជាខ្មាំង។ តើអ៊ីចឹងមែនទេ?

**ផ៖** អាហ្នឹងខ្ញុំអត់ៗច្បាស់ដែរបាទ អត់ដឹងរូបសម្តេចអីគេថាខ្មាំង ជំនាន់ វាអត់ៗមានបាននិយាយអ៊ីចឹងទេបាទ។ តែមនុស្សជំនាន់ហ្នឹង ការសង្ស័យគ្នាហ្នឹង អាបន្តិចបន្តួចហ្នឹងក៏ខ្មាំងដែរ។ ខ្ញុំបញ្ជាក់ ដូចបញ្ជាក់ខាងដើមអ៊ីចឹង។ ឲ្យតែស្អីដែលប្លែកខុសពីមាគ៌ារបស់គេកំណត់ហ្នឹង គឺសន្មតថាខ្មាំង។ សូមបញ្ជាក់ប៉ុណ្ណឹង។

[០៩:៥៣:១៤]

**ស៖** បាទ សូមអរគុណ។ ខ្ញុំបញ្ចប់ការសាកសួរពាក់ព័ន្ធនឹងទូរលេខហើយលោកប្រធាន។ ឥឡូវនេះ ខ្ញុំចង់ដកស្រង់នៃឃ្លានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ពាក់ព័ន្ធនឹងរបាយការណ៍ដែលមកពីស្រុកនៅតំបន់១០៥។ ខ្ញុំសូម -- ដំបូងខ្ញុំសូមអាន ហើយបន្ទាប់មកខ្ញុំនឹងសួរសំណួរទៅកាន់សាក្សី គឺលេខ E3/58 គឺជាកំណត់ហេតុស្តាប់ចម្លើយលើកទី១ ជាភាសាខ្មែរ ខ្ញុំហាក់ដូចជាអត់មានភាសាខ្មែរទេ គឺជាភាសាបារាំងទំព័រ៣, ជាភាសាអង់គ្លេសទំព័រ៣។ បាទ ឥឡូវនេះខ្មែរគឺឃើញហើយ ទំព័រ៤។ បាទសូមអភ័យទោស គឺភាសាខ្មែរទំព័រ៣ទេ គឺ ERN 00239936។ គឺជាសំណួរទី២ ដែលក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ។

ខ្ញុំសូមដកស្រង់ "មន្ទីរស្រុកច្រើនតែរាយការណ៍មកអំពីការងារលើកទំនប់ ប្រឡាយ ការបង្កបង្កើនផល សុខាភិបាល ការតាមដានកម្លាំង សមាសភាពល្អ ឬមិនល្អ ក្បត់ឬសន្តិសម្ព័ន្ធ។ មន្ទីរក-១៧ច្រើនតែចេញការណែនាំត្រឡប់ទៅស្រុកវិញ ហើយនិងបូកសរុបការងារតាមស្រុក រួចរាយការណ៍ទៅមជ្ឈិមប្រចាំថ្ងៃ។ ចំពោះការរាយការណ៍អំពីសមាសភាពមិនល្អ ការណែនាំពីមជ្ឈិម -- ពីមន្ទីរក-១៧ មានដូចជា លើកទី១ អប់រំនៅមូលដ្ឋាន។ លើកទី២ អប់រំនៅមូលដ្ឋាន។ លើកទី៣ ត្រូវហៅមកអប់រំនៅមន្ទីរសន្តិសុខទំនប់ភ្នំក្រោល ដែលគ្រប់គ្រងដោយប្រធានវរសេនាតូចទី២ ឈ្មោះ ឡេង។ អ្នកដែលហៅយកមកអប់រំនៅមន្ទីរសន្តិសុខទំនប់ភ្នំក្រោលទាំងនោះ មានដូចជា មិនគោរពវិន័យ ខុសសីលធម៌

លួច ប្លន់ រត់គេចពីការងារ។ នៅគ្រប់លើកអ្នកដែលមានកំហុសត្រូវតែធ្វើប្រវត្តិរូប។ ហើយលោកបញ្ជាក់ថាចំពោះការបញ្ជាពីថ្នាក់មជ្ឈិមមកមន្ទីរក-១៧ ឲ្យចាប់ខ្លួននោះ គឺមិនដែលមានទេ" សូមបញ្ចប់ការដកស្រង់។

ខ្ញុំចង់ដឹងថា នៅសម័យនោះ នៅតំបន់១០៥ តើគេធ្វើយ៉ាងម៉េចដើម្បីអាចកំណត់បានថាអ្នកណាជាសមាសភាពល្អ ឬសមាសភាពមិនល្អ ក្បត់ ឬសន្តិសម្ព័ន្ធនោះ? តើមានលក្ខណៈវិនិច្ឆ័យដូចម្ដេចខ្លះដើម្បីអាចឲ្យយើងដឹងថាអ្នកណាជាសមាសភាពល្អ មិនល្អ ក្បត់ ឬសន្តិសម្ព័ន្ធនោះ?

[០៩:៥៦:៤៣]

**ឆ៖** កាលជំនាន់នុ៎ងគេ អាហ្នឹងដូចខ្ញុំបញ្ជាក់ខាងលើអ៊ីចឹង។ ពីណាអត់សូវគោរពគេអីហ្នឹង គេថាសន្តិសម្ព័ន្ធ ហើយពួកអនុធន ពួកគ្រូចាស់ ពួកទាហានចាស់ ពួកស្អីហ្នឹង ពួកប្រវត្តិរូបដើមហ្នឹង មិនល្អហ្នឹងគេដកចេញហើយបាទ។ អាហ្នឹងសូមបញ្ជាក់បណ្ណឹង។

**ស៖** ហើយនៅចំណុចនេះដដែល តើលក្ខណៈវិនិច្ឆ័យដែលគេអនុវត្តនោះដែលឪពុករបស់លោកហើយនិងគណៈតំបន់១០៥ បានអនុវត្តនោះ ដែល -- តើលក្ខណៈវិនិច្ឆ័យនេះត្រូវបានកំណត់ដោយឪពុកលោក ឬ/និងគណៈតំបន់១០៥ ឬដោយមជ្ឈិម?

**ឆ៖** អាហ្នឹងខ្ញុំអត់យល់ច្បាស់ដែរ តែធម្មតាថ្នាក់តំបន់អត់មានសិទ្ធិអីកំណត់ដោយខ្លួនឯងទេ។ ព្រោះទិសមាគ៌ារួមនុ៎ង មកពីខាងលើ អនុវត្តតាមខាងលើទាំងអស់។ ហើយការចាប់ខ្លួន ដកស្អីៗហ្នឹង គេមិនមានមកចាប់ខ្លួននៅតំនប់ទេបាទ គឺគេមកខាងលើអ៊ីចឹងថាមករៀនសូត្រ គេរៀនសូត្រនយោបាយជារៀនបច្ចេកទេសស្អីក៏ដោយ ឲ្យតែមនុស្សមក មកបាត់បណ្ដោយ។ ហើយបានប្រកាសតាមក្រោយដូចបានបញ្ជាក់ខាងលើអ៊ីចឹងឯងបាទ។

[០៩:៥៨:៣០]

**ស៖** បើតាមបញ្ជាពីមជ្ឈិមអ្នកដែលគេផ្ទេរពីមន្ទីរសន្តិសុខភ្នំក្រោលនោះ ត្រូវបញ្ជូនទៅភ្នំពេញឬក៏យ៉ាងម៉េច?

**ឆ៖** សូមបញ្ជាក់ម្ដងទៀតបាទ អត់ច្បាស់បាទ។

**ស៖** បើតាមបញ្ជាដែលមជ្ឈិមចេញនោះ តើធ្លាប់មានការបញ្ជូនមនុស្សពី -- អ្នកទោសនោះពីមន្ទីរសន្តិសុខភ្នំក្រោលទៅភ្នំពេញដែរឬទេ?

**ឆ៖** អ្នកទោសនៅភ្នំក្រោលអត់មានទេបាទ។ ព្រោះកាលជំនាន់ហ្នឹង កាលជំនាន់ខ្ញុំនៅនុ៎ងវាអត់

មានអ្នកទោស អ្នកធ្ងន់អីនៅហ្នឹង គេបញ្ជូនចាប់អីមកក្រោម អត់មានទេ។ ដូចខ្ញុំបានបញ្ជាក់ខាងលើ អីចឹងអ្នកដែលចាប់មកក្រោមហ្នឹងគេ មករៀនសូត្រ មិនមែនចាប់នៅតំបន់ទេ។ កន្លែងនៅតំបន់ហ្នឹង អង្គាល់ហ្នឹងមានតែកន្លែងអប់រំធម្មតា អ្នកទោសស្រាលៗទេ ដូចបានបញ្ជាក់អីចឹង។ តែទោសដល់ប្រហារជីវិតអីអត់មាននៅនឹងហ្នឹងទេជំនាន់ហ្នឹង តែក្រោយមកទៀតមិនដឹងដែរបាទ។ សូមបញ្ជាក់ប៉ុណ្ណឹង។

[១០:០០:២១]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមមកនិយាយអំពីរយៈពេលក្រោយពេលដែលឪពុកលោកស្លាប់ហើយ ខ្ញុំសូមចោទសំណួរជាក់លាក់ទាក់ទងទៅនឹងមរណភាពរបស់ឪពុកលោកដោយសារពេលវេលាកាន់តែទៅមុខហើយ ហើយលោកបានលម្អិតអំពីកាលៈទេសៈនេះនៅក្នុងចម្លើយរបស់លោកកំណត់ហេតុស្តាប់ចម្លើយរបស់លោក។ ម្សិលមិញនេះ លោកបាននិយាយជាច្រើនដងថា នួន ជា បានកោះហៅកម្មាភិបាលដើម្បីចូលរួមសិក្ខាសាលា ឬក៏កិច្ចប្រជុំ។ ហើយក្រោយមកទៀត បុគ្គលទាំងអស់នេះក៏បាត់ខ្លួន ហើយលោកបានផ្តល់ឈ្មោះផងដែរ។ តើចំពោះការកោះហៅឪពុកលោកនេះ និងហៅ ខាំ ភួន ក្រោយមកនៅពេលដែលពួកគាត់មកភ្នំពេញ ហើយក្រោយមកពួកគាត់ត្រូវបានគេប្រហារជីវិត។ តើអីចឹងមែនទេ?

**ផ៖** បាទ។

**ស៖** បាទ សូមអរគុណ។ បន្ទាប់ពីឪពុកលោកស្លាប់ហើយ លោកបាននិយាយថា លោកបានចាប់ផ្តើមធ្វើការជាអ្នកបើកឡាននៅ ក-២ ជាមួយនឹង អៀង ធីរិទ្ធ ហើយគឺថារយៈពេលប្រហែលជា ៣ខែ ហើយក្រោយមកទៀតលោកបានទៅដាំដំណាំ។ តើមន្ទីរដែល អៀង ធីរិទ្ធិ ធ្វើការ ហើយនិងស្នាក់នៅនោះឈ្មោះអ្វី?

[១០:០២:០៤]

**ផ៖** បាទ ខ្ញុំសូមបញ្ជាក់អីចឹង។ មិនមែនខ្ញុំទៅធ្វើការបើកឡានឲ្យគាត់ហើយមកដាំដំណាំទេ។ ឪពុកខ្ញុំស្លាប់ហើយ ខ្ញុំនៅដាំដំណាំ រួចហើយបានគាត់យកខ្ញុំមកបើកឡានជាមួយគាត់។ បាទ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។ ហើយមន្ទីរដែលខ្ញុំនៅហ្នឹង គឺគេហៅក-២ នៅជំនាន់ហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ ក្នុងឋានៈជាអ្នកបើកបរ បើកឡាននៅក-២ ឲ្យ អៀង ធីរិទ្ធ តើលោកអាចជម្រាបតុលាការ បានដែរឬទេ ថា អៀង ធីរិទ្ធ ជួបអ្នកដឹកនាំដូចជា ប៉ុល ពត, នួន ជា, អៀង

សារី, ខៀវ សំផន, សុន សេន ហើយនិងអ្នកដឹនាំផ្សេងទៀតញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំចាំអត់បានដែរបាទ។

**ស៖** បើសិនជាលោកមិនចាំទេ ទាក់ទងទៅនឹងអ្នកដឹកនាំទាំងអស់នេះ តើលោកចាំទេករណីលោក នួន ជា? តើអ្នកស្រី អៀង ធីរិទ្ធ ធ្លាប់ទៅជួប នួន ជា ញឹកញាប់ប៉ុនណាដែរ?

[១០:០៣:៣៦]

**ឆ៖** រឿងញាប់អីហ្នឹងខ្ញុំចាំមិនបានដែរ។ ប៉ុន្តែរឿងជួបៗ បាទ តែរឿងញាប់ប៉ុនណាវាដូចជាពិបាកនិយាយដែរ មិនដឹងវាប៉ុន្មានខែម្តង ប៉ុន្មានថ្ងៃម្តងវាអត់ច្បាស់ទេបាទ ប៉ុន្តែគ្រាន់តែដឹងថាវាបានជួប។

**ស៖** ហើយគាត់ជួប នួន ជា នោះនៅកន្លែងណាដែរ?

**ឆ៖** ចាំកន្លែងអត់បានដែរបាទ។

**ស៖** សូមអរគុណ។ លោកប្រធាន ឥឡូវនេះ ខ្ញុំសុំប្រើឯកសារមួយដើម្បីរំឭកដល់សាក្សីគឺថាកំណត់ហេតុកត់ចម្លើយទីបីរបស់គាត់ គឺ E3/447។ ខ្ញុំមិនអានលេខ ERN ទេ ព្រោះថាសំណួរនិងចម្លើយហ្នឹងសុទ្ធតែមានកត់លេខ។ ខ្ញុំសូមយោងទៅនឹងសំណួរចម្លើយលេខ៨ និងលេខ៩។ សំណួរទី៨ដូចតទៅនេះ "តើលោកដឹងថា នួន ជា និងអ្នកស្រី អៀង ធីរិទ្ធ មានទំនាក់ទំនងគ្នាដែរឬទេ?" ចម្លើយរបស់សាក្សី "គឺពួកគាត់ទាំងពីរមានទំនាក់ទំនងគ្នា គឺប្រជុំជាមួយគ្នា១ខែ ពីរ ឬបីដង។ ខ្ញុំដឹង ព្រោះខ្ញុំបានជូនលោកស្រី អៀង ធីរិទ្ធ ទៅជួបលោក នួន ជា"។ សំណួរទី៩៖ "តើអ្នកស្រីអៀង ធីរិទ្ធទៅជួបជាមួយ នួន ជា ឬក៏លោក នួន ជា មកប្រជុំនៅក្រសួងសង្គមកិច្ច?"។ ចម្លើយ៖ "ជាទូទៅ លោកនួន ជា កោះហៅលោកស្រី អៀង ធីរិទ្ធ ទៅប្រជុំនៅក-៣"។ សំណួរទី១០៖ "លោក នួន ជា មានឥទ្ធិពលគ្របដណ្តប់នូវការត្រួតពិនិត្យទៅលើមន្ទីរពេទ្យដែរឬទេ?" ហើយចម្លើយ៖ "កាលនោះ គេមានរចនាសម្ព័ន្ធគ្រប់គ្រងតាមខ្សែបណ្តោយ ការងាររដ្ឋបាលមួយចំនួនត្រូវតែរាយការណ៍ទៅ នួន ជា"។ តើលោកដឹងថាគាត់ជួបគ្នាញឹកញាប់ប៉ុនណាដែរ?

[១០:០៦:១៥]

**ឆ៖** ដូចបាន -- ខ្ញុំបញ្ជាក់ហើយនៅក្នុងគេសួរខ្ញុំហ្នឹង។ គ្រាន់ថាវាមិនចាំប្រាកដទេ ព្រោះអង្គាល់សួរហ្នឹង គ្រាន់តែសន្ទនាគ្នា និយាយ "អឺ! ប្រហែលគាត់ជួបៗគ្នា ជូនគាត់ទៅអឺចឹងទៅ គេហៅថា ក-៣ ហើយខ្ញុំក៏នៅក្រៅអឺចឹងទៅ"។ ចួនណាអត់ប្រាកដប្រជាថា អឺ គាត់ជួបគ្នា ១ខែ ពីរដង ឬបីដង

ប្រាកដប្រជាតែម្ដង អត់ៗប្រាកដអ៊ីចឹងទេបាទ។ សូមបញ្ជាក់ត្រង់ហ្នឹងឡើងវិញ។ ដែលកាលជួបហ្នឹងជួបមែន។

**ស៖** តើលោកដឹងដែរឬទេថា តើ អៀង ធីរិទ្ធ ត្រូវរាយការណ៍អំពីសកម្មភាពរបស់ក្រសួងរបស់គាត់នោះទៅកាន់អ្នកណា?

**ឆ៖** អត់បានទេបាទ មិនដឹងគាត់រាយការណ៍ម៉េច អត់ដឹងដែរ។ ដឹងតែជូនគាត់ទៅ ហើយនៅតែក្រៅ មិនដែលបានទៅជាមួយគាត់ទេបាទ។

**ស៖** បាទ លោកសាក្សីសូមអរគុណ។ តើអ្នកស្រី អៀង ធីរិទ្ធ នៅពេលដែលគាត់ទៅប្រជុំនៅក-៣ ជាច្រើនដងក្នុង១ខែនោះ តើគាត់ទៅទីនោះតែម្នាក់ឯង ឬក៏គាត់ទៅដោយមានអមដំណើរពីកម្មាភិបាលរបស់ក្រសួងរបស់គាត់?

**ឆ៖** ហ្នឹងអត់ទៀងទេបាទ ជួនកាលគាត់ទៅតែឯង ជួនកាលហ្នឹងមានកម្មាភិបាលទៅជាមួយដែរ។ ចាំបានតែប៉ុណ្ណឹងបាទ។

[១០:០៨:០៤]

**ស៖** នៅពេលដែលលោកជូន អៀង ធីរិទ្ធ ទៅមន្ទីរក-៣ តើលោកមានចាំថាឃើញថាមានកម្មាភិបាលផ្សេងទៀតទៅប្រជុំនៅទីនោះដែរ ឬមេដឹកនាំផ្សេងទៀតទៅប្រជុំនៅទីនោះដែរឬទេ? ហើយមានគេធ្លាប់និយាយប្រាប់លោកទេថា មានអ្នកផ្សេងទៀតទៅប្រជុំទីនោះក្រៅពីអ្នកស្រី អៀង ធីរិទ្ធ?

**ឆ៖** អត់បានដឹងទេបាទ។ ដឹងតែទៅពី ខ្លួនឯងទៅដឹកគេទៅអ៊ីចឹងទៅ នៅត្រឹមរបងហ្នឹងគេ -- យើងបកមកវិញមក ឬក៏ជួនថ្ងៃណាគាត់មកវិញល្ងាចទៅ ល្ងាចនៅចាំនៅមាត់ទ្វារហ្នឹងទៅ នៅកន្លែងគេឲ្យចាំ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។ អត់បានចូលក្នុងរបងទេបាទ។

**ស៖** តើលោកធ្លាប់ឃើញមានឡានផ្សេងទៀតទៅដែរឬទេ? ហើយលោកធ្លាប់ជួបអ្នកបើកឡានផ្សេងទៀតដែលចាំនៅក្រៅដែរ? ហើយលោកមានដឹងថាអ្នកបើកឡានទុំផ្សេងទៀតហ្នឹង អ្នកបើកឡានឲ្យអ្នកណាដែរ ឲ្យអ្នកដឹកនាំណាដែរ?

**ឆ៖** អត់មានទេបាទ។

[១០:០៩:៣៦]

**ស៖** លោកបាននិយាយយ៉ាងច្បាស់ថា "អៀង ធីរិទ្ធ ជួប នួន ជា ពីរបីដងក្នុង១ខែ" តើហេតុអ្វីក៏លោកដឹងថាគាត់ទៅជួប នួន ជា បើសិនលោកមិនបានចូលទៅក្នុងបរិវេណ ក-៣ ផងនោះ?

**ផ៖** នេះជំនាន់ហ្នឹង ដឹងថាអ៊ំគាត់នៅហ្នឹង។

[១០:១០:១៤]

**ស៖** តើ អៀង ធីរិទ្ធ និងកម្មាភិបាលក្រសួងសង្គមកិច្ចនោះ ដែលទៅក-៣ នោះ គាត់មិនដែលបានប្រាប់ថាគាត់ទៅទីនោះដើម្បីជួប នួន ជា ទេឬ?

**ផ៖** អត់ទេបាន អត់មានបាននិយាយអ៊ីចឹងទេ។

**ស៖** បាទ ឥឡូវខ្ញុំសូមចូលទៅនិយាយប្រធានបទថ្មីមួយទៀត ខ្ញុំនៅសល់ប្រធានបទពីរ។ យើងចង់កំណត់អំណាចក្រសួង អ៊ំ! រដ្ឋមន្ត្រីនៅសម័យនោះ។ ហើយលោកបាននិយាយជាច្រើនទៅចៅក្រមស៊ើបអង្កេតទាក់ទងនឹងក្រសួងសង្គមកិច្ច។ លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់ គឺថាឯកសារ E3/447 សំណួរ-ចម្លើយទី៧។ "អៀង ធីរិទ្ធ មានសិទ្ធិតែងតាំង និងដក (បោសសម្អាត) កូនចៅរបស់ខ្លួន ហើយនិងកោះប្រជុំ ហើយនិងតាមដានបុគ្គលិកមន្ទីរពេទ្យដើម្បីរកខ្មាំងស៊ីរូងផ្ទៃក្នុង"។ នៅពេលដែលលោកនិយាយថាគាត់មានសិទ្ធិដកកូនចៅរបស់ខ្លួន អ្នកនៅក្រោមបង្គាប់របស់ខ្លួន ឬក៏បោសសម្អាតនេះ តើពាក្យ "ដក" ហើយនិង "បោសសម្អាត" នេះមានន័យដូចគ្នា ឬក៏យ៉ាងម៉េចនៅសម័យនុ៎ង? ហើយលោកស្រី អៀង ធីរិទ្ធ ហ្នឹង គាត់មានសិទ្ធិអំណាចធ្វើយ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច? គឺថា "ដក" ហើយនិង "បោសសម្អាត" នេះ?

[១០:១២:១០០]

**ផ៖** ខ្ញុំអត់យល់ន័យអារឿងបោសសម្អាតហ្នឹងដែរ កាលពីជំនាន់ហ្នឹងបាទ។ តែក្នុង -- ដែលខ្ញុំនិយាយថា គាត់ៗមានសិទ្ធិនោះ ព្រោះគាត់ជាអ្នកទទួលខុសត្រូវនៅហ្នឹង គាត់មានសិទ្ធិចង់ដកអ្នកណាក៏បានដែរជំនាន់ហ្នឹងនោះ។ ខ្ញុំចង់បញ្ជាក់ប៉ុណ្ណឹង។ តែអំណាចយ៉ាងម៉េច អីយ៉ាងម៉េចហ្នឹង ខ្ញុំអត់យល់ដែរ ប៉ុន្តែធម្មតាអ្នកដឹកនាំមិនថាថ្នាក់ទាប ឬថាថ្នាក់ខ្ពស់ទេជំនាន់ហ្នឹងនោះ បើថាអត់មានបទបញ្ជាខាងលើ គ្មានអ្នកណាហ៊ានធ្វើទេ។ សូម្បីតែអ្នកស្រី អៀង ធីរិទ្ធ ក៏គាត់មិនហ៊ានដែរ បើថាអត់មានបទបញ្ជាខាងលើ ពិតមែនតែគាត់មានសិទ្ធិប្រាប់ ឬក៏ដក តែងតាំងស្អីៗអ៊ីចឹងមែន ប៉ុន្តែគាត់អត់មានសិទ្ធិដូចថាសម្រេចយ៉ាងណាៗដោយ ៗចិត្តគាត់ អត់មានទេ។ ព្រោះជាៗគោលការណ៍ គឺទាក់តែខាងលើសម្រេច។ គ្រប់ម៉ាត់ក៏និយាយខាងលើដែរជំនាន់ហ្នឹង។ ទៅពាក្យ "ខាងលើ"ហ្នឹង ខ្ញុំអត់យល់ន័យច្បាស់ថា "ខាងលើ" យ៉ាងណា អីយ៉ាងណាទេ។ ស្អីក៏លើៗ អ៊ីចឹងបាទ។ ខ្ញុំបញ្ជាក់ជូនតុលាការអ៊ីចឹងបាទ។

[១០:១៣:២៩]

**ស៖** ហើយលោកក៏បាននិយាយផងដែរ នៅក្នុងសម្រង់ដដែលនេះ និយាយពីការដែលថាគាត់មានសិទ្ធិតាមដានបុគ្គលិកមន្ទីរពេទ្យដើម្បីរកខ្មាំងស៊ីរូងផ្ទៃក្នុង។ តើនៅពេលដែលយើងនិយាយថា "តាមដានបុគ្គលិកមន្ទីរពេទ្យ"នេះ គឺជាការចង់និយាយថាយ៉ាងម៉េច ការតាមដានហ្នឹងមានន័យយ៉ាងម៉េចដែរ?

**ផ៖** តាមដានហ្នឹងន័យត្រង់ថា តាមដានសភាព ការធ្វើការងារ ឬខាងគោលជំហរនយោបាយស្អីៗទាំងអស់ហ្នឹងបាទ។

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយរបស់លោក លោកនិយាយអំពីការចាប់ខ្លួន ស៊ូ ហើយនិង ប៉ក់ នៅក្រសួងសង្គមកិច្ច។ ហើយមុខងាររបស់ ស៊ូ ហើយនិង ប៉ក់ នៅក្រសួងសង្គមកិច្ចនេះ អ្វីដែរ? គាត់ធ្វើអ្វីដែរ?

**ផ៖** ជំនាន់ហ្នឹងដូចគាត់ធ្វើអនុប្រធានមន្ទីរក-២ ហ្នឹងបាទ អនុប្រធាន ឬក៏អនុប្រធានទទួលសង្គមកិច្ច ខ្ញុំអត់ដឹងដែរបាទ ព្រោះអត់ វាអត់មានប្រកាសជាផ្លូវការអីអ៊ីចឹងទេ។ តែដឹងថា គាត់រងពីអ្នកស្រី អៀង ធីរិទ្ធ តែប៉ុណ្ណឹងបាទ។

[១០:១៥:១០]

**ស៖** លោកចង់និយាយពី ប៉ក់ ឬពី ស៊ូ ទាំងពីរនាក់នេះ សុទ្ធតែជាប្រធាន ក-២ ឬយ៉ាងម៉េច? សូមបញ្ជាក់បន្តិច អនុក-២ ឬម៉េច? សូមបញ្ជាក់បន្តិចលោក។

**ផ៖** បញ្ជាក់ មីងស៊ូ បាទ អនុក-២។

**ស៖** ហើយឈ្មោះ ប៉ក់ នេះមានមុខងារអ្វីដែរ?

**ផ៖** មីងប៉ក់ ហ្នឹងមុខងារគាត់នៅមន្ទីរពេទ្យ ប្រធានពេទ្យ កន្លែងផលិតថ្នាំពេទ្យ (ច្រឡំអត់ទោស) ប្រធានកន្លែងផលិតថ្នាំពេទ្យ។ អង្គាល់នុំងដូចហៅ ផ-១ អ៊ីចឹងឯងបាទ។

[១០:១៦:១៨]

**ស៖** តើលោកធ្លាប់នាំ ស៊ូ ហើយនិង ប៉ក់ នោះទៅមន្ទីរក-៧ ដែរឬទេ ដែលជាមន្ទីរនីរសារ?

**ផ៖** ធ្លាប់ជូនគាត់ទៅម្តងហ្នឹង ហើយបាត់ខ្លួនរហូតហ្នឹងបាទ។

**ស៖** បាទ ជាភាសាបារាំងយើងឃើញមានការបកប្រែនៅឯករចនៈ។ អ៊ីចឹងលោកចង់និយាយពីមនុស្សទាំងពីរហ្នឹងដែលលោកជូនទៅ ឬក៏លោកយ៉ាងម៉េច? លោកចង់និយាយថា លោកជូនបុគ្គលទាំងពីររូបហ្នឹងទៅមន្ទីរក-៧ ឬក៏យ៉ាងម៉េច?

**ផ៖** បាទ ជូនគាត់ទៅមន្ទីរក-៧។ ជូនតែម្តងហ្នឹងទេ អត់ដែលជូនញឹកញាប់ទេ។

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំឮអំមិញបកប្រែជាភាសាបារាំងនេះក-១ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ថា ជូនទៅក-១ ឬក-៧ លោកសាក្សី?

**ឆ៖** ក-៧ បាទ។

**ស៖** បាទ សូមអរគុណ។ តើអ្នកណាជាអ្នកបញ្ជាលោកឲ្យជូន ស៊ូ និង ប៉ក់ នេះទៅក-៧?

**ឆ៖** អង្គាល់ហ្នឹងអ៊ំស្រី អៀង ធីរិទ្ធ គាត់ឲ្យជូនទៅ។

**ស៖** តើមានការបញ្ជាក់ដែរឬទេថា បុគ្គលទាំងពីររូបនេះត្រូវបានកោះហៅទៅប្រជុំទេ?

**ឆ៖** អត់មានបញ្ជាក់អីទេបាទ គ្រាន់តែថាឲ្យជូនទៅក-៧ តែប៉ុណ្ណឹងបាទ។

[១០:១៨:៥៥]

**ស៖** ហើយបន្ទាប់មកទៀត ថ្ងៃបន្តបន្ទាប់មកទៀតនោះតើអ្នកស្រី អៀង ធីរិទ្ធ មានបាននិយាយអំពី ស៊ូ ហើយនិង ប៉ក់ ដែរឬទេ នៅក្នុងពេលប្រជុំ?

**ឆ៖** យូរដែរបាននិយាយបាទ ប្រហែលជាកន្លះខែអីដឹង តាមចាំប្រហែលជាកន្លះខែហ្នឹងគេប្រជុំប្រកាសថា ក្បត់តែប៉ុណ្ណឹងបាទ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមយោង -- ដកស្រង់ចម្លើយទី៩ របស់លោក អ៎! ១៤ សូមទោស។ "បន្ទាប់ពីកោះប្រជុំបុគ្គលិកនៅក្រសួងសង្គមកិច្ច យាយភា ប្រកាសថា បុគ្គលទាំងពីររូបនេះជាជនក្បត់ បាទ ដោយអានសារាចរចេញពីមន្ទីរក-៣។ តើសារចរ ក-៣ ហ្នឹងជាសារចរមួយណានៅពេលដែលគាត់និយាយនៅក្នុងកិច្ចប្រជុំ? តើហេតុអីបានជាលោកដឹងថាសារាចរនេះចេញពីមន្ទីរក-៣? តើ អៀង ធីរិទ្ធ គាត់និយាយថាជាសារាចរ ក-៣ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អ្នកស្រី អៀង ធីរិទ្ធ គាត់ប្រាប់ថា សារាចរពីក-៣ មក គាត់ប្រកាសនៅកន្លែងសាលប្រជុំតែម្តង។

[១០:២០:៤០]

**ស៖** នៅពេលដែលលោកនិយាយអំពី ក-៣នោះ តើលោកដឹងអំពីទំនាក់ទំនងរវាង ក-៣ ហើយនិងមន្ទីរ៨៧០ ទាក់ទងទៅនឹងទូរលេខជាច្រើនដែលបានផ្ញើចេញចូលដែរឬទេ ទៅវិញទៅមក?

**ឆ៖** អត់ដឹងទេបាទ។

**ស៖** លោកប្រធានដើម្បីជាប្រតិចារឹក ខ្ញុំចង់ជម្រាបជូនថា នៅក្នុងសំណុំរឿងមានឯកសារ IS5.95 ដែលជាចម្លើយសារភាពរបស់ ស៊ិន ផល្គុន ហៅ ស៊ូ ហើយឯកសារនេះចុះនៅថ្ងៃទី១៣ មីនា

១៩៧៨ នេះគឺជាបញ្ជីមួយទៀត គឺថាបញ្ជីអ្នកទោសដែលមានលេខ E3/1535 ដែលជាអ្នកទោសនៅមន្ទីរស-២១ ។ ហើយលេខរៀងទី២៤ មានឈ្មោះ ភី រូ ហៅ ប៉ក់ -- អ៊ុយ ភីរូ ហើយចូលនៅ ថ្ងៃទី២១ កុម្ភៈ ឆ្នាំ១៩៧៨ នៅមន្ទីរស-២១។ ក្រៅពីកម្មាភិបាលជាន់ខ្ពស់ដែលជាអនុ អៀង ធីរិទ្ធ ហ្នឹង តើមានការបាត់ខ្លួននៅក្រសួងសង្គមកិច្ចផ្សេងទៀតទេ នៅឆ្នាំ១៩៧៨ គឺនៅក្នុងឆ្នាំដែលលោកធ្វើការនៅទីនោះ?

**ឆ៖** ខ្ញុំចាំមិនបានអស់ដែរបាទ ជំនាន់នោះ។ តែមនុស្សបាត់ច្រើន មិនដឹងអ្នកណាខ្លះចាំឈ្មោះមិនបាន។

**ស៖** តើមុននឹងបុគ្គលទាំងអស់នេះបាត់ខ្លួន តើដូចកម្មាភិបាលនៅតំបន់១២៥ ដែរ --គឺថា អ៎! ១០៥ ដែរ គឺថាគេកោះហៅទៅប្រជុំ តើគេធ្វើយ៉ាងម៉េចដែរ មុននឹងគេចាប់ខ្លួនបុគ្គលទាំងអស់នេះ?

**ឆ៖** ដូចបានបញ្ជាក់ខាងលើអ៊ីចឹង ហៅទៅធ្វើការរៀនសូត្រ។ ធ្វើការរៀនសូត្របាត់ខ្លួនៗ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

[១០:២៣:៣៧]

**ស៖** ហើយចំពោះអ្នកដែលត្រូវគេចាប់ខ្លួននៅក្រសួងសង្គមកិច្ចដែលគេកោះហៅទៅប្រជុំ ឬបណ្ដុះបណ្ដាលហ្នឹង តើអ្នកណាអ្នកចេញការកោះហៅនៅក្រសួងសង្គមកិច្ចនេះ អ្នកណាអ្នកចេញការកោះហៅ?

**ឆ៖** ខ្ញុំមិនបានដឹងដែររឿងហ្នឹងបាទ គ្រាន់តែឃើញមនុស្សបាត់ប៉ុណ្ណឹង ដឹងតែបាត់អ្នកនេះ បាត់អ្នកនោះ តែការចេញ ឱ្យហៅអ្នកណាអីអ្នកណា បញ្ជាពីអ្នកណាក៏ខ្ញុំមិនបានដឹងទេ ពីព្រោះខ្ញុំនៅតែបើកឡានបាទ។

**ស៖** បាទសូមអរគុណ។ លោកនិយាយអំពីការបាត់ខ្លួន និងការចាប់ខ្លួនជាច្រើននៅក្រសួងសង្គមកិច្ច តើនៅក្រសួងសង្គមកិច្ចគឺថា ក-២ នេះ ហើយនិងនៅតាមមន្ទីរពេទ្យ ហើយនិងតាមរោងចក្រផលិតថ្នាំ ឬក៏មន្ទីរពិសោធន៍ផ្សេងៗ តើលោកធ្លាប់បានសង្កេតឃើញថា មានការខ្វះកម្មាភិបាលមានសមត្ថភាពនៅឆ្នាំ១៩៧៨ ដោយសារតែមានការចាប់ខ្លួនដ៏ច្រើននេះ។ តើលោកធ្លាប់បានសង្កេតឃើញអ៊ីចឹងទេ?

[១០:២៥:១១]

**ឆ៖** សង្កេតឃើញៗអ៊ីចឹងបាទ អត់ៗ -- ខ្វះមនុស្សធ្វើការ។

**ស៖** លោកបាននិយាយអំពីការងារកូនរបស់ អៀង ធីរិទ្ធ, អៀង សារី ទាំងបីនាក់។ កូនស្រី

របស់គាត់ទាំងបីនាក់ក្នុងចម្លើយរបស់លោកនៅក្នុងក្រសួងសង្គមកិច្ច។ គឺថាឈ្មោះ មិញ ប្រធានពេទ្យ ហើយ នាដ នៅក្នុងខាងហ្វាម៉ាស៊ី –ខាងផលិតឱសថ– ហើយនិងឈ្មោះ វ៉ា។ នៅក្នុងចុងឆ្នាំ១៩៧៨ មានកម្មាភិបាលជាច្រើននៅធ្វើការ ឬក៏ភាគច្រើននៃកម្មាភិបាលទាំងអស់ហ្នឹងត្រូវបានបោសម្អាតហើយ?

**ឆ៖** តាំងពីខ្ញុំមកនៅជាមួយគាត់ អ្នកទាំងបីនាក់ហ្នឹងគេនៅធ្វើការនៅហ្នឹងស្រាប់បាទ។

**ស៖** បាទ លោកសាក្សី សំណួរចុងក្រោយ លោកនិយាយអំពី ក-៧ ជាមន្ទីរនីរសារនៅក្នុងចម្លើយរបស់លោក ហាក់ដូច -- កំណត់ហេតុស្តាប់ចម្លើយរបស់លោក ហាក់ដូចជាមាននិយាយពី ក-១៧។ តើមន្ទីរនីរសារនេះមានឈ្មោះជាលេខកូដ ក-១៧ ឬក៏ ក-៧?

[១០:២៧:២២]

**ឆ៖** ខ្ញុំចង់ច្រឡំដែរ ក-១៧ ឬក៏ ដូចជាក-១៧ បើខ្ញុំចាំច្បាស់គឺ ក-១៧ ហ្នឹងហើយនៅមុខវាំងហ្នឹងបាទ។ នៅជាប់មាត់ទន្លេ ហ្នឹងគេហៅថា ក-១៧។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** តើមូលហេតុនៃការភ័ន្តច្រឡំនេះមិនមែនមកពីនៅក្នុងតំបន់១០៥នោះ មានមន្ទីរមួយដែរឈ្មោះក-១៧ តើមកពីមូលហេតុអ៊ីចឹង ឬក៏យ៉ាងម៉េចបានធ្វើឲ្យលោកភ័ន្តច្រឡំ ឬក៏មានលក្ខណៈច្របូកច្របល់នេះ?

**ឆ៖** បាទ វាៗអ៊ីចឹងបាទ។

**ស៖** តើអ្នកណាជាប្រធានមន្ទីរក-១៧ នៅភ្នំពេញ? ហើយលោកក៏បាន -- កន្លែងដែលលោកនាំស្ទូ ហើយនិង ប៉ក់ ទៅនេះមន្ទីរក-១៧ ហ្នឹង អ្នកណាជាប្រធាន?

**ឆ៖** កាលជំនាន់ហ្នឹងឈ្មោះ គូ មុនហ្នឹងទៀត ខ្ញុំអត់ដឹងទេ។ អង្កាល់ជំនាន់ហ្នឹងឈ្មោះ គូ សូមបញ្ជាក់ប៉ុណ្ណឹង។ ហើយឈ្មោះពីរ គូ ឬ គី ពីរៗហ្នឹង គេហៅ ប្រើឈ្មោះពីរហ្នឹងបាទ។

**ស៖** បាទ សូមអរគុណដែលបានបំភ្លឺ។

**លោក វាំងសង់ វ៉ាយជ៍ ដេស្សាឯល៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ លោកសាក្សី សូមអរគុណដែលបានអត់ធ្មត់ឆ្លើយសំណួរខ្ញុំ។ លោកប្រធាន ខ្ញុំសង្ឃឹមថាខ្ញុំចោទសំណួរទាំងអម្បាលម៉ាននេះមិនមានសំណួរអត់ប្រយោជន៍ទេ ហើយអ៊ីចឹងខ្ញុំសូមផ្តល់វេទិកាទៅឲ្យខាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។

[១០:២៩:៣១]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣០:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សួស្តីសហព្រះរាជអាជ្ញា សួស្តីសហភាគី សួស្តីអស់លោកទាំងឡាយដែលចូលរួមសវនាការនៅទីនេះ ទោះនៅក្នុងបន្ទប់ ឬក្រៅបន្ទប់ក្តី។ ខ្ញុំមានការកត់សម្គាល់មួយយ៉ាងចម្លែកបំផុត អម្បាញ់មិញសហព្រះរាជអាជ្ញាដែលបានបញ្ចប់សំណួរចម្លើយរបស់គាត់ គាត់បាន -- ដូចជា ធ្វើការកត់សម្គាល់ ឬក៏ណែនាំថាសំណួររបស់គាត់ទាំងប៉ុន្មានមិនអត់ប្រយោជន៍ទេ។ នេះជាៗការចម្លែកបំផុតដែលយើងមិនដែលឮ មិនដែលជួបប្រទះ។ ទី២ សហព្រះរាជអាជ្ញាបានសួរដេញដោលច្រើនទាញយកអង្គហេតុ ហើយពីករណីទាក់ទងនឹងអ្នកស្រី អៀង ធីរិទ្ធ ក៏ដូចជាក្រសួងសង្គមកិច្ចដែលយើងទាំងអស់គ្នាដឹងថា សំណុំរឿង ឬលោកស្រី អៀង ធីរិទ្ធ បានត្រូវបែកចែក ឬញែកដាច់ចេញពីសំណុំរឿង០០២/០១ នេះទៅហើយ ក៏ប៉ុន្តែបើនិយាយពីរឿងរចនាសម្ព័ន្ធៗរដ្ឋបាល អាហ្នឹងខ្ញុំមិនយល់ទាស់ទេ ប៉ុន្តែបើនិយាយពីករណីពាក់ព័ន្ធបទចោទទៅលើលោកស្រី អៀង ធីរិទ្ធ វាជាការ ជាសំណួរ ឬចម្លើយដែលមិនពាក់ព័ន្ធនឹងសំណុំរឿងសោះ។ យើងសោកស្តាយដែលៗមិនបានធ្វើការឡើងជំទាស់តាំងពីដំបូង ដោយ--

[១០:៣១:៣៣]

**ប្រធានអង្គជំនុំ៖**

បានហើយៗ ប៉ុណ្ណឹងបានហើយ។ លោកមានឱកាសក្នុងការជំទាស់ លោកបែជាប្រើពាក្យស្តាយមិនជំទាស់ទៅវិញ ហើយយកឱកាសហ្នឹងមកធ្វើការកត់សម្គាល់ទៅវិញ។ លោកមានឱកាសច្រើននៅក្នុងការបង្ហាញនូវសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ចំពោះបញ្ហាផ្សេងៗដែលលោកយល់ឃើញថាមិនសមស្រប។

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ មេធាវីដែលទទួលសិទ្ធិ គឺលោកមេធាវី សំ សុគង់ និងលោកស្រីមេធាវី អ៊ីស្សាបែល ដៀរ៉ង់។

សូមលោកប្រធានអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ!

[១០:៣៣:០៦]

**លោក សំ សុគង់៖**

បាទ ជាបឋម ខ្ញុំមេធាវី សំ សុគង់ សូមគោរពលោកប្រធាន ក្រុមប្រឹក្សា សូមគោរពក្រុមប្រឹក្សា និងសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

**ស៖** ជម្រាបសួរលោក ផាន វ៉ាន! ទាក់ទងនឹងបញ្ហាសំណួរ គឺខ្ញុំមានសំណួរមិនជាច្រើនទេ ហើយដោយសារពេលវេលា ហើយខ្ញុំសូមសួរសំណួរលោកជាសំណួរខ្លីៗ ហើយនិងសូមឲ្យលោកឆ្លើយឲ្យបានខ្លីផងដែរ។

កាលពីម្សិលមិញលោកបានឆ្លើយចំពោះលោក -- សំណួរទាក់ -- លោកព្រះរាជអាជ្ញាទាក់ទងនឹងក្រុមគ្រួសាររបស់លោករត់ចូលទៅព្រៃ ទៅរស់នៅក្នុងព្រៃ។ តើខ្ញុំចង់សួរថា លោក ក្រុមគ្រួសារលោករត់ចូលទៅរស់នៅក្នុងព្រៃហ្នឹង តើលោកចូលទៅនៅក្នុងព្រៃហ្នឹងដោយសារតែមូលហេតុអីដែរលោក?

[១០:៣៤:០៩]

**លោក ផាន វ៉ាន៖**

**ផ៖** ការរត់ចូលព្រៃនេះ សូមបញ្ជាក់អ៊ីចេះ កាលជំនាន់ហ្នឹង វាមានចលនាតស៊ូ ដូចខ្ញុំនៅក្មេងខ្ញុំអត់ដឹងទេ ប៉ុន្តែខ្មោចឪពុកខ្ញុំហ្នឹង គាត់ជាអ្នកតស៊ូកាលជំនាន់ហ្នឹង។ ដល់អ៊ីចឹងគេតស៊ូ ថាដើម្បីរំដោះជាតិ រំដោះប្រជាជនអ៊ីចឹងនោះ មានចលនាតស៊ូហ្នឹងចូលព្រៃ។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** លោកថា វាជាចលនាតស៊ូ តើចលនាតស៊ូដែលក្រុមគ្រួសារលោករត់ចូលព្រៃហ្នឹង តើជាចលនាតស៊ូហ្នឹងមានឈ្មោះអីដែរ?

**ផ៖** រណសិរ្សរួបរួមជាតិបាទ។

**ស៖** លោកមានដឹងថារណសិរ្សរួបរួមជាតិហ្នឹង តើជាការដឹកនាំឬក៏គ្រប់គ្រងដោយអ្នកណាដែរ?

[១០:៣៥:១៨]

**ឆ៖** សម្តេច នរោត្តម សីហនុ កាលជំនាន់ហ្នឹងបាទ។

**ស៖** នៅពេលដែលលោករស់នៅក្នុងព្រៃ និងក្រុមគ្រួសាររបស់លោករស់នៅក្នុងព្រៃនោះ តើលោកលោករស់នៅក្នុងព្រៃមានរយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** យូរដែរ ចាំអត់បានតាំងពីខ្ញុំនៅតូចៗរហូតដល់ដឹងក្តីមក ៧០ ហ្នឹងមកចេញមកភូមិវិញបាទ។ ស្រុកហ្នឹងកើតតំបន់រំដោះទាំងអស់អ៊ីចឹង។

**ស៖** ខ្ញុំសួរសំណួរលោកទាក់ទងនឹងប-២០។ នៅប-២០ លោកថា លោកធ្លាប់ទៅនៅ -- ទៅរៀននៅប-២០ រៀនទាក់ទងនឹងការវាយអង្គុលីលេខ តើអ្នកដែលបានទៅរៀននៅប-២០ហ្នឹង គឺជាមនុស្សប្រភេទណាដែរ?

[១០:៣៦:៤៤]

**ឆ៖** អង្កាល់ហ្នឹងអត់ ខ្ញុំអត់ដឹងច្បាស់ថា ប្រភេទណាអីប្រភេទណាទេ តែគ្រាន់ខ្ញុំនៅក្មេងៗហ្នឹងគេឲ្យរៀនបកសារទូរលេខ ខ្ញុំចេះហើយក៏ខ្ញុំទៅស្រុកវិញ ទៅនៅជាមួយខ្មោចឪពុកខ្ញុំហ្នឹងក៏បកសារទូរលេខឲ្យគាត់ក្នុងរយៈពេលដែលខ្ញុំទៅហ្នឹង។ ក្រោយពីហ្នឹងមក ក៏បងខ្ញុំមកពីក្រោមក គាត់ក៏បកសារទូរលេខជំនួសខ្ញុំ។ ខ្ញុំនៅបើកឡាន ខ្ញុំចាំបានតែប៉ុណ្ណឹងបាទ។

**ស៖** ទាក់ទងនឹងមន្ទីរប-២០ នៅក្នុងមន្ទីរប-២០ លោកដឹងថា តើប-២០នេះ គឺជាមន្ទីរអ្វី? ហើយប-២០ ធ្វើការងារអ្វីដែរ?

**ឆ៖** កាលជំនាន់នុ៎ងវាយូរពេក ខ្ញុំវាចាំវាមិនអស់បាទ ខ្ញុំភ្លេច។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង ប៉ុន្តែគ្រាន់តែថាដឹងទម្រង់កាលពី៧០ ហ្នឹងរដ្ឋប្រហារហើយហ្នឹងក៏អ៊ំៗទាំងអស់នុ៎ងមកពីរតនគិរី។ ក្រោយពីហ្នឹងមកនោះ ខ្ញុំនោះ ឪពុកខ្ញុំមករៀនសូត្រនៅប-២០ ហ្នឹងគាត់ក៏យកខ្ញុំមក។ ខ្ញុំមកនៅប-២០ហ្នឹងរហូតមកនៅរៀនសារទូរលេខអី ហើយរត់សំបុត្រអី បម្រើចាស់ៗ អ៊ំៗអីជំនាន់ហ្នឹង ចាំបានតែប៉ុណ្ណឹង។ ដល់ហើយខ្ញុំចេះធំដឹងក្តីមែនទែន ខ្ញុំចេះបកសារទូរលេខទៅ។ ឪពុកខ្ញុំក៏យកខ្ញុំទៅស្រុកវិញ។ អត់មនុស្សប្រើនៅជាមួយគាត់អ៊ីចឹង ខ្ញុំចាំបានតែប៉ុណ្ណឹងបាទ។

[១០:៣៨:១២]

**ស៖** ការដែលលោក ឬក៏ឪពុកលោកនៅប-២០ តើគាត់រស់នៅប-២០ ប៉ុន្មានៗឆ្នាំដែរ នៅក្នុងប-២០ហ្នឹង?

**ធ៖** ឪពុកខ្ញុំអត់បាននៅប-២០ ទេ។ ខ្ញុំបញ្ជាក់វិញ នៅតែខ្ញុំទេបាទ។

**ស៖** នៅក្នុងប-២០ តើលោកមានបានឃើញថា ក្រៅពីប-២០ តើមានមន្ទីរផ្សេងៗទៀតនៅក្នុង ប-២០ ហ្នឹងទេ ឬក៏មានតែ ប-២០ មួយហ្នឹងទេ?

**ធ៖** នៅប-២០ ហ្នឹងវាមានសាខាវាច្រើនជំនាន់ហ្នឹង ជំនាន់សង្គ្រាមហ្នឹង។ អស់លោកក៏បានដឹង ហើយថា ទម្រង់បែបបទ គេរៀបចំរចនាសម្ព័ន្ធសង្គ្រាមហ្នឹង យើងនិយាយលម្អិតហ្នឹងទាល់តែនិយាយ រយៈពេលយូរដែរបានយល់គ្នាបាទ។ បើថាយើងនិយាយ -- សួរខ្លីៗ ខ្ញុំមិនដឹងឆ្លើយយ៉ាងម៉េចដែរ ដល់ អ៊ីចឹង ព្រោះវាទម្រង់នៅមន្ទីរហ្នឹងវាមានអ្នកដាំបន្លែ មានអីៗជំនាន់ហ្នឹងវាខុសពីឥឡូវ យើងប្រៀបធៀប វាលំបាកដែរ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង។ ប៉ុន្តែក្នុងប-២០ ហ្នឹងវាមានច្រើនបាទ។ វាធំ ដីៗក្រហម ក្រោយសង្គ្រាមមក ពូៗបញ្ញាជនក៏ធ្លាប់ទៅនៅហ្នឹងដែរ គាត់ដឹងដែរបាទ វាអ៊ីចេះ ចង់បញ្ជាក់ជូនប៉ុណ្ណឹង។ ព្រោះកាលជំនាន់សង្គ្រាមហ្នឹង រដ្ឋប្រហារហើយហ្នឹង អ្នកដឹកនាំទាំងអស់ហ្នឹងមកនៅហ្នឹង ចុះពីរតនគិរី មក។ ខ្ញុំដឹងតែប៉ុណ្ណឹងទេបាទ។

[១០:៣៩:៤៩]

**ស៖** នៅក្នុងប-២០ លោកថា មានមន្ទីរជាច្រើនស្ថិតនៅក្រោមប-២០។ តើនៅពេលដែលលោក ស្នាក់នៅ នៅប-២០ តើលោកមានបានសង្កេតឃើញថាមានកិច្ចប្រជុំ រវាងមេដឹកនាំធំៗនៅក្នុងប-២០ នោះដែរឬទេ?

**ធ៖** តាមខ្ញុំដឹងនិងចាំ គឺមាន ពីព្រោះវាអ៊ីចឹងឯង ព្រោះកន្លែងធំ វាទាល់តែប្រជុំរហូត។ ព្រោះ កន្លែងមន្ទីរប-២០ ជាកន្លែងសិក្ខាសាលា ចង់និយាយភាសាយើងឥឡូវ។ ជាកន្លែងអប់រំរៀនសូត្រមាន គ្រប់ ដូចស្ថាប័នរដ្ឋមួយ បើយើងប្រៀបធៀបយើងឥឡូវ នៅហ្នឹងកាលជំនាន់សង្គ្រាមបាទ។

**ស៖** នៅពេលដែលលោករស់នៅប-២០ លោកមានបានដឹងពីគោលនយោបាយរបស់អ៊ំៗ ក៏ដូច ជាអ្នកដឹកនាំនៅទីនោះដែរឬទេ នៅពេលដែលគាត់រស់នៅប-២០ នោះ?

**ធ៖** អត់ដឹងទេបាទ ព្រោះនៅក្មេង ជំនាន់នោះនៅក្មេងមែនទែន អត់ដឹងទេពីរឿងនយោបាយ អីនោះ ដឹងតែពីធ្វើបាទ។

**ស៖** លោកបានមានប្រសាសន៍ថា លោកជាសិស្សរៀននៅប-២០ ជាអ្នករៀនវាយអង្គុលីលេខ នៅពេលដែលលោកកំពុងតែរៀន តើមានគេផ្សព្វផ្សាយទាក់ទងនឹងអ្វី ឬបញ្ហាអ្វី ឬក៏ជាគោលនយោបាយ អ្វីទៅចំពោះសិស្សដែលរៀនអង្គុលីលេខនោះដែរឬទេ?

[១០:៤១:៤២]

**ឆ៖** ចាំមិនបានអស់ដែរអារឿងទ្រឹស្តីរៀនកាលជំនាន់ហ្នឹង រៀននូវមាគ៌ាស្អីៗច្រើនណាស់ តែវាចាំមិនបាន គ្រាន់តែដឹងថា បានរៀន រៀនរឿងការតស៊ូវណ្ណៈ ជំនះអីលើខ្លួនឯងស្អីៗអ៊ីចឹងទៅ វាច្រើនណាស់។ អាហ្នឹងបើយើងចង់ដឹងពីបញ្ហាហ្នឹងទាល់តែគិតសាឡើងវិញទៀតបាននឹកឃើញបាទ។ បើសួរប្រថុចញ៉ុច នឹកអត់ឃើញទេ ព្រោះវាកន្លង វាបន្លាយយូរពេក។ សូមបញ្ជាក់ជូនតុលាការប៉ុណ្ណឹងបាទ។

**ស៖** អ៊ីចឹងចម្លើយរបស់លោកមានន័យថាមាន មានការបង្រៀនទាក់ទងមាគ៌ាផ្សេងៗហ្នឹង ប៉ុន្តែលោកមិនចាំ មិនអ៊ីចឹងលោក?

**ឆ៖** បាទ។

**ស៖** សំណួរមួយទៀតពាក់ព័ន្ធនឹងលោកស្នាក់នៅ ប-២០ ហ្នឹង តើលោកមានធ្លាប់ឮគោលនយោបាយនៃការជម្លៀសប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញទៅពេលដែលជ័យជម្នះនោះដែរឬទេ?

**ឆ៖** អត់មានទេ បាទ អត់មានបានដឹងបានឮអីទេ។

[១០:៤៣:១៦]

**ស៖** ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងការងាររបស់លោក។ នៅពេលដែលលោករៀនចប់ លោកថាលោកធ្លាប់ធ្វើជាអ្នកវាយអង្គុលីលេខជូនឪពុកលោក ក៏ដូចជាលោកធ្លាប់ជានីរសាររបស់ឪពុកលោកដែរ។ ក្រោយមក គឺលោកបានប្រគល់តួនាទីនេះទៅឲ្យបងស្រី។ តើមូលហេតុអីបានលោកប្រគល់តួនាទីឲ្យបងស្រី ហើយលោកបែរជាមកធ្វើការជាអ្នកបើកបររថយន្តទៅវិញ?

**ឆ៖** កាលជំនាន់ហ្នឹង វាគ្មានអីប្រាកដប្រជាកំណត់ថាច្បាស់លាស់ ធ្វើអីជាអាជីព ជាមុខងារច្បាស់លាស់អត់មានទេបាទ ជំនាន់ហ្នឹងស្រេចតែគេថា វាអ៊ីចឹង។ ឧបមា ដូចខ្ញុំអ៊ីចឹងរៀនបកសារទូរលេខអ៊ីចឹង មិនមែនជារៀនជាសាលាអីធំដុំទេ គ្រាន់តែចេះម៉ាយល់ ម៉ាប្រើបាន។ អ៊ីចឹងហើយបានធ្វើការឲ្យធ្វើការបាន ចេះតែប្រើមួយរយៈអ៊ីចឹងទៅ ត្រូវធ្វើអី ធ្វើទៀត អត់មានកំណត់ថាឲ្យនៅធ្វើតែអាហ្នឹងរហូតអត់ទេ។ អាហ្នឹងខ្មោចឪពុកខ្ញុំ ឃើញខ្ញុំពូកែអារឿងខាងម៉ាស៊ីន គាត់ក៏ប្រើអារឿងបើកបរទៅជាមួយគាត់អ៊ីចឹង។ ដល់បងខ្ញុំមកគាត់ជាស្រី គាត់នៅធ្វើបកសារទូរលេខនៅហ្នឹងកន្លែងទៅ ហើយខ្ញុំបើកឡាន ទៅនេះទៅនោះ ជូនគេទៅនេះទៅនោះអ៊ីចឹងទៅ។ ជំនាន់នោះវាអ៊ីចឹងបាទ។

[១០:៤៤:៥០]

**ស៖** ឥឡូវខ្ញុំសូមសួរលោកទាក់ទងនឹងក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ នៅ -- លោកបាន

ប្រសាសន៍ពីម្សិលមិញឆ្លើយទៅនឹងសំណួរលោកព្រះរាជអាជ្ញា លោកថា "នៅក្រោយថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ គឺលោកបានមកទីក្រុងភ្នំពេញជាមួយឪពុករបស់លោក គឺក្នុងអំឡុងខែមិថុនា ឆ្នាំ៧៥ ហ្នឹង មានកិច្ចប្រជុំនៅស្តាតអូឡាំពិក អ៎! ខែឧសភា សូមទោស។ តើនេះជាៗចម្លើយរបស់លោកដែលបានឆ្លើយពីម្សិលមិញមែនដែរឬអត់លោក?

**ឆ៖** បាទៗ មកមែនបាទ កាលជំនាន់ហ្នឹង។

**ស៖** តើនៅពេលដែលលោកអញ្ជើញមកជាមួយឪពុកលោក ក៏ដូចជាអ្នកកម្មាភិបាលផ្សេងៗទៀតនោះ តើលោកធ្វើដំណើរដោយជិះអ្វីមកដែរពីតំបន់១០៥ហ្នឹង?

**ឆ៖** ជំនាន់ហ្នឹងជិះឡានមកដល់ក្រចេះ ហើយបានជិះកាណូតមកដល់ភ្នំពេញតែម្តងបាទ។

[១០:៤៦:១៨]

**ស៖** នៅពេលដែលលោកមកដល់ទីក្រុងភ្នំពេញ ហើយកិច្ចប្រជុំនោះ តើគេ -- កិច្ចប្រជុំនោះវាប្រព្រឹត្តទៅប៉ុន្មានថ្ងៃដែរនៅពេលដែលមានកិច្ចប្រជុំហ្នឹង?

**ឆ៖** ចាំអត់បានដែរ គេប្រជុំប៉ុន្មានថ្ងៃអង្កាល់ជំនាន់ហ្នឹង ខ្ញុំនៅក្មេងៗដឹងតែមកចង់សប្បាយនឹងគេតែប៉ុណ្ណឹងឯងបាទ ចង់ឃើញតែប៉ុណ្ណឹង។

**ស៖** បើសិនជាលោកអត់ចាំប្រជុំប៉ុន្មានថ្ងៃ តើលោកបានស្នាក់នៅទីក្រុងភ្នំពេញប៉ុន្មានថ្ងៃដែរនៅពេលនោះ?

**ឆ៖** យូរដែរបាទ ចង់ប្រហែលកន្លះខែ ព្រោះ ទៅវិញដឹកអីវ៉ាន់ទៅអ៊ីចឹងបាទ។

**ស៖** នៅពេលដែលលោកចូលរួម -- លោកឪពុកលោកមកចូលរួមនៅទីក្រុងភ្នំពេញ តើមានកម្មាភិបាលប៉ុន្មាននាក់ដែរ ដែលមកជាមួយនឹងឪពុករបស់លោកមកពីតំបន់១០៥ហ្នឹង?

**ឆ៖** មកច្រើន បាទ ជំនាន់ហ្នឹងមក មិនមែនមកម្នាក់ឯងមកច្រើនគ្នា។

**ស៖** នៅពេលដែលលោកត្រឡប់ទៅខេត្តមណ្ឌលគិរី គឺនៅតំបន់១០៥ វិញ នៅពេលដែលលោកក្នុងនាមជាលោកជានីរសារក៏ដូចជាអ្នកវាយអង្គុលីលេខជូនឪពុករបស់លោក តើឪពុករបស់លោកមានប្រាប់លោកទាក់ទងនឹងកិច្ចប្រជុំនៅទីក្រុងភ្នំពេញថាតើគេប្រជុំពីបញ្ហាអ្វីដែរឬទេ?

**ឆ៖** អត់ទេបាទ។

[១០:៤៨:២៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីផ្អាកមួយនាទី ឲ្យអ្នកបច្ចេកទេសប្តូរឌីវីឌី។

មើល៍ រដ្ឋបាលសម្របសម្រួលលើបញ្ហានេះ ហើយពេលរួចរាល់រាយការណ៍ប្រាប់យើងវិញ។

*(សម្រាករយៈពេលខ្លី)*

[១០:៤៩:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តលោកមេធាវី!

**សួរដោយលោក សំ សុគង់៖**

**ស៖** ខ្ញុំសូមសួរបញ្ជាក់លោកបន្តិចទាក់ទងនឹងកិច្ចប្រជុំកាលពីខែឧសភា តើការប្រជុំហ្នឹងគេធ្វើនៅស្តាតអូឡាំពិក ឬក៏ធ្វើនៅកន្លែងផ្សេងក្រៅពីស្តាតអូឡាំពិក បើតាមលោកចាំ?

**លោក ផាន វ៉ាន៖**

**ឆ៖** នៅស្តាតអូឡាំពិកបាទ។ ហើយមួយទៀត ខ្ញុំចង់ៗបញ្ជាក់ជូនលោក រឿងថាវាយអង្គុលីលេខ ខ្ញុំមិនមែនអ្នកវាយអង្គុលីលេខទេ ខ្ញុំបកសារ បកសារទូរលេខ។ ហ្នឹងបាទ ចង់បញ្ជាក់ប៉ុណ្ណឹង។

[១០:៥០:០៥]

**ស៖** លោកអាចឆ្លើយបានទេថា ហេតុអ្វីបានលោកប៉ានអះអាងថា កិច្ចប្រជុំនេះធ្វើឡើងនៅៗធ្វើនៅស្តាតអូឡាំពិក?

**ឆ៖** នៅកាលហ្នឹងមនុស្សគ្រប់ខេត្តក្រុងមកទាំងអស់ហ្នឹងបាទ។ មនុស្សច្រើន មនុស្សរាប់ម៉ឺននាក់នុ៎ងបាទ។

**ស៖** នៅពេលកិច្ចប្រជុំចាប់ផ្តើមធ្វើឡើងនោះ តើគេធ្វើនៅក្នុងស្តាត ក្នុងបរិវេណស្តាតអូឡាំពិក ឬខាងក្រៅស្តាតអូឡាំពិក?

**ឆ៖** នៅខាងៗក្រៅបាទ។

**ស៖** សំណួរពាក់ព័ន្ធនឹងការដែលប្រជុំចប់ នៅពេលដែលឪពុករបស់លោកដែលជាលេខាតំបន់ក៏ដូចជាកម្មាភិបាលផ្សេងៗទៀតត្រឡប់ទៅតំបន់វិញ តើលោកមានបានឃើញថា ឪពុករបស់លោករៀបចំកិច្ចប្រជុំថ្នាក់តំបន់ដែរឬទេ?

[១០:៥១:២៥]

**ឆ៖** ខ្ញុំមិនបានដឹងដែរ រឿងហ្នឹងបាទ វាចាំអត់បាន។ ព្រោះជាធម្មតា តែមានស្អីទៅដល់វិញ ការប្រជុំជារឿងធម្មតាទៅហើយជំនាន់ហ្នឹងបាទ។

**សៈ** នៅពេលដែលឪពុករបស់លោក ក៏ដូចជាកម្មាភិបាលផ្សេងៗទៀតត្រឡប់ពីប្រជុំនៅស្តាតអូឡាំពិក តើការងារមួយចំនួននៅក្នុងតំបន់របស់លោកមានការផ្លាស់ប្តូរផែនការអនុវត្តការងារដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនបានដែររឿងហ្នឹងបាទ។ តែជំនាន់ហ្នឹងការងារមានស្អីក្រៅពីបង្កបង្កើនផល ភាគច្រើនរឿងធ្វើស្រែធ្វើចម្ការហ្នឹងឯងបាទ។

**សៈ** នៅពេលដែលៗលោកនិយាយទាក់ទងរឿងសហករណ៍ៗនៅៗតំបន់១០៥។ តើសហករណ៍ហ្នឹងលោកអាចចាំបានទេថា វាកើតឡើងនៅពេលណាដែរ?

**ឆ៖** នៅ១០៥ ហ្នឹងខ្ញុំចាំអត់បានទេ មិនកើតឆ្នាំណា គិតទៅមុនរំដោះភ្នំពេញទៀត សហករណ៍មានហូបបាយរួមហើយនៅនុ៎ងបាទ។

[១០:៥៣:៥៥]

**សៈ** នៅពេលដែលមានសហករណ៍ហ្នឹង តើសហករណ៍ហ្នឹងក្រៅពីការងារហូបបាយរួម តើសហករណ៍ហ្នឹងគាត់មានៗការងារអីផ្សេងទៀតក្រៅពីហូបបាយរួមទេ?

**ឆ៖** អត់យល់សំណួរបាទ។

**សៈ** ទាក់ទងនឹងសហករណ៍ លោកថាសហករណ៍មានន័យថា ហូបបាយរួម។ តើសហករណ៍ហ្នឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុករបស់លោក ឬមួយក៏សហករណ៍ហ្នឹងមានជាៗផ្នែកមួយដោយឡែកពីតំបន់១០៥?

**ឆ៖** នៅ១០៥ហ្នឹង សហករណ៍វា -- នៅមន្ទីរ១០៥ ខ្លួនឯងហ្នឹងក៏មានសហករណ៍ដែរ បាទ។ ចង់បញ្ជាក់អ៊ីចឹង។ នៅក្នុងមន្ទីរហ្នឹងដូចថា មានគ្នា៦០នាក់អ៊ីចឹង មានចង្ក្រានបាយមួយ ឧទាហរណ៍អ៊ីចឹងបាទ ហើយនិងតាមភូមិនោះគេផ្សេងទៀត សហករណ៍ភូមិគេហ្នឹង ហើយពួកមន្ទីរហ្នឹងក៏មានសហករណ៍គេ។ ចង់បញ្ជាក់បណ្ដឹង។ សហករណ៍ហ្នឹង ក្រៅពីហូបបាយរួមហ្នឹង នៅមានការងារដូចជាចម្ការរបស់សហករណ៍អ៊ីចឹង របស់រួមអ៊ីចឹងទៅ ទៅធ្វើទាំងអស់គ្នាអ៊ីចឹងទៅ ដាំស្អី ស្រែអ៊ីចឹងរបស់រួមទាំងអស់គ្នា។ ចង់បញ្ជាក់បណ្ដឹងបាទ។ គោក្របីអីៗហ្នឹងរបស់សហករណ៍ហ្នឹង វានៅរួមទាំងអស់គ្នាមានអ្នកមើលដោយឡែកៗអ៊ីចឹងទៅបាទ។ ចង់បញ្ជាក់បណ្ដឹង។

[១០:៥៥:៥២]

**ស៖** លោកមានបានសង្កេតឃើញថា នៅពេលដែលឪពុករបស់លោក ក៏ដូចជាកម្មាភិបាល ត្រឡប់ចេញ ត្រឡប់ពីការប្រជុំនៅភ្នំពេញវិញ តើមានការសកម្មភាពណាមួយ ឬការប្រព្រឹត្តិណាមួយ ទៅលើជនជាតិវៀតណាម ក៏ដូចជាការបង្ខំឲ្យមានការរៀបអាពាហ៍ពិពាហ៍ណាមួយនៅក្នុងតំបន់របស់លោកទេ?

**ឆ៖** សូមបញ្ជាក់ម្តងទៀតមកបាទ។

**ស៖** នៅពេលដែលឪពុករបស់លោក ក៏ដូចជាកម្មាភិបាលផ្សេងៗទៀត ត្រឡប់ពីមកប្រជុំនៅទីក្រុងភ្នំពេញ តើវាមានការប្រព្រឹត្តអ្វីមួយទៅលើជនជាតិវៀតណាម ក៏ដូចជាការបង្ខំឲ្យមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់របស់លោកដែរឬទេ?

[១០:៥៧:០៩]

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ! ក្រៅវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការហើយ។ អាពាហ៍ពិពាហ៍ដោយបង្ខំមិនបានជាអំពើទាំងឡាយដែលកំណត់ធ្វើសវនាការនាទីនេះទេ គឺបានរៀបរាប់ច្បាស់លាស់ណាស់ នៅឯកសារ E124/7.1។ អំពើអមនុស្សធម៌ផ្សេងៗទៀត មិនរាប់បញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ កម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និង ទី២។

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបង្វែរសំណួរផ្សេង។

**សួរដោយលោក សំ សុគង់៖**

**ស៖** ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ លោកបានឆ្លើយពីម្សិលមិញផងដែរថា នៅក្នុងតំបន់១០៥ ដែលនៅក្នុងតំបន់ គឺមានមន្ទីរសន្តិសុខដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកលោក ហើយក្រោយមកហ្នឹងក៏មានកងពលលេខ៩២០ ក៏ដាក់តាំងនៅក្នុងតំបន់១០៥ ផងដែរ។ តើការងាររវាងមន្ទីរសន្តិសុខរបស់ឪពុកលោក និងតំបន់៩២០ ហ្នឹង តើវាមានការងារទំនាក់ទំនងគ្នាយ៉ាងដូចម្តេចដែរ?

[១០:៥៨:៤២]

**ឆ៖** ការទំនាក់ទំនងគ្នាហ្នឹងវាមានបាទ។ ប៉ុន្តែការទំនាក់ទំនងយ៉ាងម៉េច អីយ៉ាងម៉េចហ្នឹងក៏ក្លាប់មិនបានទេបាទ។ ខ្ញុំក្លាប់អត់បាន ពីព្រោះវាយូរពេកចាំវាអត់បាន។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែលលោកធ្វើការជានីរសារ ជូនឪពុករបស់លោកនៅតំបន់១០៥ តើលោកធ្លាប់

នាំសារទៅៗតាមមន្ទីរស្រុកផ្សេងៗដែរឬទេ?

**ឆ៖** ធ្លាប់បាទ ធ្លាប់។

**ស៖** លោកមានបានដឹងថា នៅក្នុងសារនោះគឺមានន័យ -- បានន័យថា អត្ថន័យក្នុងសារនោះ តើសារនោះមានន័យដូចម្ដេចដែរ ចំពោះសារដែលផ្ញើទៅតាមស្រុកនីមួយៗនោះ?

**ឆ៖** អត់ដឹងទេបាទ។

**ស៖** សារដែលលោកនាំទៅតាមស្រុកនីមួយៗតើលោកទទួលពីខាងណាដែរ? ពីនរណាដែរ?

**ឆ៖** ជួនកាលពីខ្មោចឪពុកខ្ញុំផ្ទាល់ ជួនកាលអ្នកធ្វើការជាមួយហ្នឹងពីប្រធានមន្ទីរអ៊ីចឹងទៅបាទ។

**ស៖** ទាក់នឹងការបកប្រែអង្គុលីលេខ តើនៅក្នុងតួនាទីលោកជាអ្នកបកប្រែអង្គុលីលេខហ្នឹង តើលោកបានទទួលនូវការបកប្រែហ្នឹង ទទួលពី -- ទាក់ទងហ្នឹងឯកសារដែលលោកត្រូវបកប្រែតើលោកទទួលពីខាងណាមកដែរ?

[១១:០១:១៣]

**ឆ៖** ទទួលពីអ្នកវាយអង្គុលីលេខបាទ អ្នកវិទ្យុទាក់ទងវាយអង្គុលីលេខបាទ។

**ស៖** បាទលោកប្រធានខ្ញុំដូចជា ខ្ញុំអស់សំណួរហើយសួរចំពោះសាក្សី ហើយខ្ញុំមានសហភាគខ្ញុំជាអន្តរជាតិគាត់អាចនៅមានសំណួរបន្ត។ សូមការអនុញ្ញាត ហើយសូមអរគុណលោកសាក្សីដែល បានឆ្លើយសំណួររបស់ខ្ញុំ។ សូមអរគុណ។

**លោកស្រី អ៊ីសាបែល ឌៀរ៉ង់៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរអស់លោក លោកស្រី ភាគីទាំងអស់។ ជម្រាបសួរសាក្សី ខ្ញុំឈ្មោះ អ៊ីសាបែល ឌៀរ៉ង់។ ខ្ញុំជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរបន្ថែមដើម្បីចោទសួរលោក។

**សួរដោយលោកស្រី អ៊ីសាបែល ឌៀរ៉ង់៖**

**ស៖** កាលពីអម្បាញ់មិញនេះ លោកបានឆ្លើយថា លោកបានអមដំណើរឪពុកលោកកាលពីខែឧសភា ឆ្នាំ១៩៧៥ មកភ្នំពេញដើម្បីចូលរួមមហាមីទ្ទិងមួយនៅស្ដាតអូឡាំពិក។ តើលោកអាចពិពណ៌នាក្រុងភ្នំពេញនៅខែឧសភា ឆ្នាំ១៩៧៥បានទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** ពណ៌នា អត់យល់ន័យបាទ។

[១១:០៣:០៤]

**ស៖** នៅពេលដែលលោកមកភ្នំពេញនៅខែឧសភា ឆ្នាំ១៩៧៥ តើស្ថានភាពទីក្រុងមានយ៉ាងម៉េចដែរ? មានមនុស្សដើរហើរទៅមក មានឡានម៉ូតូ កង់ បើកបរ ឬក៏ជាទីក្រុងស្ងាត់ជ្រងំ ដូចវាលរហោស្ថាននោះ?

**ផ៖** កាលខ្ញុំមកនោះអត់មានមនុស្សទេបាទ ស្ងាត់ជ្រងំ យប់អត់ហ៊ានដើរទេព្រោះខ្លាច ព្រោះមនុស្សចេញអស់ អត់មានអ្នកណានៅម្នាក់ទេ ឡាន ម៉ូតូអីក៏អត់មានដែរ។ នៅមានតែទាហានយាមតាមកន្លែងមួយៗតែប៉ុណ្ណឹងបាទ។

**ស៖** តើទីក្រុងភ្នំពេញមានសភាពយ៉ាងម៉េចដែរ នៅពេលដែលលោកធ្វើការជាអ្នកបើកបរឲ្យ អៀង ធីរិទ្ធ នោះនៅដើមឆ្នាំ៧៨ នោះ?

**ផ៖** កាលជំនាន់នោះក៏អត់មានឡានអីឯណាច្រើនទេ មានតែកម្មករ ភាគច្រើនបុគ្គលិកធ្វើការហ្នឹង មានតែកម្មករ និងអ្នកធ្វើការតាមក្រសួងមន្ទីរ ហើយទាហានតែប៉ុណ្ណឹងទេបាទ។

[១១:០៤:៥០]

**ស៖** ក្នុងឋានៈលោកជាអ្នកបើកបរឲ្យ អៀង ធីរិទ្ធ តើលោកធ្វើការយ៉ាងម៉េចដែរ លោកគេងនៅឯណា? ទទួលទានអាហារនៅឯណា? ហើយលោកធ្វើដំណើរជូនលោកស្រី អៀង ធីរិទ្ធ ទៅណាមកណាហ្នឹងញឹកញាប់កម្រិតណាដែរ?

**ផ៖** គេង មានផ្ទះគាត់ឲ្យគេងនៅៗក្រៅ។ ហើយឯបាយទឹកអី គេមានសហករណ៍គេ។ សហករណ៍របស់ៗមន្ទីរហ្នឹងបាទ។ ឯជូនគាត់ទៅណាមកណាស្រេចតែគាត់ឲ្យជូន ទៅកន្លែងពេទ្យ ជូនទៅកន្លែងរោងចក្រធ្វើថ្នាំពេទ្យអីចឹងទៅបាទ។

**ស៖** តើលោកមានលទ្ធភាពអាចជជែកពិភាក្សាជាមួយនឹងបុគ្គលិកផ្សេងទៀតនៅក្រសួងសង្គមកិច្ចបានដែរឬទេ?

**ផ៖** ជំនាន់ហ្នឹងអត់មានទេបាទ អត់មានជជែកស្អីជាមួយបុគ្គលិកក្រសួងអីទេបាទ ព្រោះតួនាទីខ្ញុំអត់មាន តែបើកឡានតែប៉ុណ្ណឹងបាទ។

**ស៖** ចុះហេតុអ្វីបានជាលោកមិនអាចពិភាក្សាជាមួយអ្នកផ្សេងទៀតបាននោះ?

[១១:០៦:៤១]

**ផ៖** ខ្ញុំអត់យល់ន័យ ចង់ៗដឹងពិភាក្សាពីរឿងអីបាទ ព្រោះអីពិភាក្សារឿងនិយាយលេង និយាយ

សើចអីធម្មតាហ្នឹងបានបាទ។ បើថានិយាយពីរឿងការងារ ឬក៏តួនាទីស្អី ខ្ញុំអត់មានតួនាទីអីទេជំនាន់ហ្នឹង សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ចុះបើលោកថាជជែកលេងហ្នឹង ជជែកលេងគ្នាអំពីអ្វីដែរ?

**ឆ៖** និយាយៗធម្មតា សួរសុខទុក្ខគ្នា អ្នកនេះធ្លាប់នៅឯណា នៅអីចឹងៗបាទ។

**ស៖** តើលោកមានលទ្ធភាពក្នុងការផ្លាស់ប្តូរយោបល់គ្នា ពីការចាប់អារម្មណ៍គ្នាទៅវិញទៅមក ពាក់ព័ន្ធទៅនឹងស្ថានភាពនៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** ជំនាន់ហ្នឹងអត់មាននរណាហ៊ាននិយាយទេបាទ ព្រោះខ្លាចរៀងៗខ្លួន។ ខ្លាចគេថាខ្មាំងបាទ។ ជំនាន់ហ្នឹងដូចលោកបានដឹងហើយ អត់មាននរណាហ៊ាននិយាយពីរឿងនយោបាយទេ។

**ស៖** លោកបានឆ្លើយថា លោកបានជូនលោកស្រី អៀង ធីរិទ្ធ ទៅកន្លែងផ្សេងៗ ជាពិសេសទៅសាលាពេទ្យ។ តើលោកអាចប្រាប់បានទេថាមានអ្នកណាខ្លះនៅសាលាពេទ្យនោះ? មាននិស្សិត ឬក៏មានមនុស្សច្រើនទេ?

[១១:០៨:៥៤]

**ឆ៖** ជូនគាត់ទៅកន្លែងសាលាពេទ្យហ្នឹង ជូនកាលគាត់បង្រៀនសូត្រពួកមកពី អ្នកចូលថ្មី បុគ្គលិកមកថ្មីអីចឹងទៅបាទ។

**ស៖** មានតែបុគ្គលិកក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច នៅសាលាពេទ្យហ្នឹង ឬក៏អ្នកផ្សេងទៀតដែរ?

**ឆ៖** មានតែបុគ្គលិកពេទ្យនៅក្រសួងសង្គមកិច្ចហ្នឹងទេបាទ។

**ស៖** តើលោកអាចប្រាប់បានទេថា ប្រព័ន្ធទំនាក់ទំនងនៅក្នុង និងនៅក្រៅក្រសួងសង្គមកិច្ចនោះប្រព្រឹត្តិទៅយ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំអត់បានដឹងទេបាទ ប្រព័ន្ធយ៉ាងម៉េច អីយ៉ាងម៉េច ព្រោះខ្ញុំវានៅតែបើកឡាន អត់យល់ពីប្រព័ន្ធគេទេបាទ។

**ស៖** តើលោកដឹងថា មានផ្នែកទូរលេខនៅក្រសួងសង្គមកិច្ចដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ដែលមានលេខ E3/447 លោកបានលើកអំពីកិច្ចប្រជុំពីរប្រភេទដែលប្រព្រឹត្តទៅនៅក្នុងក្រសួងសង្គមកិច្ច។ គឺមានកិច្ចប្រជុំត្រីមាស ហើយនិងកិច្ច

ប្រជុំតាមដាន។ តើលោកអាចបញ្ជាក់បានទេថា កិច្ចប្រជុំទាំងពីរជាកិច្ចប្រជុំពីរផ្សេងដាក់ដោយឡែកពីគ្នា។

[១១:១១:៣៥]

**ផ៖** បាទ ប្រជុំពីរហ្នឹង វាដាច់ដោយឡែកពីគ្នាបាទ។ មួយប្រជុំធម្មតា អាមួយប្រជុំទិតៀនស្វ័យទិតៀន ហើយជារឿងធម្មតាកាលជំនាន់ហ្នឹងហើយបាទ។

**ស៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បើកៗក្បាលមីក្រូហ្វូន!

**សួរដោយលោកស្រី អ៊ីស្សាបែល ដៀវ៉ង់៖**

**ស៖** សូមអភ័យទោស។ នៅពេលប្រជុំ ដែលលោកហៅថាជាប្រជុំធម្មតានោះ តើមានហេតុការណ៍អ្វីកើតឡើងខ្លះដែរ?

**ផ៖** អត់មានអីទេ មានតែការទិតៀនគ្នាហ្នឹងឯងបាទ។

**ស៖** ចុះនៅក្នុងកិច្ចប្រជុំស្វ័យទិតៀនវិញ តើគេធ្វើអ្វីខ្លះ?

**ផ៖** ស្វ័យទិតៀនដូចអ្នកដែលគេទិតៀនហ្នឹង ត្រូវដាក់ខ្លួនឲ្យគេកសាងអ៊ីចឹង ឧទាហរណ៍អ៊ីចឹងបាទ។

[១១:១៣:១១]

**ស៖** ហើយក្រោយពីប្រជុំស្វ័យទិតៀនហើយ តើមានការសម្រេចអ្វីទេ?

**ផ៖** ក្រោយពីហ្នឹង គេឲ្យសាមីខ្លួនហ្នឹង សាមីខ្លួនទៅប្ដេជ្ញាចិត្តឈប់ធ្វើអ៊ីចឹងទៀត ឧបមាធ្វើអីខុស ឬក៏និយាយអីខុសអ៊ីចឹង។ មានតែប៉ុណ្ណឹង។

**ស៖** អ៊ីចឹងមានតែការសម្រេចបែបហ្នឹងមួយទេ មែនទេ?

**ផ៖** បាទ។

**ស៖** បុគ្គលដែលត្រូវបានបញ្ជូនទៅក-៧ តើពេលបញ្ជូនទៅនោះ មានកិច្ចប្រជុំយ៉ាងម៉េចទៀតក្រៅពីបញ្ជូនមនុស្សចេញទៅហើយនោះ?

**ផ៖** អត់មានប្រជុំអីទេបាទ។

[១១:១៤:៤៥]

**ស៖** ក្នុងនាមលោកជាអ្នកបើកបរនោះ លោកជូន អៀង ធីរិទ្ធ ទៅតាមមន្ទីរពេទ្យផងដែរ។ តើលោកអាចបញ្ជាក់បានទេថា នៅតាមមន្ទីរពេទ្យនោះ គេព្យាបាលមនុស្សប្រភេទណា? ជាទាហាន ឬក៏ជាជនស៊ីវិល? ហើយនៅក្នុងពេទ្យនីមួយៗនោះមានអ្នកជំងឺច្រើនទេ?

**ឆ៖** កាលជំនាន់ហ្នឹងរឿងព្យាបាលហ្នឹងទាំងស៊ីវិល ទាំងទាហាន តែទាហានច្រើន។ ហើយអ្នករបួសមកពីតាមព្រំដែនមកនោះច្រើនពេញមន្ទីរពេទ្យទាំងអស់កាលជំនាន់ហ្នឹងបាទ។ មុននឹង៧៩ ហ្នឹងបាទ។

**ស៖** ចំពោះបុគ្គលិកពេទ្យ និងបច្ចេកទេសដែលនៅតាមមន្ទីរពេទ្យ តើលោកអាចប្រាប់បានទេលោកឃើញមានមនុស្សច្រើនគ្រប់គ្រាន់ទេ ហើយអ្នកទាំងអស់នោះដែលជាបុគ្គលិកបច្ចេកទេស និងបុគ្គលិកពេទ្យហ្នឹងមានសញ្ជាតិអ្វីខ្លះ?

[១១:១៦:១៤]

**ឆ៖** បុគ្គលិកពេទ្យជំនាន់ហ្នឹងមានតែខ្មែរទេ អ្នកបច្ចេកទេសមានតែចិន។ ក្រៅពីហ្នឹងអត់មានទេបាទ។

**ស៖** លោកបានរៀបរាប់អំពីរឿងរ៉ាវមួយដែលនៅក្នុងពេលនោះ គឺគេបន្ទោស អៀង ធីរិទ្ធ អំពីការបាត់បង់អ្នកបច្ចេកទេសនៅតាមមន្ទីរពេទ្យ។ តើលោកអាចរៀបរាប់ពីរឿងរ៉ាវដែលគេបន្ទោស អៀង ធីរិទ្ធ នេះម្តងទៀតបានទេ?

**ឆ៖** រៀបរាប់យ៉ាងម៉េចបាទ សូមបញ្ជាក់ម្តងទៀត។

**ស៖** គឺនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត លោកបានឃើញរឿងរ៉ាវមួយ ហេតុការណ៍មួយ ហើយនៅក្នុងពេលនោះ គឺថាគេបន្ទោស អៀង ធីរិទ្ធ អំពីការបាត់ខ្លួនអ្នកបច្ចេកទេស។ លោកចាំទេថាលោកបានរៀបរាប់អំពីរឿងហ្នឹងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ?

[១១:១៧:៥០]

**ឆ៖** បាន បាទ។ ក្នុង អង្កាល់នុំងគាត់ហ្នឹងជួបជាមួយមិត្តចិន ដល់បុគ្គលិកវាអត់មានអ្នកធ្វើការពេទ្យនោះអត់មានអី ចិនគេបន្ទោស គេថាមនុស្សទៅណាអស់។ គាត់គ្រវី គាត់ដើរចេញមកជាមួយអនុប្រធានគាត់ ឬក៏គ្នាគាត់ប៉ុន្មាននាក់ បីបួននាក់ជជែកគ្នា ខ្ញុំក៏ឮ។ ចង់បញ្ជាក់ប៉ុណ្ណឹង។ ឮគាត់ជជែកគ្នា។ ប៉ុន្តែមេគាត់យ៉ាងម៉េច អីយ៉ាងម៉េចខ្ញុំអត់យល់ទេ។ គ្រាន់តែឮគាត់រអ៊ូរទាំថា វាអត់មានមនុស្សថាមូលហេតុអី អីចឹងបាទ។ ចង់បញ្ជាក់ប៉ុណ្ណឹង។

**ស៖** តើ អៀង ធីរិទ្ធ ធ្វើការសម្រេចបែបណាចំពោះការជំនួសបុគ្គលិកពេទ្យដែលបាត់ខ្លួនទៅនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក អៀង សារី!

**លោក អាង ឧត្ដម៖**

សូមគោរពសវនាការ សូមគោរពតុលាការ សូមគោរពអង្គសវនាការ។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ ពីព្រោះសំណួរនេះមិនពាក់ព័ន្ធទេ។ លោកស្រី អៀង ធីរិទ្ធ ត្រូវបានដកចេញពីសំណុំរឿង ០០១ អ៎! សូមទោស ០០២/០១ ហើយ ហើយវាគ្រាន់តែចំណាយពេលឥតប្រយោជន៍តែប៉ុណ្ណោះ។ សូមអរគុណ។

[១១:១៩:៣៩]

**លោកស្រី អ៊ីស្សាបែល ឌៀរ៉ង់៖**

លោកប្រធាន សំណួររបស់ខ្ញុំនោះមិនផ្ដោតទៅលើ អៀង ធីរិទ្ធ នោះទេ គឺខ្ញុំផ្ដោតទៅលើការរៀបចំរចនាសម្ព័ន្ធនៅតាមមន្ទីរពេទ្យ។ គាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដូច្នេះ គាត់មានភារៈទទួលបន្ទុកលើមន្ទីរពេទ្យទាំងអស់នោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២២:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីលោក អៀង សារី ទៅលើការតាំងសំណួរចុងក្រោយនេះ មានមូលហេតុសមស្រប សេចក្ដីជំទាស់មានប្រសិទ្ធភាព។

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយ ដែលសួរឡើងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិទេ។

**សួរដោយលោកស្រី អ៊ីស្សាបែល ឌៀរ៉ង់៖**

**ស៖** លោកសាក្សី ខ្ញុំសូមត្រឡប់មកក្រោយបន្តិចវិញ។ លោកឆ្លើយថា លោកបានរៀនសរសេររៀនអាននៅរតនគិរី ហើយលោកក៏បានបញ្ជាក់ថា នៅប-២០ កូនៗរបស់កម្មាភិបាលចាប់ពីប្រធានតំបន់ទៅត្រូវបានគេបញ្ជូនទៅកន្លែងនុំង។ លោកបានរៀនសូត្រនៅទីនោះ តើលោកអាចប្រាប់បានទេថា កូនៗ ឬក៏ក្មេងៗផ្សេងទៀតនោះ ក៏ទទួលបានការអប់រំដូចលោកដែរ?

**លោក ផាន វ៉ាន់៖**

**ផ៖** បាទ បានទៅរៀនគ្នាច្រើនជំនាន់ហ្នឹងបាទ។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** អ៊ីចឹងមិនមែនតែកូនកម្មាភិបាលទេ កូនក្មេងទូទៅក៏ទទួលបានការអប់រំអ៊ីចឹងដែរ មែនទេ?

**ផ៖** អត់ទេ កន្លែងហ្នឹងកន្លែងកូនកម្មាភិបាលជំនាន់ហ្នឹង។

[១១:២៤:៥១]

**ស៖** អ៊ីចឹង អ្នក -- ក្មេងៗ ឬក៏កូនរបស់អ្នក ដែលមិនមែនជាកូនរបស់កម្មាភិបាលនោះ គាត់រៀនសូត្រ ឬក៏អប់រំនៅឯណាវិញទៅអ៊ីចឹង?

**ផ៖** ជំនាន់ហ្នឹងអត់មានសាលាទេបាទ គ្រាន់តែកន្លែងរៀននៅក្នុងព្រៃ កន្លែងមន្ទីរធម្មតាហ្នឹង មិនមែនជាសាលា បើកឲ្យរៀនជាទូទៅទេ។ សូមបញ្ជាក់ប៉ុណ្ណឹង។ ហើយអ្នកទូទៅអត់មានបានរៀនទេ ជំនាន់ហ្នឹងបាទ ហើយកូនកម្មាភិបាលរៀនបាន រៀនបច្ចេកទេស។ អ្នកមករៀនបច្ចេកទេសដូចខ្ញុំបាន បញ្ជាក់ខាងលើអ៊ីចឹងបាទ។ មានតែប៉ុណ្ណឹងទេបាទ។

**ស៖** លោកបានឆ្លើយថា មានសហករណ៍ ក៏ប៉ុន្តែលោកមិនបាននិយាយពីជំរំការងារទេ។ តើនៅ ក-១៧ នោះមានជំរំការងារទេ?

[១១:២៦:១៦]

**ផ៖** អត់យល់ជំរំការងារម៉េចបាទ។ សូមៗបញ្ជាក់ម្តងទៀតបាទ ន័យ។

**ស៖** ចំពោះលោកនោះ តើសហករណ៍ហ្នឹងជាកន្លែងប្រមូលផ្តុំប្រជាជនសម្រាប់ធ្វើការ។ នៅពេលដែលលោកប្រើពាក្យ "សហករណ៍" តើចំពោះលោកហ្នឹងជាកន្លែងប្រមូលផ្តុំទៅធ្វើការអ៊ីចឹងមែនទេ?

**ផ៖** សហករណ៍កន្លែងៗបាយ រោងបាយរួមហ្នឹងគេហៅ "សហករណ៍" បាទ ជំនាន់ហ្នឹង។ ហើយការធ្វើការងារហ្នឹងក៏ធ្វើរួមដែរ វាអ៊ីចឹង ព្រោះវាអត់មានស្រែឯកជន អត់មានចម្ការឯកជនអីទេ។ កន្លែងស្រែហ្នឹង សហករណ៍សមាជិក ឧទាហរណ៍អ៊ីចឹង។ ឧបមានៅក្នុងមួយភូមិហ្នឹងមានកន្លែងរោងបាយមួយ ឧបមាអ៊ីចឹង។ ឯក្នុងមួយភូមិនោះ ក៏ស្រែៗក្នុងភូមិហ្នឹងទាំងអស់គ្នា អត់មានរបស់អ្នកណាទេ នេះចង់បញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** ចុះក្មេងៗនៅតាមសហករណ៍ទទួលបានការរៀនសូត្រទេ?

**ផ៖** ជំនាន់ហ្នឹងមិនទាន់មានការរៀនសូត្រទេ បាទ នៅ១០៥ អត់មានៗសោះ។

[១១:២៨:១០]

**ស៖** សូមអរគុណលោកសាក្សី។

**លោកស្រី អ៊ីស្សាបែល អៀរ៉ង់៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកចៅក្រមមានសំណួរត្រូវសួរទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

**ស៖** លោកសាក្សី ខ្ញុំជាចៅក្រម ឡាវ៉ែន៍ ហើយគេចោទសំណួរទៅលោកច្រើនមកហើយ ហើយតាំងពីម្សិលមិញមក។ ខ្ញុំមានសំណួរមួយចំនួនសួរបន្ត។ ជាបឋមគឺទាក់ទងនឹងកាលបរិច្ឆេទនៃមរណភាពរបស់ឪពុកលោក តើលោកអាចផ្តល់ព័ត៌មានច្បាស់លាស់មួយចំនួនបានដែរឬទេទាក់ទងទៅនឹងកាលបរិច្ឆេទនេះ?

[១១:២៩:១២]

**លោក ផាន វ៉ាន៖**

**ឆ៖** ការស្លាប់របស់ឪពុកខ្ញុំ ខ្ញុំចាំរៀបរាប់ ចាំមិនបានអស់ពីសេចក្តីការចាប់ផ្តើមនៃការស្លាប់ទេ គ្រាន់តែថា ដឹងកាលហ្នឹង ហៅមកធ្វើការ។ មកធ្វើការនៅភ្នំពេញហ្នឹង ដោយមានពីមណ្ឌលមកជិះកន្ទុំរុយមក។ មកគ្នាបួននាក់ មានខ្ញុំ មានអង្គរក្សគាត់ម្នាក់ទៀត ហើយមានអ៊ំខ្ញុំ និងខ្មោចឪពុកខ្ញុំ។ មកដល់ពោធិ៍ចិនតុងហើយក៏ឡានខាង ក-១៧ហ្នឹង គេមកយក។ មកយកមក មកដល់មាត់ទន្លេកន្លែងមន្ទីរពាណិជ្ជកម្ម១០៥ ហ្នឹង ពួកខ្ញុំក៏ចុះនៅហ្នឹង។ ឯគាត់ទាំងពីរនាក់ក៏មកក-១៧ អ៊ីចឹងទៅក៏ខាងក-១៧ គេឲ្យពួកខ្ញុំហ្នឹងនៅដើរទស្សនកិច្ចអ្នកមកពីខាងខេត្តហ្នឹង។ ចង់ដើរលេងទៅណា ចាំគេមកយកនាំជូនដើរលេង។ គ្រាន់តែបញ្ជាក់តែប៉ុណ្ណឹង។ ដល់ក្រោយពីគាត់ទៅធ្វើការបាត់ទៅ ល្ងាចៗឡើង ពួកខ្ញុំមកពីដើរលេងហ្នឹង គេនាំដើរលេងមកមុខវាំង មកអ៊ីចឹងមក។ ល្ងាចឡើងហ្នឹង ក៏ឃើញគាត់ស្លាប់នៅលើផ្ទះហ្នឹងបាត់ទៅហើយ។ ដល់ស្លាប់ទៅ ខ្ញុំក៏រាយការណ៍មកក-១៧ ហ្នឹងថា "ឪពុកខ្ញុំស្លាប់"។ ដល់អ៊ីចឹង

ក-១៧ គេចាត់ចែងមនុស្សមកដឹកពព្រូសប៉ប្រះយកសពហ្នឹងទៅភ្នំពេញហ្នឹង ដោយគ្មានការស៊ើបអង្កេត ឬក៏សួរនាំអីច្រើនទេ។ គ្រាន់តែថាខ្មាំងសម្លាប់ប៉ុណ្ណឹង។ ក្នុងការស្លាប់នៅហ្នឹង ខ្ញុំឃើញនឹងភ្នែកហ្នឹង វាមានកាំភ្លើងខ្លីនៅដៃអ៊ំខ្ញុំហ្នឹងមួយដើម ហើយនិងដែកបីជ្រុងហ្នឹងមួយនៅហ្នឹង។ ហើយខ្មោចឪពុកខ្ញុំ គាត់ស្លាប់នៅលើគ្រែ ហើយអ៊ំហ្នឹង គាត់ស្លាប់នៅមាត់ទ្វារ។ នេះឃើញតែប៉ុណ្ណឹងទេបាទ។ ហើយសពហ្នឹងក៏ខាង ១៧ ហ្នឹង គេដឹកយកទៅបាត់ទៅ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

[១១:៣១:២៧]

**ស៖** នៅពេលដែលលោកនិយាយអំពីអ៊ំរបស់លោកនោះ លោកចង់និយាយពី ខាំភួន ឬក៏និយាយអ្នកណា?

**ឆ៖** បាទ ខាំភួន បាទ។

**ស៖** តើព្រឹត្ត -- រឿងមូលហេតុដែលគួរឲ្យទុកចិត្តបានជាងគេនោះ ចំពោះលោកនោះ តើមកពីការឈ្លោះគ្នារវាងពួកគាត់ ឬមួយក៏មកពីការអន្តរាគមន៍ពីខាងក្រៅដែរ ឬក៏ការសងសឹកមកពីក្រៅនោះ ដែលធ្វើឲ្យគាត់ស្លាប់ហ្នឹង?

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអភ័យទោស ខ្ញុំសូមជំទាស់ទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍។ នេះគឺជាគោលជំហររបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលថាសាក្សីនេះ គឺមកផ្តល់សក្ខីកម្មទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល។ និងការទំនាក់ទំនង។ ចំពោះកាលបរិច្ឆេទដែលបានចោទប្រកាន់ដែលថាគេកោះហៅបុគ្គលណាម្នាក់មកទីក្រុងភ្នំពេញហ្នឹង គឺវាមិនពាក់ព័ន្ធនោះឡើយ។ ដូច្នេះ ខ្ញុំគិតថាព័ត៌មានលម្អិតដែលលោកចៅក្រមប្រហែលជានឹងពិចារណា និងសាកសួរនៅក្នុងសំណុំរឿង០០២/០១ហ្នឹង គឺកំពុងតែបន្តទៅមុខដែលការសាកសួរហ្នឹងប្រហែលជាមិនមាន ឬក៏មានការពាក់ព័ន្ធតិចតួចបំផុតទាក់ទងទៅនឹងចរនាសម្ព័ន្ធរដ្ឋបាល។ ដូច្នេះ ប្រសិនបើខ្ញុំនិយាយខុស សូមលោកចៅក្រមកែប្រែផង។ ការនិយាយអំពីការសម្លាប់ហ្នឹងប្រហែលជាមិនបានបង្កើតជាមូលសម្រាប់ជួយដល់អង្គជំនុំជម្រះនោះឡើយ។

[១១:៣៣:១៤]

ខ្ញុំមិនមែនជំទាស់ទៅនឹងសំណួរទី១នោះទេ ហើយខ្ញុំគ្រាន់តែចង់និយាយថា អ្វីដែលបានចោទប្រកាន់ហ្នឹង គឺបានលើកឡើង។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា អ្វីដែលកើតឡើងបន្ទាប់ពីការសម្លាប់ហ្នឹង គឺវាហាក់ដូចជាមិនពាក់ព័ន្ធនោះទេ។ សូមអរគុណ។

[១១:៣៣:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៤:២៤]

**ប្រធានអង្គជំនុំ៖**

បាទសេចក្តីជំទាស់ និងសំអាងហេតុសេចក្តីជំទាស់របស់មេធាវី នួន ជា មិនត្រឹមត្រូវទេ។ លោកសាក្សី ឆ្លើយតបនឹងសំណួរដែលសួរឡើងដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ ប្រសិនបើលោកមិនចាំទេ លោកអាចសុំឱ្យលោកចៅក្រមសួរសំណួរលោកសាជាថ្មីម្តងទៀត។

**លោក ផាន វ៉ាន៖**

**ឆ៖** សូមឱ្យសួរសាថ្មីម្តងទៀតបាទ។

[១១:៣៤:៥៦]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកសាក្សី ខ្ញុំអម្បាញ់មិញនេះ ខ្ញុំសួរលោកថា តាមអ្វីដែលលោកដឹងនោះ គឺថាមានព័ត៌មានមួយគួរឱ្យទុកចិត្តបានជាងព័ត៌មានមួយទៀត ទាក់ទងនឹងការស្លាប់របស់ឪពុកលោក និងអ៊ំលោក។ តើ សំណួរខ្ញុំចង់ដឹងថាតើជាជម្លោះរវាងពួកគាត់ទាំងពីរ ឬក៏មានមូលហេតុផ្សេងទៀតដែលធ្វើឱ្យពួកគាត់ស្លាប់នេះ?

**ឆ៖** ខ្ញុំអត់ៗយល់ដែរបាទ។ មិន -- បើថាគាត់ទាំងពីរនាក់ទាស់គ្នាក៏វាមិនត្រូវរឿងទាស់គ្នាពីរនាក់ដល់ថ្នាក់សម្លាប់គ្នាដែរ។ ពីព្រោះបងប្អូន អាហ្នឹងទី១។ ទី២ ព្រោះគាត់គ្មានរឿងអីទៅទាស់គ្នាទេបាទ។ ពីព្រោះមកពីនោះ មកល្អកល្អិនហ្នឹងគ្នា។ ទី៣ កាំភ្លើងក៏អត់មានដែរកាលជំនាន់ កាលចុះពីយន្តហោះមកអត់មានកាំភ្លើងទេ ព្រោះគេឆែក។ ហើយអីវ៉ែអីវ៉ាន់អីទុកនៅកន្លែងពាណិជ្ជទាំងអស់។ អត់មានកាំភ្លើង អត់មានស្អីជាប់នឹងខ្លួនទេ ពីព្រោះចុះពីយន្តហោះមក ឆែកឆេរអស់មុននឹងទៅបាទ។

[១១:៣៦:១៨]

អាហ្នឹងការស្លាប់របស់គាត់ហ្នឹង ព្រោះបើថាទាស់គ្នា វាមានទាស់តាំងពីផ្ទះទៅអីមានការជជែកគ្នា វែកញែកមានដឹងរឿងទាស់គ្នាជាធំដុំអីដែរ។ នេះគ្មានអីសោះបាទ។ ព្រោះជំនាន់ហ្នឹងការស្លាប់ហ្នឹងស្លាប់អត់មានការស៊ើបអង្កេតអីសាកសួរអីណាអត់មានទេ។ មាន -- ខ្ញុំវានៅក្មេងអត់យល់ដែរ។ បានថាស្លាប់ទៅ ក្រោយមកគេប្រកាសថា ខ្មាំងសម្លាប់អីចឹងទៅបាទ។ នេះខ្ញុំបញ្ជាក់បណ្តឹងបាទ។

**ស៖** តើចំពោះការស្លាប់គាត់នេះ មានមូលហេតុជាផ្លូវការដែរឬទេ? តើគេៗបានប្រព្រឹត្តទៅលើឪពុកលោក សាកសពគាត់ទាំងពីរហ្នឹងដូចគ្នាដែរឬទេ ដូចឪពុកលោកអ៊ីចឹងគេបានបូជាគាត់ ហើយបញ្ជូនធាតុទៅតំបន់១០៥ ទៀត តើចំពោះអ៊ំលោកនោះមានការប្រព្រឹត្តដូចគ្នាដែរឬទេ ទៅលើរូបគាត់?

**ឆ៖** ជំនាន់ហ្នឹង ខ្ញុំអត់បានដឹងទេ ព្រោះគេអត់ឲ្យ -- ខ្ញុំក៏មិនបានទៅធ្វើបុណ្យធ្វើទានអីទេបាទ។ ព្រោះធាតុគាត់ទាំងពីរហ្នឹងមិនដឹងគេធ្វើយ៉ាងម៉េច ខ្ញុំក៏អត់បានដឹងដែរ។ ក្រោយពីហ្នឹងមកខ្ញុំនៅអរិយក្សត្រមួយរយៈអ៊ីចឹងទៅ មកនៅជាមួយអ្នកស្រី អៀង ធីរិទ្ធ ដល់អ៊ីចឹងទៅស្រុកក៏អត់បានឲ្យទៅដែរ។ ខ្ញុំសុំគេទៅ គេអត់ឲ្យទៅដែរបាទ។

**ស៖** បើសិនជាលោកមិនអាចឆ្លើយប្រាប់ពីការបរិច្ឆេទជាក់លាក់ទេ តើលោកអាចយល់ថាអាចឲ្យជាឆ្នាំ ឬក៏ថាចុងឆ្នាំ ខែណាមួយលោកអាចផ្តល់ព័ត៌មាននេះបានទេ ទាក់ទងនឹងមរណភាពរបស់គាត់ទាំងពីររូបនេះ?

[១១:៣៨:៥០]

**ឆ៖** អង្គាល់ហ្នឹងចាំឆ្នាំអត់បានបាទ។ ខ្ញុំចាំឆ្នាំអត់បាន មិនដឹងឆ្នាំណាខែណាប្រាកដ។ បើថាចង់ស្រាវជ្រាវឲ្យប្រាកដហ្នឹងទាល់តែខ្ញុំមានពេលវេលា ស្រាវជ្រាវសួរបងប្អូន ហើយមិត្តភក្តិដែលៗជិតស្និទ្ធនឹងគ្នា អាហ្នឹងបានច្បាស់ពិតប្រាកដតែម្តងបាទ។

**ស៖** តើលោកដឹងដែរឬទេ នៅពេលដែលរឿងនេះកើតឡើងនេះ មានបុគ្គលផ្សេងទៀតដែលជាអ្នករងគ្រោះនៃការបោសសម្អាត? តើមានអ្នកផ្សេងទៀតដែលត្រូវបានគេកោះហៅមករៀនសូត្រនៅភ្នំពេញ ហើយបាត់ខ្លួន ហើយបើសិនជាលោកដឹង សូមផ្តល់ឈ្មោះអ្នកទាំងនោះ។ សូមអរគុណ។

**ឆ៖** ក្រោយពីឪពុកខ្ញុំស្លាប់--

[១១:៣៩:៥៦]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

លោកប្រធាន ខ្ញុំសូមធ្វើការជំទាស់ទៅនឹងសំណួរនេះ។ ខ្ញុំសូមអភ័យទោស ដែលខ្ញុំត្រូវធ្វើការកាត់ ប៉ុន្តែខ្ញុំសូមជំទាស់ទៅលើសំណួរនេះ។

តើខ្ញុំអាចលើកបានដែរទេ? ខ្ញុំសូមបញ្ជាក់ថា ខ្ញុំសូមធ្វើការជំទាស់ ហើយខ្ញុំសូមអភ័យទោសដែលខ្ញុំធ្វើការជំទាស់បែបនេះ។ ម៉្យាងអ្វីដែលខ្ញុំចង់និយាយគឺថា ការបោសសម្អាតមិនមែនជាផ្នែកនៃសំណុំរឿងនោះទេ។ វាមិនមែនជាមូលដ្ឋាននៃឧក្រិដ្ឋកម្ម ដែលយើងកំពុងតែពិនិត្យឡើយ។ អ្វីដែលយើង

ពិនិត្យមើលនៅក្នុងសំណុំរឿងនេះគឺ ការជម្លៀសប្រជាជន។ ជាការពិត យើងអាចនិយាយអំពីទូរលេខ អំពីរចនាសម្ព័ន្ធ អ្វីៗដែលយើងនិយាយនេះ។ ប៉ុន្តែនៅពេលដែលយើងសួរលម្អិត អំពីការបោសសម្អាត ដែលបានចោទប្រកាន់នោះ ខ្ញុំសូមធ្វើការលើកឡើងថា វាគឺស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។ ខ្ញុំសូមធ្វើការបញ្ជាក់ក្នុងកំណត់ត្រាប្រតិចារឹក ដោយសារតែវាហាក់ដូចជាចម្លែក ដែលខ្ញុំធ្វើការជំទាស់ទៅនឹងសំណួរបែបនេះ ប៉ុន្តែខ្ញុំធ្វើការជំទាស់នេះ ដើម្បីបញ្ចូលទៅក្នុងកំណត់ត្រាប្រតិចារឹក។

[១១:៤១:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ជាប្រយោជន៍គឺថាត្រូវ អង្គជំនុំជម្រះត្រូវប្រកាន់គោលជំហរថា សម្រេចថាតើនៅពេលដែលចៅក្រមចោទសំណួរនោះភាគីអាចជំទាស់បានដែរឬក៏អត់? ហើយខ្ញុំគិតថា នេះមិនគួរជំទាស់ទេ។ យើងបាននិយាយសាក្សី និយាយអំពីការកោះហៅ ដែល នួន ជា កោះហៅទៅតំបន់១០៥ ហើយក្រោយមកមានការបាត់ខ្លួន។ ហើយខ្ញុំ -- ហើយអ៊ីចឹងខ្ញុំគិតថាសំណួរនេះ វាពាក់ព័ន្ធហើយ ព្រោះវាពាក់ព័ន្ធទៅនឹងការបោសសម្អាត ដែលចេញដោយថ្នាក់លើ គឺថាមានបញ្ជាពីថ្នាក់លើ ទាក់ទងនឹងការបោសសម្អាតនេះ ចេញពីមជ្ឈិមតែម្តង។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមធ្វើការឆ្លើយតប។ ខ្ញុំយល់ស្របថាសំណួរគឺថា ប្រធានបទដែលលើកឡើង គឺនិយាយអំពីការទំនាក់ទំនង មធ្យោបាយទំនាក់ទំនង។ ខ្ញុំមិនជំទាស់ទៅលើបញ្ហានេះទេ អ្វីដែលខ្ញុំជំទាស់គឺ ការព្យាយាមស្វែងរកព័ត៌មានលម្អិតនៃការបោសសម្អាតជាលក្ខណៈបុគ្គល ដែលខ្ញុំគិតថា ចៅក្រម ឡាវែន៍ គាត់នឹងធ្វើការសាកសួរទៅលើបញ្ហានេះ។ ប្រសិនបើខ្ញុំមិនត្រូវបានឲ្យអនុញ្ញាត គឺថាវាជាបញ្ហាមួយផ្សេង ប៉ុន្តែខ្ញុំនឹងព្យាយាមធ្វើការជំទាស់ ប្រសិនបើវា អ្វីដែលខ្ញុំជំទាស់ ហើយខ្ញុំសង្ឃឹមថា ចៅក្រមប្រហែលជាអាចសម្រេចទៅលើបញ្ហានេះបាន។ សូមអរគុណ។

[១១:៤៣:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៤:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចថា សេចក្តីជំទាស់មិនត្រឹមត្រូវ មិនមានមូលដ្ឋានច្បាប់ទេ។ ហើយអង្គជំនុំជម្រះសម្រេចថា មិនអនុញ្ញាតឲ្យភាគីជំទាស់ទៅនឹងការតាំងសំណួររបស់ចៅក្រមនៃអង្គជំនុំជម្រះទេ។

បញ្ចប់ ឥឡូវនៅសល់ ឲ្យឆ្លើយបញ្ចប់ទៅ ព្រោះពេលវេលាអស់ហើយ។

**លោក ផាន វ៉ាន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ព្រឹត្តិការណ៍នៃការស្លាប់ ហ្នឹងដូចខ្ញុំបានរៀបរាប់អ៊ីចឹង ពួកគាត់ចុះអត់មានកាំភ្លើង អត់មានអីទេ ប៉ុន្តែការស្លាប់ហ្នឹង ស្លាប់នៅលើគ្រែ ដូចខ្ញុំបានបញ្ជាក់រៀបរាប់អ៊ីចឹង។ លើគ្រែឪពុកខ្ញុំ លើគ្រែ ហើយអ៊ំខ្ញុំហ្នឹងស្លាប់នៅមាត់ទ្វារ ដោយមានកាំភ្លើងជាប់នៅនឹងដៃ។ ប៉ុន្តែការមកហ្នឹង វាអត់មានកាំភ្លើងទេ វាឆ្លល់ត្រង់ហ្នឹងជំនាន់ហ្នឹងបាទ។ ប៉ុន្តែការស៊ើបអង្កេតអីក៏អត់មានដែរ តែក្រោយមកក៏គេប្រកាសថា "ក្បត់" ថាអ៊ំខ្ញុំហ្នឹងក្បត់សម្លាប់ឪពុកខ្ញុំអ៊ីចឹងទៅ។ នេះខ្ញុំបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

[១១:៤៦:២៤]

**ប្រធានអង្គជំនុំ៖**

បាទ កិច្ចដំណើរការសវនាការសម្រាប់ព្រឹកនេះដល់ពេលត្រូវសម្រាកហើយ ដោយហេតុថានៅពេលវេលាបន្តិចទៀតនេះផ្នែកខាងអន្តរជាតិនឹងរៀបចំកិច្ចប្រជុំ*ថោនហលមីទ្ទិង* មួយនៅវេលាម៉ោងដប់ពីរ។ ចាប់ផ្តើមពីម៉ោងដប់ពីរដែលត្រូវខាងការិយាល័យរដ្ឋបាល ស្នើសុំរៀបចំនូវទីកន្លែងសម្រាប់ប្រជុំ។ ហើយសវនាការគឺទៅបន្តធ្វើនៅរសៀលនេះចាប់ផ្តើមពីម៉ោងពីរ ហើយការសវនាការនៅរសៀលនេះគឺធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-1 តាមមធ្យោបាយសោតទស្សន៍ពីប្រទេសបារាំង ដែលនឹងផ្តើមនឹងសួរដេញដោល ដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុនភាគីដទៃទៀត។

អរគុណលោក ផាន វ៉ាន ការស្តាប់សក្ខីកម្មរបស់លោកមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មលោកនៅព្រឹកថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត គឺថ្ងៃព្រហស្បតិ៍ ទី១៣ ខែធ្នូ ឆ្នាំ២០១២។ ហើយមន្ត្រី -- មេធាវីប្រឹក្សាសាក្សីដូចគ្នា គឺសូមអញ្ជើញលោកមកជាមួយនឹងសាក្សី នៅព្រឹកថ្ងៃស្អែកទៀតចាប់ផ្តើមវេលាម៉ោងប្រាំបួន។

[១១:៤៧:៤៥]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែង ដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំបានជម្រាបថា គាត់មិនមានសុខភាពល្អទេ ដូច្នេះគាត់សុំអនុញ្ញាតតាមដានកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម ដោយសារថាឈឺខ្នង ឈឺចង្កេះ និងមិនអាចផ្តង់អារម្មណ៍បាន។ ហើយយើងនឹងដាក់ពាក្យសុំអនុញ្ញាតលះបង់សិទ្ធិ ដើម្បីឲ្យគាត់អាចបន្តការតាមដាននៅពេលរសៀលនេះនៅបន្ទប់ឃុំខ្លួនខាងក្រោម។ សូមលោកប្រធានមេត្តាអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាពដែលនាំឲ្យគាត់មិនអាចអង្គុយតាមដានក្នុងកិច្ចដំណើរការសវនាការ ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះបាន។

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិ ចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ របស់ជនជាប់ចោទ នួន ជា។

[១១:៤៩:៣៦]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ សម្រាប់

រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឱ្យលោក នួន ជា នៅក្នុងបន្ទប់រៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឱ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ ឱ្យបានមុនម៉ោងពីររសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥០ នាទី ដល់ម៉ោង ១៤:០៩ នាទី)*

[១៤:០៩:៣៨]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការនេះ។ សវនាការនេះ អង្គជំនុំជម្រះនឹងដំណើរការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឈ្មោះ ដេនីស អាហ្វុងកូ (Denise AFFONCO) គឺដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-1។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ដេនីស អាហ្វុងសូ៖**

**ឆ៖** ជម្រាបសួរលោកប្រធានៗ។

**ស៖** បាទ លោកស្រី។ ខ្ញុំឈ្មោះ និល ណុន ជាចៅក្រម និងជាប្រធានអង្គជំនុំជម្រះសាលាដំបូង

នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សូមសួរលោកស្រីថាតើលោកស្រីឈ្មោះអ្វី?

**ឆ៖** ខ្ញុំឈ្មោះ ដេនីស អាហ្វុងសូ។

**ស៖** បាទ អរគុណលោកស្រី។ តើលោកស្រីអាចប្រាប់អង្គសវនាការបានទេ ថាតើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា?

[១៤:១២:៣០]

**ឆ៖** ខ្ញុំកើតនៅថ្ងៃទី២២ វិច្ឆិកា ឆ្នាំ១៩៤៤ នៅទីក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ តើលោកស្រីសព្វថ្ងៃនេះ រស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំនៅប្រទេសបារាំងសព្វថ្ងៃនេះ។ ខ្ញុំរស់នៅប្រទេសបារាំង ផ្នែកខាងត្បូងប្រទេសបារាំងនៅ -- *អាជ្រេស* គឺផ្ទះលេខ៧ *ស្ទ្រីម៉ា* ផ្លូវអារ៉ូម -- ដេហ្សារ៉ូម។

**ស៖** បាទ អរគុណលោកស្រី។ តើលោកស្រីប្រកបមុខរបរ រកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** លោកប្រធាន សព្វថ្ងៃនេះ ខ្ញុំចូលនិវត្តន៍ហើយ។ ពីមុនមក ខ្ញុំជារាជការនៅក្រសួងការបរទេស។ ខ្ញុំសិក្សាខាងសន្តិសុខនៅសហភាពអឺរ៉ុប ហើយខ្ញុំបញ្ចប់ការងារខ្ញុំហ្នឹងនៅឆ្នាំ២០០៩។

**ស៖** បាទ អរគុណ។ តើលោកស្រីអាចប្រាប់ដល់អង្គសវនាការបានទេថា ឪពុករបស់លោកស្រីឈ្មោះអី? ហើយម្ដាយរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ម៉ូរីស លូស្យាង អាហ្វុងសូ ហើយម្ដាយខ្ញុំជាជនជាតិ -- ឪពុកខ្ញុំជនជាតិបារាំង ម្ដាយខ្ញុំជនជាតិវៀតណាម ហើយឈ្មោះ ទ្រួង ធីឡេ។

**ស៖** បាទ អរគុណ ហើយសព្វថ្ងៃនេះ តើស្វាមីលោកស្រីឈ្មោះអ្វី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីខ្ញុំឈ្មោះ រ៉ូប៊ែ អែកម៉ាន ហើយយើងពុំមានកូនចៅអ្វីទេ។

**ស៖** បាទ អរគុណ។ លោកស្រីមានសញ្ជាតិអ្វីដែរ?

[១៤:១៥:១៧]

**ឆ៖** ខ្ញុំមានសញ្ជាតិបារាំង។

**ស៖** បាទ អរគុណ។ លោកស្រី អាហ្វុងសូ ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីស្ថានភាពទុក្ខវេទនា ស្ថានភាពព្យសនកម្ម ដែលកើតមានចំពោះលោកស្រី ដែលមានជាអាទិ៍ ការខូចខាតខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬខាងសម្ភារៈ ព្យសនកម្ម

ផ្ទាល់ដែលជាបច្ច័យដោយផ្ទាល់ ពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឱ្យលោកស្រីប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

**ឆ៖** *(គ្មានការបកប្រែ)*

*(មានបញ្ហាបច្ចេកទេស)*

**ស៖** បាទ យើងបន្តឱ្យចប់ពីព្រោះមានបញ្ហា ហើយសូមបញ្ជាក់ថា ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលត្រូវចោទប្រកាន់ទៅលើជនជាប់ចោទទាំងបីរូប នួន ជា, អៀង សារី, ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយនេះជាពេលចុងក្រោយ ដែលអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅលោកស្រី ឱ្យធ្វើដូច្នេះ ប្រសិនបើមានលោកស្រីមានបំណងធ្វើដូច្នេះ។ លោកស្រីយល់ទេ?

[១៤:១៧:២៧]

**ឆ៖** ខ្ញុំយល់លោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយលោកស្រីអាចជម្រាបដល់អង្គសវនាការបានទេ នៅជិតលោកស្រីដូចជាមានមេធាវីមួយរូប។ តើលោកឈ្មោះអ្វី ហើយជា -- មានទំនាក់ទំនងយ៉ាងម៉េចជាមួយលោកស្រី?

**ឆ៖** គាត់ជាមេធាវីរបស់ខ្ញុំ ឈ្មោះ ជូល្យាន រីវ៉េ (Julien Rivet) ។

**លោក ជូល្យាន រីវ៉េ៖**

បាទ ជម្រាបសួរលោកប្រធាន ខ្ញុំជាមេធាវីរបស់គាត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះ សូមជម្រាបជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ជាការអនុវត្តនូវបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីឯទៀតនៃរឿងក្តី។ ហើយសូមជម្រាបថា ទាំងសហមេធាវីនាំមុខ រួមទាំងសហព្រះរាជអាជ្ញា មានពេលវេលាមួយពេល មួយរសៀលនេះក្នុងការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ មេធាវីដែលទទួលសិទ្ធិនៅក្នុងការសួរសំណួរទៅលើលោកស្រី

ដេនីស ហ្វុងស្វូ គឺលោកមេធាវី សំ សុគង់ និងលោកមេធាវី អេម៉ានូអ៊ែល ហ្សាកូមី។ ក៏ប៉ុន្តែខ្ញុំមានចំណុចមួយចង់ជម្រាបជូនលោកប្រធាន និងលោក លោកស្រីចៅក្រម ដូចបង្ហាញនៅលើអេក្រង់អម្បាញ់មិញ គឺមានវត្តមានរបស់លោកមេធាវី រីវ៉េ -- ជូល្យាន រីវ៉េ ដែលនៅជិតលោកស្រីថាតើមានការចាំបាច់នៅក្នុងការស្នើសុំ ដើម្បីឲ្យមានការទទួលស្គាល់លោកមេធាវីនេះឲ្យហើយដែរ ឬយ៉ាងណា? សូមលោកប្រធានសម្រេច។ សូមអរគុណ។

[១៤:១៩:៤០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ បើមានការស្នើសុំតើលោកមេធាវីនេះ បានចុះបញ្ជីនៅគណៈមេធាវីកម្ពុជាហើយនៅ? ហើយបានស្បថនៅចំពោះមុខសាលាឧទ្ធរណ៍ហើយឬនៅ?

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ លោកមេធាវីនេះ គាត់នៅក្នុងក្រុមមេធាវីមួយ ដែលបានផ្តល់ -- ទទួលសិទ្ធិពីលោកស្រី ដេនីស ហ្វុងស្វូ នេះ យូរឆ្នាំហើយ។ ហើយគាត់ តាមព័ត៌មានដែលដឹងគឺ គាត់បានស្បថរួចហើយ នៅចំពោះមុខសាលាឧទ្ធរណ៍លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះបើយូរហើយ តើវាមានបញ្ហាអីនឹងការទទួលស្គាល់ដែរឬទេ?

[១៤:២០:៣៧]

**លោក ពេជ អង្គ៖**

បាទ សូមៗអរគុណលោកប្រធាន។ តាមការពិត កន្លងមកនៅពេលដែលចាប់ផ្តើមសវនាការកន្លងមកគឺ លោកមេធាវីរូបនេះមិនទាន់បានមកចូលរួមនៅក្នុងសវនាការផ្ទាល់ទេ តែពេលនេះ លោកមេធាវីរូបនេះមានវត្តមាន។ ដូច្នេះ នៅជិតដើមបណ្តឹងរដ្ឋប្បវេណី ហើយវត្តមាន -- ហើយជាកិច្ចមួយនៃនីតិវិធី ដែលបង្ហាញអំពីការចូលរួមក្នុងកិច្ចមួយក្នុងនីតិវិធីនៃសវនាការយើងនេះ។ ដូច្នេះ យោបល់ -- សំណួរចង់សួរលោកប្រធានថាតើមានភាពចាំបាច់ថា ឲ្យយើងខ្ញុំសូមឲ្យមានការទទួលស្គាល់ឲ្យហើយ ឬក៏ចាំលោកមេធាវីនេះមកមានវត្តមានផ្ទាល់តែម្តងនៅក្នុងសវនាការនេះ ដើម្បីឲ្យយើងខ្ញុំសូមការទទួលស្គាល់ពី -- ឲ្យលោកមេធាវីនេះមានសិទ្ធិពេញលេញដូចមេធាវីដទៃទៀត។ សូមអរគុណ។

[១៤:២១:៤១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២២:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមិនប្រាកដថា អង្គជំនុំជម្រះយល់ពីស្ថានភាពនេះទេ តើជាការត្រឹមត្រូវដែរឬទេថា មេធាវី ជូល្យាន រីវ៉េ ដែលតំណាងឲ្យអ្នកស្រី អាហ្វុងសូ បានចុះឈ្មោះនៅគណៈមេធាវីនៅប្រទេសកម្ពុជា ហើយបានស្បថរួចហើយនៅសាលាឧទ្ធរណ៍នៅប្រទេសខ្មែរយើងនេះ។ តើនេះស្ថាន -- យើងស្ថិតនៅក្នុងស្ថានភាពនេះដែរឬទេ? តើឥឡូវនេះ លោកកំពុងតែសុំឲ្យគាត់ទទួលស្គាល់ក្នុងឋានៈជាមេធាវីអន្តរជាតិ? រហូតដល់ពេលនេះ បានធ្វើអីខ្លះហើយចំពោះគាត់នេះ ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី? សូមឲ្យគាត់ទទួលស្គាល់ហើយឬនៅ?

**លោក ពេជ អង្គ៖**

រហូតមកដល់ពេលនេះ យើងខ្ញុំពុំទាន់បានសុំឲ្យមានការទទួលស្គាល់ ពីសំណាក់អង្គជំនុំជម្រះចំពោះមេធាវីរូបនេះនៅឡើយទេ ហើយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ចង់ជម្រាបជូនព័ត៌មានបន្ថែម។ សូមអរគុណលោកប្រធាន។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមបំភ្លឺបញ្ហានេះ គឺថាមេធាវី ជូល្យាន រីវ៉េ ជាសមាជិកគណៈមេធាវីនៅប្រទេសកម្ពុជាហើយគាត់បានស្បថនៅប្រទេសកម្ពុជាហើយៗ។ ហើយគាត់ទទួលអណត្តិពីអ្នកស្រី អាហ្វុងសូ គាត់នៅប្រទេសបារាំងទេ ក៏ប៉ុន្តែមេធាវីដែលចោទសំណួរគាត់នៅថ្ងៃនេះ គឺមេធាវី ហ្សាកូមី ដែលស្ថិតនៅក្នុងក្រុមគាត់ដែរ ហើយគាត់នុ៎ងក៏ជាមេធាវីរបស់អ្នកស្រី អាហ្វុងសូ ហ្នឹងដែរ។ ដូច្នេះ សំណួរដែលចង់សួរទៅអង្គជំនុំជម្រះនោះ ថាតើចង់ឲ្យយើងសុំការទទួលស្គាល់លោកមេធាវី ជូល្យាន រីវ៉េ នេះអំពីសំណាក់អង្គជំនុំជម្រះដែរឬទេ? ពីព្រោះថា រាល់ដងនោះទាល់តែមេធាវីនោះមានវត្តមាននៅក្នុងសាលសវនាការនេះបានសូមឲ្យទទួលស្គាល់ តែគាត់នៅស្រុកបារាំងទេឥឡូវនេះ។

[១៤:២៤:៤១]

**ប្រធានអង្គជំនុំ៖**

បាទ នៅដំណាក់កាលនេះ ហើយតាមនីតិវិធីនេះ មេធាវីដែលចូលរួមនៅអមជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី អាហ្វុងសូ នាពេលនេះគ្រាន់តែគាំពារដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ គាត់មិនចូលរួមនៅក្នុងការតាំងសំណួរដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណីទេ។ ដូច្នេះ អង្គជំនុំជម្រះមិនតម្រូវធ្វើនីតិវិធីនៃការបង្ហាញទទួលស្គាល់គាត់នាពេលនេះទេ ដំណាក់កាលនេះទេ គឺដំណាក់កាលក្រោយដរាបណាគាត់មកនៅចំពោះមុខអង្គជំនុំជម្រះចូលរួមនៅក្នុងបន្ទប់សវនាការនេះ ទើបអង្គជំនុំជម្រះកំណត់តម្រូវឱ្យគាត់ឱ្យមេធាវីសុំការទទួលស្គាល់គាត់ ដូចជាមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

**លោក សំ សុគង់៖**

បាទ ជាបឋម ខ្ញុំបាទ សូមគោរពគោរពលោកប្រធាន ក្រុមប្រឹក្សា សូមគោរពក្រុមប្រឹក្សា និងសូមគោរពក្រុមប្រឹក្សាទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

**ស៖** ជម្រាបសួរលោកស្រី ដេនីស អាហ្វុងសូ! លោកស្រីស្តាប់ខ្ញុំឮទេ លោកស្រី?

**លោកស្រី ដេនីស អាហ្វុងសូ៖**

**ឆ៖** ខ្ញុំឮលោកច្បាស់ណាស់ លោកមេធាវី។

**ស៖** លោកស្រី ខ្ញុំមានសំណួរមួយចំនួនដែលនឹងសួរលោកស្រី ហើយនៅក្នុងដំណាក់កាលទី១នៃសំណួររបស់ខ្ញុំ ខ្ញុំសួរទាក់ទងនឹងមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ សំណួរទី១ របស់ខ្ញុំចង់ដឹងថា មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកស្រីបានរស់នៅកន្លែងណាដែរនៅក្នុងប្រទេសកម្ពុជា?

[១៤:២៧:០០]

**ឆ៖** ខ្ញុំនៅទីក្រុងភ្នំពេញ។ អាសយដ្ឋានចុងក្រោយរបស់ខ្ញុំ គឺនៅផ្លូវឧញ៉ា ខ្ញុំមិនចាំថាឧញ៉ាអីទេ គឺជាផ្លូវនៅក្បែរកន្លែងផ្តល់វិភាជដល់យោធា។ ខ្ញុំមិនដឹងផ្លូវហ្នឹងឈ្មោះផ្លូវអីទេ ហើយនៅជិតពេទ្យចិនផងដែរ។

**ស៖** នៅពេលនោះ តើលោកស្រីមានមុខរបរធ្វើការងារអ្វីដែរនៅមុនថ្ងៃ១៧ មេសា ១៩៧៥?

**ឆ៖** មុនមេសា ឆ្នាំ១៩៧០ -- ៧៥ ខ្ញុំជាលេខា ខ្ញុំធ្វើការនៅក្នុងក្រុមហ៊ុនជាច្រើន ហើយក្រុម-

ហ៊ុនចុង -- តំណែងចុងក្រោយដែលខ្ញុំកាន់កាប់នោះ គឺនៅផ្នែកវប្បធម៌នៃស្ថានទូតបារាំង។ ខ្ញុំធ្វើការនៅក្នុងផ្នែកវប្បធម៌នៅឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ -- រហូតដល់៧៣ហ្នឹង ខ្ញុំធ្វើការនៅក្រុមហ៊ុនឯកជន គឺថាក៏មានខ្មែរដែលធ្វើទឹកដោះគោខាប់ ហើយនិងក្រុមហ៊ុនមួយទៀតឈ្មោះ ស៊ូគីឡេ។ ហើយខ្ញុំធ្វើការឲ្យការិយាល័យប្រធានរបស់ខ្ញុំ។

[១៤:២៨:៤៤]

**ស៖** លោកស្រីបានមានប្រសាសន៍ថា លោកស្រីធ្វើការនៅស្ថានទូតបារាំង។ តើនៅក្នុងអំឡុងពេលលោកស្រីធ្វើការនៅស្ថានទូតបារាំងហ្នឹង តើលោកស្រីអាចរៀបរាប់បានទេពីស្ថានភាព?

**ឆ៖** ខ្ញុំធ្វើការនៅផ្នែកវប្បធម៌ នៅស្ថានទូតបារាំង។

**ស៖** បាទ សូមអរគុណលោកស្រី។ ទាក់ទងនឹងស្ថានភាពមុនឆ្នាំ -- មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកស្រីមានអាចរៀបរាប់បានទេ ពីស្ថានភាពកាលសម័យនោះនៅក្នុងទីក្រុងភ្នំពេញ?

**ឆ៖** ពេល សីហនុ ត្រូវបានគេទម្លាក់ពីតំណែង ហើយ លន់ នល់ ឡើងកាន់អំណាច ហើយដែលការមានទំនោរទៅកាន់ខាងអាមេរិក។ សង្គ្រាមស៊ីវិលក៏ចាប់ផ្ដើមកើតឡើងនៅប្រទេសកម្ពុជា។ រាល់រៀងរាល់ថ្ងៃចាប់ពីពេលនោះមកហ្នឹង យើងទទួលគ្រាប់ផ្លោង ដែលធ្លាក់នៅតាមផ្សារ នៅតាមសាលា ហើយការរស់នៅនោះកាន់តែលំបាកទៅៗ។ ខ្ញុំអាចបន្តទៀតបានទេ? អ៊ីចឹងការរស់នៅកាន់តែលំបាកទៅៗ យើងរស់នៅក្នុងភាពភ័យខ្លាច ហើយក្នុងការទន្ទឹងរង់ចាំសន្តិភាព គឺថាចាំការ -- ដោយយើងរំពឹងទុកថា ពេលដែលថាសង្គ្រាមចប់ទៅសន្តិភាពមកដល់ ហើយនិងរង់ចាំជ័យជម្នះខ្មែរក្រហម។ នៅពេលនោះ នៅពេលដែលខ្មែរក្រហមនៅតែបន្តផ្លោងដាក់ក្រុង ជួនកាលធ្លាក់លើស្ពាន ហើយគ្រាប់ផ្លោងហ្នឹងធ្លាក់នៅលើព្រលានយន្តហោះពោធិ៍ចិនតុងជាដើម ហើយធ្លាក់ចូលក្នុងទឹកទន្លេ។ ពេលនោះ គឺថាជិវិត យើងថាថប់ដង្ហើម ដកដង្ហើមមិនរួចទេ ពិបាករស់នៅ។

[១៤:៣១:០៥]

នៅឆ្នាំ១៩៧២ នៅពេល -- ពេលនោះ ខ្ញុំធ្វើការនៅរោងចក្រផលិតទឹកដោះគោនៅឡើយ ហើយតាំងពីពេលនោះមកហើយ ដែលយើងពិបាកផលិតទឹកដោះគោ ពីព្រោះពេលនោះយើងពិបាករករូបធាតុដើម ហើយក្រោមមកទៀត ខ្ញុំទៅធ្វើការនៅស្ថានទូតបារាំង ហើយនៅពេលនោះហើយដែល -- ប៉ុន្តែជីវិតនៅតែបន្តរស់ទៅទៀត ក៏ប៉ុន្តែដោយលំបាក។ នៅស្ថានទូតបារាំងនោះ រាល់ថ្ងៃខ្ញុំមកទទួលដំណឹងគេដំណឹងប្រាប់យើងពីការលំបាក គេនិយាយថានៅពួកទាហានខ្មែរក្រហមចូលដល់កន្លែងណានោះ គឺថា

បំផ្លាញភូមិស្រុក ហើយជម្លៀសប្រជាជនចេញ។ អ៊ីចឹងដំណឹងដែលគួរប្រកាសភាពអាសន្នទាំងអស់នេះមកដល់យើង ហើយខ្ញុំប្រាប់កូនខ្ញុំ ប្ដីខ្ញុំ ហើយដោយសារគាត់នោះ គាត់ខាងចិនកុម្មុយនីស្ត ហើយគាត់ក៏ឆ្លើយប្រាប់ខ្ញុំថា "អានេះសុទ្ធតែជាការឃោសនាពួកអាចក្រពត្តិទេ។ ព្រោះថាគាត់នោះ អ្នកស្ដាប់វិទ្យុមកពី -- ផ្សាយមកពីទីក្រុងប៉េកាំង ហើយដែលប្រកាសព័ត៌មានខុសពីហ្នឹង។ ហើយដែលក្នុងការប្រកាសផ្សាយព័ត៌មាននេះគឺថា ពេលខ្មែរក្រហមទៅណា ប្រជាជនសប្បាយរីករាយកន្ធែងនោះ"។ ហើយនៅៗពេលដែលស្ថានភាពកាន់តែដុនដាបទៅ ពេលនោះអាជ្ញាធរបារាំងបានសុំឲ្យប្រជាពលរដ្ឋរបស់ខ្លួនចាកចេញពីប្រទេសកម្ពុជា ហើយខ្ញុំមិនបានធ្វើតាមដំបូន្មានគេនោះទេ ខ្ញុំសុខចិត្តនៅប្រទេសខ្មែរជាមួយប្ដីខ្ញុំ ហើយនិងកូនចៅខ្ញុំ។ ពីព្រោះថាប្ដីខ្ញុំនោះ ពេលនោះគាត់យល់ឃើញយ៉ាងជាក់ច្បាស់ថា របបកុម្មុយនីស្តនឹងមិនធ្វើបាបប្រជាជននោះទេ។ ហើយដោយអាស្រ័យហេតុដូច្នេះហើយ ក៏យើងនៅប្រទេសកម្ពុជា ហើយនៅក្នុងឋានរកតែម្ដង។

[១៤:៣៣:១៥]

**ស៖** សូមអរគុណបាទ។ សំណួរពាក់ព័ន្ធនឹងមុនថ្ងៃ១៧ មេសា មួយទៀត ទាក់ទងនឹងលោកស្រីថា លោកស្រីបានទទួលព័ត៌មានពាក់ព័ន្ធនឹងជម្លៀស ៗប្រជាពលរដ្ឋ ហើយពួកខាងខ្មែរក្រហមទៅដល់ភូមិណា កម្ទេចភូមិនោះ។ តើលោកស្រីទទួលបានព័ត៌មាននេះនៅក្នុងអំឡុងឆ្នាំណាដែរលោកស្រី?

ខ្ញុំសូមសួរម្ដងទៀត នៅពេលដែលលោកស្រីបានឆ្លើយពីខាងលើអម្បាញ់មិញថា លោកស្រីបានទទួលព័ត៌មាននៅពេលដែលលោកស្រីនៅធ្វើការនៅខាងវប្បធម៌នៅទូតបារាំងហ្នឹង ឮថាមានកងទ័ពខ្មែរក្រហមហ្នឹងចូលទៅដល់ភូមិណា គឺកម្ទេចនៅនោះ ទី១ ហើយទី២ ទាក់ទងនឹងការជម្លៀសប្រជាពលរដ្ឋចេញពីភូមិ។ តើលោកស្រីទទួលបានព័ត៌មាននេះក្នុងឆ្នាំណាដែរ?

[១៤:៣៥:០៣]

**ឆ៖** អង្កាល់នោះ នោះ ខ្ញុំទទួលព័ត៌មានតាមរយៈភ្នាក់ងារសារព័ត៌មានបារាំង គឺថានៅរវាងឆ្នាំ -- ខែមករា គឺថាចន្លោះ៧៣-៧៥ ហ្នឹង។ ចន្លោះ៧៣-៧៥ ហើយដំណឹងទាំងអស់នោះ នោះគឺភ្នាក់ងារសារព័ត៌មានបារាំងដែលផ្ញើមកខ្ញុំ ហើយខ្ញុំទទួលដំណឹងនេះរាល់ថ្ងៃតាមរយៈស្ថានទូត ហើយតាមហ្វាក់។

**ស៖** ទាក់ទងនឹងព័ត៌មានដែលលោកស្រីបានទទួលតាមរយៈសារព័ត៌មានក៏ដូចជាស្ថានទូតតាមរយៈហ្វាក់ហ្នឹង ក្រៅពីការជម្លៀសប្រជាពលរដ្ឋតើលោកស្រីមានបានទទួលដំណឹងអីផ្សេងទៀតទេ?

**ឆ៖** ជាការពិតណាស់ គឺថារាល់ថ្ងៃហ្នឹង ថាយើងឃើញមនុស្សជាព្រោងព្រាត ដែលជម្លៀស

ចេញពីភូមិស្រុកជិតៗហ្នឹង ហើយចូលមកក្នុងក្រុង ហើយគេរៀបរាប់រឿងប្រាប់យើង រឿងរ៉ាវដែលកើតមាននៅស្រុកភូមិគេនោះ គឺជាជនភៀសខ្លួនដែលមកដល់ទីក្រុងភ្នំពេញ ហើយពួកគាត់ហ្នឹងនិយាយរឿងរ៉ាវប្រាប់យើង។

[១៤:៣៦:៥៦]

**ស៖** តើលោកស្រីដឹងថា ហេតុអីបានជាប្រជាពលរដ្ឋគាត់ភៀសខ្លួន គាត់មិនភៀសខ្លួនទៅតំបន់ផ្សេងៗបែរជាភៀសខ្លួនមកទីក្រុងភ្នំពេញវិញ?

**ឆ៖** ពីព្រោះថានៅជុំវិញភ្នំពេញនោះ គឺថាសង្គ្រាមវាកាន់តែខ្លាំងទៅៗ ហើយភ្នំពេញនោះវាជាកន្លែងតែមួយគត់ដែលពួកគេអាចថា ខ្លួនពេលមកដល់ហ្នឹងនឹងមានសុវត្ថិភាព មានសន្តិសុខ។

**ស៖** បាទ សូមអរគុណលោកស្រី ហើយសំណួរមួយទៀតទាក់ទងទៅនឹងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ តើលោកស្រីរស់នៅទីក្រុងភ្នំពេញ ហើយលោកស្រីជាអ្នកធ្វើការខាងវប្បធម៌នៅស្ថានទូតបារាំងទៀត តើលោកស្រីអាចរៀបរាប់ពីស្ថានភាពនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ បានទេ?

**ឆ៖** ខ្ញុំអាចរៀបរាប់បានលោកមេធាវី។

[១៤:៣៨:២៩]

**ស៖** តើស្ថានភាពនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើវាមានស្ថានភាពបែបណាដែរលោកស្រី?

**ឆ៖** មុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ យើង កាលនោះ យើងសម្រាកបុណ្យចូលឆ្នាំគឺថ្ងៃទី១៣, ១៤, ១៥ មេសា។ ដូច្នេះយើងទាំងអស់គ្នានៅផ្ទះ ហើយថ្ងៃទី១៧ គឺជាថ្ងៃដែលខ្ញុំត្រូវត្រឡប់ទៅធ្វើការនៅការិយាល័យវិញ ហើយនៅព្រឹកនោះ ខ្ញុំកំពុងតែត្រៀមលក្ខណៈដើម្បីទៅធ្វើការ មិនទាន់ទាំងចេញពីផ្ទះផង ខ្ញុំឮសំឡេងប៉ោកព្រៀវ ហើយនិងឮស្នូរកាំភ្លើងមកពីគ្រប់ទិសទី។ ហើយខ្ញុំក៏មើលខាងក្រៅថាមានរឿងអ្វីកើតឡើង ហើយខ្ញុំឃើញហ្វូងមនុស្សថា សប្បាយរីករាយនឹងទទួលខ្មែររំដោះ ខ្មែរក្រហមដែលរំដោះនោះ។ គេហៅទាហានរំដោះជាតិ ហើយអ្នកទាំងអស់គ្នានោះសប្បាយចិត្តណាស់ ក៏ប៉ុន្តែទាហានរំដោះជាតិដែលខ្ញុំដាក់ក្នុងអព្ភន្តរនេះ គេស្លៀកពាក់ខ្មៅទាំងអស់ ហើយមានៗភ្នែកគេឡើងក្រហមស្រងែ។ ហើយខ្ញុំ កាលនោះ ខ្ញុំមានអារម្មណ៍ថា ប្រហែលជាមានគ្រោះថ្នាក់អីហើយ។ អារម្មណ៍ភ័យខ្លាចគ្រោះថ្នាក់ ហើយខ្ញុំប្រាប់ប្តីខ្ញុំថា បើយើង យើងគួរតែទៅស្ថានទូតបារាំងទៅ ក៏ប៉ុន្តែ -- គាត់ប៉ុន្តែពេលនោះយើងមិនអាចចេញពីស្ថានទូតបារាំងបានទេ ពីព្រោះថាគ្រប់ផ្លូវទាំងអស់រាំងស្ទះ សង្កាត់ទាំងអស់រាំងស្ទះ ស្ថានទូតនៅខាងជើង ហើយកាលនោះយើងនៅខាងត្បូងភ្នំពេញ។ អ៊ីចឹងហើយយើង

មិនអាចទៅស្ថានទូតបានទេ ផ្លូវទាំងអស់ស្ទះ ទូរស័ព្ទក៏មិនមានហើយទាក់ទងតាមវិធីណាក៏មិនបានដែរ។ ក៏ប៉ុន្តែ មនុស្សទាំងអស់គ្នា គេហាក់ដូចជាសប្បាយចិត្តណាស់ព្រោះគេគិតថា សន្តិភាពនឹងត្រឡប់ មកវិញហើយ ក៏ប៉ុន្តែនេះគ្រាន់តែជាការភ័ន្តច្រឡំតែប៉ុណ្ណោះ។

[១៤:៤០:៥៦]

**ស៖** បាទ សូមអរគុណលោកស្រី។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើប្រជាពលរដ្ឋទីក្រុងភ្នំពេញ ត្រូវបានជម្លៀសចេញហើយឬនៅលោកស្រី?

**ឆ៖** មិនមែនទេ នៅថ្ងៃទី១យើងនៅផ្ទះយើងនៅឡើយ។ នៅពេលដែលពួកខ្មែរក្រហមមក ដល់ប្រហែលជាខ្ទង់ម៉ោងប្រាំពីរ ម៉ោងប្រាំបីព្រឹក។ ហើយនៅថ្ងៃទី១ នោះពួកគេទុកឲ្យយើងនៅផ្ទះយើង អនុញ្ញាតឲ្យយើងនៅផ្ទះយើងនៅឡើយទេ។ ហើយនៅពេលដែលមេឃក្តៅខ្លាំងឡើងនោះ ខ្ញុំឃើញប្តីខ្ញុំ គឺថាឪពុកកូនចៅខ្ញុំនេះដែលជាអ្នកកាន់លទ្ធិកុម្មុយនីស្តនោះ យកប៊ីយែទៅឲ្យពួកខ្មែរក្រហមហ្នឹងផឹកទៀត។ ហើយថ្ងៃបន្ទាប់ហើយនោះទេ ដែលគេចេញបញ្ជាឲ្យយើងចាកចេញពីផ្ទះយើងទាំងអស់គ្នានោះ។

**ស៖** បាទ សូមអរគុណ។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ផងដែរនោះ តើលោកស្រីអាចរៀបរាប់ស្ថានភាពនៅស្ថានទូតបារាំង ដែលលោកស្រីធ្វើការនោះវាមានស្ថានភាពបែបណាដែរនៅស្ថានទូតបារាំង លោកស្រី?

**ឆ៖** លោកមេធាវីដូចដែលខ្ញុំបាននិយាយអម្បាញ់មិញនេះ ចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ មកនោះ ខ្ញុំមិនដែលត្រឡប់មកស្ថានទូតបារាំងវិញនោះទេ។ ខ្ញុំនៅផ្ទះខ្ញុំកាលពីថ្ងៃទី១៧ មេសា កាលនោះ ខ្ញុំត្រូវទៅធ្វើការហើយខ្ញុំមិនបានទៅធ្វើការនោះទេ មិនអាចទៅបាននោះទេ។

**ស៖** បាទ អរគុណ។ ចំពោះក្រុមគ្រួសារលោកស្រី តើក្រុមគ្រួសារលោកស្រីត្រូវបានគេជម្លៀសនៅថ្ងៃទីប៉ុន្មានដែរ លោកស្រី?

[១៤:៤៣:១៤]

**ឆ៖** យើងចាកចេញពីទីក្រុងភ្នំពេញក្នុងពេលជាមួយគ្នា ក្រុមគ្រួសារយើងទាំងអស់ចេញថ្ងៃជាមួយគ្នាគឺថ្ងៃបន្ទាប់ៗ ពីពួកខ្មែរក្រហមចូល។ ហើយពួកខ្មែរក្រហមប្រាប់យើងឲ្យរៀបចំអីវ៉ែអីវ៉ាន់ ហើយកុំឲ្យយកច្រើន អ្នកទាំងអស់គ្នាចេញពីទីក្រុងភ្នំពេញតែពីរបីថ្ងៃទេ ហើយក្រោយមកត្រឡប់មកវិញហើយ កុំឲ្យត្រូវគ្រាប់បែកអាមេរិកាំង។ ហើយយើងក៏ថែមទាំងឲ្យសោរផ្ទះយើងទៅពួកខ្មែរ ក្រហមទៀតហ្នឹង ហើយដោយប្តីខ្ញុំនោះគាត់ជាមនុស្សទន់ភ្លន់ ហើយនិងគាត់ជឿជាក់ថាអ្វីៗទាំងអស់នឹងប្រសើរ

ឡើង ហើយគាត់ទុកស្បៀងអាហារសឹងទាំងអស់នៅផ្ទះ។ អ៊ីចឹងយើងយកសៀវភៅបន្តិចបន្តួច អីវ៉ែអីវ៉ាន់បន្តិចបន្តួច ហើយនិងកាតអត្តសញ្ញាណប័ណ្ណរបស់យើងបន្តិចបន្តួចប៉ុណ្ណោះ ហើយយើងចាកចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១។ ហើយខ្ញុំនៅចាំនៅឡើយទេ ពេលដែលមុនចេញ ពួកខ្មែរក្រហមនៅមុខផ្ទះ ហើយយើងឲ្យសោរផ្ទះយើងទៅឲ្យគាត់ ហើយប្រាប់ថា នេះផ្ទះខ្ញុំ អ៊ីចឹងខ្ញុំសូមផ្ញើសោរផង។ ហើយពេលនោះយើងចាកចេញទៅ ក្រុមគ្រួសារយើងទាំងអស់ចាកចេញទៅក្នុងពេលជាមួយគ្នា។

[១៤:៤៥:០០]

**ស៖** បាទ សូមអរគុណ។ លោកស្រីថា នៅពេលដែលលោកស្រីចាកចេញពីលំនៅដ្ឋាន ឬពីផ្ទះហ្នឹងលោកស្រីបានឃើញខ្មែរក្រហម។ តើខ្មែរក្រហមទាំងនោះ គាត់មានឯកសណ្ឋានជាអ្វីដែរលោកស្រី?

**ឆ៖** កាលនោះយើងមានឡានម៉ាកហ្វតមួយ។ យើងចាកចេញដោយជិះឡានហ្នឹង ហើយយើងចង់ទៅខាងជើង ទៅខាងស្ពានទួតបាវាំង ទៅមិនបានដោយសារគេរាំងផ្លូវ អ៊ីចឹងយើងធ្វើដំណើរទៅខាងត្បូង ហើយនៅមុខពេទ្យចិនហ្នឹងមានទាហានខ្មែរក្រហម -- មានខ្មែរ ទាហានខ្មែរបីនាក់ មានស្លៀកពាក់ពណ៌បៃតង មិនមែនជាឯកសណ្ឋានពណ៌ខ្មៅទេ។ ហើយពួកគេនោះចេញពីហាងមួយ ហើយគេលួចអីៗនៅក្នុងហាងនុំង ហើយនៅក្នុងកន្ត្រកគេនោះ សុទ្ធតែស្បៀងអាហារដែលគេលួច ហើយគេក៏ឲ្យឡានយើងឈប់ ហើយគេសុំ គេដាក់អីវ៉ែអីវ៉ាន់គេលើឡានយើង ហើយពេលនោះហើយដែលប្ដីខ្ញុំនិយាយថា ប្រាប់គាត់ថា យើង -- សាំងនៅសល់តិចណាស់ ទៅឆ្ងាយមិនកើតទេ ហើយគេក៏និយាយថា ឥឡូវចាំយើងនៅទីនេះហើយ។ ម្នាក់នៅក្នុងចំណោមអ្នកទាំងបីនាក់ហ្នឹងចេញទៅហើយ ត្រឡប់មកវិញយកសាំងមកចាក់ឡាន ហើយគេដាក់អីវ៉ែអីវ៉ាន់ក្នុងឡាន លើឡាន ហើយគេឡើងលើដំបូលឡាន ហើយគេបាញ់ឡើងទៅលើ ដើម្បីកុំឲ្យស្ទះផ្លូវឲ្យមនុស្សចៀសផ្លូវឲ្យ ដើម្បីឲ្យឡានទៅមុខស្រួល។

[១៤:៤៧:០១]

**ស៖** លោកស្រី ខ្ញុំចង់តាំងសំណួរបន្តិចទៀត ទាក់ទងទៅនឹងពេលដែលលោកស្រី មុនជម្លៀសលោកស្រីថា នៅមុខ -- នៅក្នុងមុខផ្ទះលោកស្រីមានទាហានខ្មែរក្រហម ដែលទៅប្រាប់លោកស្រីឲ្យលោកស្រីចាកចេញ តើទាហាន -- តើពួកខ្មែរក្រហមទាំងនោះ គាត់មានឯកសណ្ឋានអ្វីដែរ ហើយគាត់មានអាវុធនៅក្នុងដៃដែរឬទេ នៅពេលដែលប្រាប់លោកស្រីឲ្យចាកចេញពីផ្ទះនោះ?

**ឆ៖** ខ្ញុំអាចជម្រាបជូនបានលោកមេធាវី។

**ស៖** បាទ សូមអញ្ជើញ!

**ផ៖** ពួកគេនោះមានកាំភ្លើង គេមិនបានភ្ជង់យើងទេ គេគ្រាន់តែបញ្ជាយើងយ៉ាងមុតមាំឲ្យចាកចេញ ហើយគេស្លៀកពាក់ខោអាវខ្មៅ សម្លៀកបំពាក់ខ្មៅ ហើយមានក្រមាបង់-ក ពណ៌ស ហើយពណ៌ក្រហម ក្រឡាក្រហម-ស ហើយគេស្ពីដូចក្រមាមកពីខាង -- ពាក់ស្បែកជើងហូជីមិញ ហើយពួកគេនោះមានកាំភ្លើងកាន់។

**ស៖** នៅពេលដែលគេប្រាប់លោកស្រីឲ្យចាកចេញ ក៏ដូចជាប្រជាពលរដ្ឋ ប្រជាជនផ្សេងៗទៀតនៅទីក្រុងភ្នំពេញ លោកស្រីមានបានឃើញស្ថានភាពថា ក្នុងពេលនៅពេលដែលប្រជាជនណាមួយមិនចាកចេញ តើគេអាចនឹងប្រើអំពីហិង្សា ឬក៏បង្ខំបែបណាមួយដល់ប្រជាពលរដ្ឋទាំងនោះដែរឬទេលោកស្រី?

[១៤:៤៨:៥២]

**ផ៖** នៅក្នុងសង្កាត់យើង មិនមានអ្នកណាជំទាស់ទេ យើងគោរពតាមបញ្ជាទាំងអស់។ ប៉ុន្តែក្រោយមកទៀត អ្នកដែលនៅហ្នឹងទៀត មិត្តភក្តិខ្ញុំនៅរៀននៅវិទ្យាល័យនោះ ដែលគាត់នៅភ្នំពេញដើម្បីចាំប្តីគាត់នោះ ប្តីគាត់មិនដែលត្រឡប់មកវិញទេ ហើយគាត់ ខ្លួនគាត់ មិត្តភក្តិខ្ញុំផ្ទាល់នោះ ក៏ត្រូវបានគេសម្លាប់ដែរសម្លាប់នៅនឹងកន្លែងតែម្តង។ ហើយដែលខ្ញុំដឹងនេះ ដោយសារបងប្អូនគាត់ហ្នឹងមកប្រាប់ខ្ញុំនៅប្រទេសបារាំងនេះ។ អ៊ីចឹងបើសិនជាកាលនោះ បើសិនជាយើងមិនបានចាកចេញវិញទេនោះ គឺថាយើងក៏ប្រហែលជាត្រូវគេសម្លាប់ចោលទាំងអស់គ្នាហ្នឹង ព្រោះគេឲ្យយើងចេញទៅ ដើម្បីចៀសពីគ្រាប់បែកអាមេរិកាំង។

**ស៖** នៅពេលដែលលោកស្រីចាកចេញពីផ្ទះ ពីលំនៅដ្ឋាន តើលោកស្រីទៅតាមទិសខាងណានៃទីក្រុងភ្នំពេញ?

**ផ៖** គឺទាហានទាំងបីនាក់ ដែលនៅលើដំបូលយើងនោះ ដែលគេនាំផ្លូវយើងឲ្យចេញតាម ទៅខាងត្បូងចេញទៅតាមតាខ្មៅ ពួកគេនុំងហើយជាអ្នកនាំផ្លូវយើងចេញទៅតាមនុំង។

**ស៖** នៅពេលដែលលោកស្រីត្រូវបានទាហាន នាំលោកស្រីទៅទិសខាងត្បូង ទៅតាមទីក្រុងតាខ្មៅ តើជាទិសមួយដែលលោកស្រីមានបំណងចង់ទៅដែរឬទេនៅពេលនោះ?

[១៤:៥១:០១]

**ផ៖** អត់ទាល់តែសោះ។ ទិសដែលគេនាំទៅនោះ ខ្ញុំមិនចង់ទៅទេ ទិសដែលខ្ញុំចង់ទៅ ទៅ

ស្ថានទូតបារាំង នៅខាងជើងភ្នំពេញនោះ។ ក៏ប៉ុន្តែយើងមិនអាចទៅទិសខាងជើងទេពេលនោះៗ។

**ស៖** អរគុណលោកស្រី។ ពាក់ព័ន្ធទៅនឹងការធ្វើដំណើររបស់លោកស្រី ទៅទិសខាងត្បូងនៃទីក្រុងភ្នំពេញ តើលោកស្រីអាចរៀបរាប់ពីស្ថានការណ៍ទៅតាមផ្លូវ ទាក់ទងទៅនឹងការជម្លៀសប្រជាជនក៏ដូចជាក្រុមគ្រួសារលោកស្រីធ្វើដំណើរ តើវាមានស្ថានការណ៍បែបណាដែរ នៅពេលធ្វើដំណើរលោកស្រី?

**ឆ៖** គឺជាភាពច្របូកច្របល់ដែលមិនអាចពណ៌នាបានទេ គឺថាមេឃក្តៅខ្លាំងគ្រប់ទិសទី ហើយយើងឃើញមនុស្សដើរជើងទទេ ឬក៏ដែលជិះកង់ ជិះស៊ីក្លូ ហើយដាក់អីវ៉ែអីវ៉ាន់ទៅតាមដែលខ្លួនអាចដាក់បាន មានអ្នកខ្លះដើរក្រោមមេឃក្តៅ ហើយក្មេងៗយំរញ៉េរញ៉ៃ រញ៉េចរញ៉ាចពីក្រោយ ហើយតាមចេញពីពេទ្យនោះវិញឃើញថា អ្នកជំងឺនៅលើប្រង់កា ឬគេរុញរទេះនោះ។ អ៊ីចឹងមនុស្សទាំងអស់នោះត្រូវបានគេបណ្តេញឲ្យទៅទិសតែមួយ ហើយយើងគឺថាជាការដែលលំបាកមែនទែន។ យើងដូចមានសំណាងម៉្យាងដែរ ដោយសារយើងមានឡាន យើងចំណាយពេលតិចជាងគេបន្តិច ដើម្បីឲ្យទៅដល់ចំណុចទី១ គឺថាកន្លែងសម្រាកទី១ ក៏ប៉ុន្តែគ្រាន់តែចេញផុតពីភ្នំពេញបន្តិចនោះ -- អ៊ំ! ចេញពីតាខ្មៅបន្តិចនោះមានចំណុចត្រួតពិនិត្យមួយ កុងត្រូលមួយ ហើយគេមានកុងត្រូលគេសុំអត្តសញ្ញាណបណ្ណ គេឆែកឆេរឡាន ហើយនិងបោះសៀវភៅចោល ហើយនិងកូនក្រមុំ ហើយខ្ញុំប្រាប់គាត់ថា ខ្ញុំជាជនជាតិបារាំង។

[១៤:៥៣:២៥]

អ៊ីចឹង គេយកកាតខ្ញុំឲ្យកាត និងប៉ាស្ព័រ គេយកៗហើយគេហែកចោលទាំងអស់ បោះចោល ហើយគេនិយាយថា ចាប់ពីពេលនេះទៅលែងមានបារាំង លែងមានវៀតណាម លែងមានចិនទៀតហើយ នៅទីនេះមានតែខ្មែរទេ ហើយទៅមុខទៅ! អង្គការចាំអ្នកទាំងអស់គ្នានៅមុខ។ នេះជាថ្ងៃទីមួយ ហើយដែលខ្ញុំឮពាក្យអង្គការនោះ ខ្ញុំមិនដឹងថា អង្គការនោះជាអ្វីទេ។ ហើយនៅពេលនោះៗ ខ្ញុំមិនដឹងថា អង្គការនោះជាអ្នកណាទេ យើងបន្តដំណើរទៀតទៅ ហើយខ្ញុំចាប់ផ្តើមយំហើយនៅពេលនោះ ខ្ញុំគិតទៅដល់កូនខ្ញុំ គិតពីសៀវភៅដែលថា ទុកឲ្យពួកគេអាន ហើយគេថា អ្វីទាំងអស់ដែលខ្ញុំយកទៅនោះ គេហែកចោលតែមួយភ្លែតតែប៉ុណ្ណោះ ហើយតាមផ្លូវឃើញមានលុយរាត់រាយ ហើយឃើញយើងយកលុយទៅតាមប្រហែលជាពីរលានរៀលទៅតាមនោះ តែគេយកលុយចោលទាំងអស់។ នេះស្ថានភាពវាបែបនេះឯង។ ហើយយើងទៅដល់ចំការមននោះ នៅខាងតាមផ្លូវនោះនៅមានខ្មោចជាច្រើនស្អុយរលួយនៅទីនោះ។

[១៤:៥៤:៣៤]

**ស៖** ខ្ញុំមានសំណួរពីរសំណួរទៀតដែលសួរទៅលោកស្រី ហើយនៅសល់ប្រហែលជាសហមេធាវីខ្ញុំគាត់នឹងមានសំណួរបន្ត។ សំណួរមួយទៀតគឺ ពាក់ព័ន្ធនឹងលោកស្រីបានឆ្លើយពីខាងលើអម្បាញ់មិញថា នៅចំការមនលោកស្រីឃើញមានខ្មោច ហើយធុំក្លិនស្អុយរលួយ អាសោចយ៉ាងខ្លាំង។ តើសាកសពទាំងនោះជាសាកសពប្រជាជនធម្មតា ឬមួយក៏ជាអ្នករាជការណាមួយនៅក្នុងសម័យណាមួយមុនៗខ្មែរ -- មុនថ្ងៃ១៧ មេសា?

**ឆ៖** គឺជាខ្មោចយោធា តាមមើល គឺជាខ្មោចទាហាន។ ហើយនេះពិតជាសាកសពទាហាន លន់ នល់ ហើយ។

**ស៖** បាទ សូមអរគុណលោកស្រី។ សំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធទៅនឹង នៅពេលដែលលោកស្រីធ្វើដំណើរទៅតាមផ្លូវចេញពីទីក្រុងភ្នំពេញទៅឆ្ពោះទៅទិសខាងត្បូង ទៅទីក្រុងតាខ្មៅនោះ។ ស្ថានភាពទាក់ទងនឹងចាស់ជរា ក៏ដូចជាកុមារ ឬក៏អ្នកជំងឺដែលត្រូវបានគេបង្ខំឲ្យជម្លៀសចេញពីមន្ទីរពេទ្យក៏ដូចជាស្ត្រីមានផ្ទៃពោះ តើពួកគាត់ត្រូវបានគេយកចិត្តទុកដាក់ក្នុងការធ្វើដំណើរ ក៏ដូចជានូវបញ្ហាដែលគាត់ឈឺចាប់នៅពេលធ្វើដំណើរដែរឬទេ?

[១៤:៥៦:២៥]

**ឆ៖** គេប្រព្រឹត្តទៅលើបុគ្គលគ្រប់រូបដូចគ្នា ហើយមនុស្សទាំងអស់គ្នាត្រូវចាកចេញពីផ្ទះរបស់ខ្លួន ហើយទៅទិសតែមួយ ទៅតាមទិសដែលទាហានចង្អុលបង្ហាញ ហើយយើងមិនមានទទួលជំនួយពីអ្នកណានោះទេ ហើយមេឃក្ដៅខ្លាំង ហើយធ្វើឲ្យកូនក្មេងដែលឪពុកម្ដាយដែលមិនអាចអៀវបានអីបាន ឬក៏ដាក់លើកង់បានអីនោះ គឺថាត្រូវដើរតាមក្រោយ គឺគ្មានអ្នកណាជួយទេ ទាហាននោះ មិនមានទាហានណាជួយទេ។ ទាហាន គេហៅថាទាហានរំដោះនោះ គ្មានជួយអីទេ។ ពុំមានជួយអ្វីទាំងអស់ គឺថាក្បាលអ្នកណា សក់អ្នកហ្នឹងតែម្ដង។

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំសូមអស់សំណួរ ហើយទុកសំណួរនេះទៅខាងសហភាតារបស់គាត់ខ្ញុំដែលក្រែងលោគាត់មានសំណួរបន្ត។ ហើយសូមអរគុណលោកស្រី ដេនីស អាហ្វុងសូ ដែលព្យាយាមឆ្លើយនូវសំណួររបស់ខ្ញុំ។ បាទ សូមអរគុណ។

**លោកស្រី ដេនីស អាហ្វុងស្វូ៖**

សូមអរគុណលោកមេធាវី។

**លោក អេម៉ានូអ៊ែល ហ្សាកូមី៖**

សូមអរគុណលោកមេធាវី សំ សុគង់។ លោកប្រធាន លោកស្រីចៅក្រម ជម្រាបសួរ។ ភាគីទាំងអស់ ជម្រាបសួរសាធារណជន ជម្រាបសួរលោកស្រី អាហ្វុងស្វូ។ ខ្ញុំឈ្មោះ ហ្សាកូមី អេម៉ានូអ៊ែល។ ខ្ញុំជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៤:៥៨:១១]

**សួរដោយលោក អេម៉ានូអ៊ែល ហ្សាកូមី៖**

**ស៖** ខ្ញុំចង់សួរសំណួរមួយចំនួន។ ជាដំបូង ជាសំណួរទូទៅពាក់ព័ន្ធនឹងរយៈពេលមុនឆ្នាំ៧៥ លោកស្រីបានឆ្លើយទិដ្ឋភាពមួយចំនួនទៅហើយ ហើយខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងការសម្ភាសទី -- ការជម្លៀសទី១ ហើយនិងចូលដល់ការជម្លៀសទី២។ លោកស្រី អាហ្វុងស្វូ ខ្ញុំព្យាយាមចោទសួរសំណួរច្បាស់លាស់ ហើយសូមឲ្យលោកស្រីឆ្លើយខ្លីៗ ឆ្លើយឲ្យបានច្បាស់ពីព្រោះថា យើងមានពេលវេលាខ្លីណាស់។ សូមឲ្យលោកស្រីឆ្លើយធ្វើម៉េចឲ្យខ្លីៗ ច្បាស់លាស់។ ជាដំបូងជាសំណួរទូទៅ តើនេះមិនមែនជាលើកទីមួយទេ ដែលលោកធ្វើសក្ខីកម្មនៅក្នុងសវនាការពាក់ព័ន្ធទៅនឹងអង្គហេតុដែលលោកស្រីបានរៀបរាប់នោះ គឺថាតើលោកស្រីធ្លាប់ផ្ដល់សក្ខីកម្មរួចហើយ ឬនៅ?

**លោកស្រី ដេនីស អាហ្វុងស្វូ៖**

**ឆ៖** ជម្រាបសួរលោកមេធាវី ខ្ញុំអាចឆ្លើយនឹងសំណួរនេះបាន។ នៅឆ្នាំ៧៩ នៅពេលវៀតណាមចូលមក គេបានរៀបចំការកាត់ក្ដីនៅខែសីហា ឆ្នាំ៧៩ គេបាននាំមកឲ្យខ្ញុំមកធ្វើសក្ខីកម្មនៅក្នុងសវនាការនោះ គឺឆ្នាំ៧៩ នោះ គឺខែសីហា គេបានរៀបចំសវនាការ ហើយកោះហៅខ្ញុំឲ្យចូលមកបំភ្លឺក្នុងនាមជាសាក្សី។

**ស៖** នៅពេលដែលលោកស្រីផ្ដល់សក្ខីកម្មនៅក្នុងសវនាការនោះ តើគេមានសួរលោកស្រីឲ្យលោកស្រីប្រាប់ពីអ្វីដែលមិនមែនជាការពិត គេឲ្យលោកស្រីលាក់បាំងការពិតដែរឬទេនៅពេលនោះ?

[១៤:៥៩:៥០]

**ឆ៖** អ្វីដែលខ្ញុំនិយាយនៅឆ្នាំ៧៩នោះ គឺខ្ញុំនិយាយដោយសេរី អ្វីដែលខ្ញុំ អ្វីដែលគេប្រាប់ឲ្យខ្ញុំលាក់នោះគឺថាឪពុករបស់ខ្ញុំ សេង ទៀង នោះ គឺជាជនកុម្មុយនីស្ដ។ នេះជាចំណុចតែមួយគត់ដែលគេ

ប្រាប់ខ្ញុំថា កុំឲ្យប្រាប់ថាប្ដីខ្ញុំជាជនកុម្មុយនីស្ដ។

**ស៖** ចុះអង្គហេតុផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងរឿងរ៉ាវដែលលោកស្រីបានឆ្លងកាត់នោះ តើគេមានប្រាប់ឲ្យលោកស្រីលាក់បាំង ឬក៏លុបចោលទេ?

**ឆ៖** គឺអត់ទេ គឺខ្ញុំនិយាយតែការពិតប៉ុណ្ណោះ។ គេប្រាប់ឲ្យខ្ញុំរៀបរាប់ការពិតរឿងរ៉ាវដែលខ្ញុំជួបប្រទះ។ ដូច្នេះ ខ្ញុំរៀបរាប់តែការពិតប៉ុណ្ណោះ។

**ស៖** សូមអរគុណ។ លោកស្រី អាហ្វុងសូ លោកស្រីបានរៀបរាប់អម្បាញ់មិញនេះថា មុនឆ្នាំ៧៥ មានស្ថានភាពលំបាកណាស់នៅទីក្រុងភ្នំពេញ តើលោកស្រីចាត់ទុកស្ថានភាពនេះថាជាស្ថានភាពមួយដែលបង្កឲ្យមានភាពអត់ឃ្លានដែរឬទេ?

[១៥:០០:៥៥]

**ឆ៖** ខ្ញុំមិននិយាយថា មានភាពអត់ឃ្លាននោះទេ។ ពីព្រោះថាយើងអាចនៅរកម្ហូបអាហារហូបចុកបាន។ ស្បៀងពិបាកមកដល់មែន ក៏ប៉ុន្តែប្រជាជននៅតែអាចហូបចុក គឺមិនទាន់មានគ្រោះអត់ឃ្លាននៅឡើយទេ នៅពេលនោះៗ។ គ្រោះអត់ឃ្លាន គឺកើតក្រោយឆ្នាំ៧៥ នៅពេលដែលគេជម្លៀសប្រជាជនចេញពីទីក្រុង ហើយបញ្ជូនឲ្យទៅធ្វើការស្រែចម្ការ គេបង្ខំឲ្យធ្វើការនោះ ពេលនោះហើយដែលកើតមាននូវភាពអត់ឃ្លាននោះ។ ហើយការអត់ឃ្លាននេះ គឺជាការអត់ឃ្លានដែលមានការរៀបចំត្រឹមត្រូវ។

**ស៖** សូមអរគុណលោកស្រី។ សំណួរមួយពាក់ព័ន្ធទៅនឹងគ្រួសាររបស់លោកស្រី លោកស្រីបានឆ្លើយថា លោកស្រីបានកើតនៅឆ្នាំ១៩៤៤ ដូច្នេះនៅពេលនោះ លោកស្រីមានអាយុប្រហែលជា៣០ឆ្នាំផ្លាយ តើមែនទេលោកស្រី?

**ឆ៖** ពិតហើយលោកមេធាវី គឺអ៊ីចឹងមែន។

[១៥:០១:៤៨]

**ស៖** តើលោកស្រីអាចបញ្ជាក់អំពីសមាជិកគ្រួសារដែលនៅជាមួយលោកស្រីនៅពេលនោះ ដែលគេបានជម្លៀសជាមួយលោកស្រី? ហើយសូមបញ្ជាក់អាយុផងលោកស្រី។

**ឆ៖** ប្ដីរបស់ខ្ញុំមានអាយុប្រហែល៣៨ឆ្នាំ ប្អូនថ្លៃរបស់ខ្ញុំមានអាយុប្រហែលជា៣៦, ៣៧។ កូនខ្ញុំមានអាយុប្រហែល៨ឆ្នាំ កូនស្រី, កូនប្រុស ១០ឆ្នាំ ហ្សង់ហ្សាក, ហ្សានី កើតឆ្នាំ៦៧ ហើយកូនរបស់ប្អូនថ្លៃរបស់ខ្ញុំមានឈ្មោះ ឡេង អាយុប្រហែល១៧ ,១៨ឆ្នាំ មួយទៀតអាយុ១៥ឆ្នាំ ឬក៏១២ឆ្នាំ។ រឿងរ៉ាវវាកើតឡើងយូរមកហើយលោកមេធាវី ខ្ញុំប្រហែលជាមិនអាចចាំអាយុរបស់កូនៗទាំងអស់នោះបានទេ។

ហើយកូនដែលតូចជាងគេនោះ ឈ្មោះ ហា អាយុ៥ឆ្នាំ។

**ស៖** សូមអរគុណលោកស្រី។ លោកស្រីបានឆ្លើយថា លោកស្រីបានយកសម្ភារៈទៅមួយចំនួន មានសៀវភៅ មានស្បៀង មានលុយកាក់ ហើយក្រោយមក តើលោកស្រីអាចរក្សាទុករបស់របរទាំងអស់នេះបានទេ?

**ឆ៖** មិនអាចរក្សាបានទេ គេដកយើងទាំងអស់តាំងពីថ្ងៃដំបូង ប៉ុន្មានម៉ោងក្រោយមកនោះ គឺគេរឹបអូសយកទាំងអស់តែម្តង។ ទ្រព្យសម្បត្តិទាំងអស់នោះត្រូវបានរឹបអូសយកគ្មានទុកអ្វីបន្តិចទាល់តែសោះ។

[១៥:០៣:២០]

**ស៖** សូមអរគុណ។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីភូមិដំបូងដែលលោកស្រីបានរស់នៅបន្ទាប់ពីត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ។ លោកស្រីឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីថា "លោកស្រីបានទៅភូមិទួលទឹកវិល" តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ពិតមែនហើយ គឺភូមិកោះទឹកវិល។ នៅពេលទៅដល់យើងដេកនៅក្នុងវត្តមួយ។

**ស៖** សូមអរគុណ។ តើលោកស្រីអាចរៀបរាប់អំពីលក្ខខណ្ឌរស់នៅរបស់លោកស្រីនៅក្នុងភូមិនោះដែរឬទេ? ហើយជាពិសេសតើលោកស្រីមានម្ហូបអាហារហូបចុកគ្រប់គ្រាន់ទេ? ហើយអ្នកខាងអនាម័យអីនោះយ៉ាងម៉េចដែរ លោកស្រី?

**ឆ៖** នេះគឺជា នោះគឺជាថ្ងៃដំបូងនៃការជម្លៀស។ យើងមានរបស់របរគ្រប់គ្រាន់ ជាពិសេសថ្នាំសង្កូវ យើងអាចយកទៅដូរ ដោះដូរបាន ក៏ប៉ុន្តែរឿងមួយដែលយើងត្រូវធ្វើនៅពេលទៅដល់ភូមិនោះ គឺបោះចោលទាំងអស់នូវខោអាវពណ៌ គឺទុកតែខោអាវពណ៌ខ្មៅ កាត់សក់កាត់អីឲ្យខ្លី ដើរជើងទទេ ហើយយើងត្រូវតែផ្តល់ឲ្យទាំងអស់នៅពេលដែលអង្គការសុំ អង្គការសុំអី យើងត្រូវតែធ្វើតាមអង្គការបញ្ជា។

ថ្ងៃបន្ទាប់មក យើងចាប់ផ្តើមទៅស្រែចម្ការ ហើយចាប់ពីពេលនោះទៅ យើងលែងមានទឹក លែងមានភ្លើង ហើយយើងដុតទៀន ក៏ប៉ុន្តែយើងនៅជិតទន្លេ ដូច្នេះយើងមានទឹកទន្លេដើម្បីអាចផឹកបាន។ ប្រហែលជា១អាទិត្យក្រោយមក យើងមិនសូវមានបាយទេ យើងត្រូវលាយបាយជាមួយពោតដើម្បីហូប។ មេភូមិឈ្មោះលោក ផាន ដែលរស់នៅជិតខ្ទមស្បូវរបស់យើងនោះ បានមកយកដំណឹងពីយើងរហូត ក៏ប៉ុន្តែឪពុក -- ក៏ប៉ុន្តែប្តីរបស់ខ្ញុំជឿជាថា នេះជាការមកឃ្លាំមើល គឺជាគិញ គាត់ជាគិញហើយ ផាន នោះ។ ដូច្នេះគាត់ចង់បានព័ត៌មានដែលគាត់ចង់បាន។

**ស៖** ខ្ញុំយល់ពីអ្វីដែលលោកស្រីបានប្រាប់អម្បាញ់មិញនេះ គឺថាគេបង្ខំឲ្យលោកស្រីធ្វើការនៅក្នុងភូមិ តើកូនរបស់លោកស្រីដែលនៅជាមួយលោកនោះត្រូវបានគេបង្ខំឲ្យធ្វើការដែរឬទេ?

**ឆ៖** បាទ កូនៗក៏ត្រូវតែធ្វើការនៅក្នុងភូមិដែរ។ គឺពួកគេទៅរក អ្នកណារកឧសបានទៅរកឧស អ្នកណាទៅកាប់ផ្ការបានគឺទៅកាប់ផ្ការ ហើយទៅកាប់ដី។ កូនស្រីខ្ញុំនៅក្មេងពេក គឺពួកគេផ្ទះជាមួយនឹងកូនរបស់ លី ក៏ប៉ុន្តែពួកគេចាប់ផ្តើមមិនមានអាហារហូបចុកគ្រប់គ្រាន់ហើយពេលនោះ។

[១៥:០៦:៤០]

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្រីផ្តល់ចម្លើយជូនអ្នកស៊ើបអង្កេតសម្រាប់ជាប្រតិចារឹក គឺឯកសារ D195/15--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីគាត់អានលេខ ERN យឺតៗបន្តិចព្រោះអ្នកបកប្រែតាមអត់ទាន់ទេ។

**ប្រធានអង្គជំនុំ៖**

អ្នកបកប្រែតាមអត់ទាន់ទេ លោកមេធាវីអានលេខ ERN យឺត ហើយនិយាយឲ្យបានយឺតបន្តិចជាងនេះ! យឺតជាងនេះបន្តិចណ៎ះ!

**លោក អេម៉ានូអ៊ែល ហ្សាកូមី៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំនឹងនិយាយឲ្យបានយឺតៗ។

**សួរដោយលោក អេម៉ានូអ៊ែល ហ្សាកូមី៖**

**ស៖** ឯកសារនោះ គឺ 00346934 ជាភាសាអង់គ្លេស, 00349114 ជាភាសាខ្មែរ។ លោកបានលោកស្រីបាននិយាយអំពីភូមិនោះ គឺថាមានគុកមួយ មានគុកឥតជញ្ជាំង តើលោកស្រីអាចជម្រាបបានទេ គុកឥតជញ្ជាំងនោះ?

**ឆ៖** បាទ គឺពិតណាស់ គឺជាគុកឥតជញ្ជាំងមែន។ គេតាមឈ្លបមើលយើង ស៊ើបយកព័ត៌មានយើងរហូត ហើយគេសួរសំណួរពីកូនថា តើឪពុកឯងជាទាហានទេ ហើយមានសម្លៀកបំពាក់យោធាអីទេ? គឺចំពោះយើង យើងអត់មានសិទ្ធិចេញពីភូមិទេ យើងរស់នៅលើកោះមួយ ដែលកោះនុំងហ៊ុមជិតដោយអ្នកភូមិ។ ដើម្បីទៅធ្វើការនៅចម្ការ គឺមានស្ត្រីអ្នកភូមិយាមយើងទៀត។ ដូច្នេះមានអ្នកភូមិយាមការពារ យាមយើងរហូតពួកគេនោះហើយសុទ្ធតែជាគិញ។

[១៥:០៨:៥៦]

**ស៖** អ្នកភូមិបានឃាមលោកស្រី ចុះខ្មែរក្រហមនោះតើមានឃាមឃ្លាំមើលលោកស្រីទេ?

**ឆ៖** អ្នកភូមិទាំងអស់នោះ គឺសុទ្ធតែជាអ្នកចុះចូលជាមួយខ្មែរក្រហម។ ពួកនុ៎ងគឺសុទ្ធតែជាដៃជើងរបស់ខ្មែរក្រហមរួចទៅហើយ ពួកគេកាចសាហាវណាស់ ក៏ប៉ុន្តែអត់មានកាំភ្លើងទេ។

**ស៖** សូមអរគុណ។ តើលោកស្រីអាចជម្រាបបានទេ អំពីរឿងរ៉ាវដែលបានកើតឡើងចំពោះប្ដីរបស់លោកស្រីនៅក្នុងភូមិនោះ?

**ឆ៖** លោក សេង គាត់ជាមនុស្សចូលចិត្តឡូឡា ជជែកគ្នា ហើយគាត់មានមិត្តជាស្នងការប៉ូលិស ហើយគាត់បានសុំ ផាន នោះឲ្យអតីតគ្រួសារស្នងការប៉ូលិសហ្នឹងមកនៅជាមួយគាត់។ ដូច្នេះពួកគាត់និយាយគ្នាណាស់ ជជែកគ្នាជាភាសាអង់គ្លេស ជាភាសាបារាំង គាត់បន្តជជែកគ្នា។ ស្នងការប៉ូលិសត្រូវបានគេយកចេញទៅមុនគេ។ ហើយមួយសប្ដាហ៍ក្រោយមកទាហានខ្មែរក្រហម ដែលមានកាន់កាំភ្លើងផងដែរនោះដែលមកកោះនោះ ហើយចាប់បុរសៗផ្សេងទៀតនៅក្នុងភូមិ ពួកខាង កូនចៅរបស់ស្នងការប៉ូលិស ហើយមានអ្នកខ្លះជាយោធាផងនោះ ហើយមាន សេង ដែលជាប្ដីខ្ញុំ ក៏គេយកទៅ។ ហើយគេបានប្រាប់ថាប្ដីរបស់លោកស្រីត្រូវបានគេវាយការណ៍ គេឆ្លើយដាក់ហើយ អង្គការត្រូវការព័ត៌មាន។

[១៥:១០:៤៤]

ហើយថ្ងៃទីពីរ គេប្រាប់ថាកុំភ័យអីគាត់នៅរស់ទេ ហើយអង្គការគឺគ្រាន់តែយកគាត់ទៅរៀនសូត្រប៉ុណ្ណោះ គឺគេយកទៅកសាងទេ គាត់នឹងត្រឡប់មកវិញមិនអីទេ។ សាមសិបឆ្នាំជាងក្រោយមកខ្ញុំមិនដែលឮដំណឹងពីគាត់អ្វីទាល់តែសោះ។ ដូចដែលខ្ញុំបានរៀបរាប់អ៊ីចឹង គឺថាអ្វីៗគឺគ្មានដំណឹង បាត់សូន្យឈឹង។

**ស៖** សូមអរគុណ។ លោកស្រីបាននិយាយថាប្ដីរបស់លោកស្រីត្រូវបានគេឆ្លើយដាក់ តើលោកស្រីដឹងទេថាគេឆ្លើយដាក់គាត់អំពីរឿងអ្វីដែរ?

**ឆ៖** ខ្ញុំអត់ដឹងទេ គ្រាន់តែគេប្រាប់ថាគេឆ្លើយដាក់គាត់។ មេភូមិ ផាន ឆ្លើយថាស្នងការប៉ូលិសនោះជាអ្នកឆ្លើយដាក់គាត់តែប៉ុននុ៎ង។ ហើយគេមិនដែលប្រាប់ពីហេតុផលពិតប្រាកដដល់យើងទេ។

[១៥:១១:៤៣]

**ស៖** សូមអរគុណលោកស្រី។

**ឆ៖** សូមអរគុណលោកមេធាវី។

**ស៖** នៅភូមិនេះដដែល នៅពេលដែលអ្នកស៊ើបអង្កេតស្តាប់ចម្លើយលោកស្រី លោកស្រីបានឆ្លើយថា ព្រឹកមួយលោកស្រីទទួលបានបញ្ជាឲ្យចូលរួមនៅក្នុងមិទ្ទីងមួយនៅក្នុងវត្ត។ សម្រាប់ជាប្រតិចារឹកនោះគឺឯកសារ D199/15, ទំព័រទី៤ ជាភាសាបារាំង 00342181, 00349464 ជាភាសាអង់គ្លេស, 00349113 ជាភាសាបារាំង(ស៊ីក)។ លោកស្រីអាចរៀបរាប់បានអំពីពេលប្រជុំនៅវត្តព្រៃទូតនោះ ដែរឬទេ? ហើយខ្មែរក្រហមបាននិយាយអ្វីខ្លះនៅក្នុងអង្គប្រជុំនោះ?

**ឆ៖** កិច្ចប្រជុំនោះនៅតែដក់ជាប់នៅក្នុងខួរក្បាលរបស់ខ្ញុំ ហើយខ្ញុំនៅតែចងចាំនូវអ្វីដែលគេបានប្រាប់។ ១អាទិត្យបន្ទាប់ពីយើងទៅដល់កោះទឹកវិល គេឲ្យយើងទៅប្រជុំនៅវត្តព្រៃទូត ហើយយើងត្រូវតែទៅទាំងអស់គ្នា។ នៅពេលទៅដល់វត្តនោះ យើងបានឈរជាជួរៗអង្គុយនៅលើដី ហើយយើងចាំបន្តិចមក បន្ទាប់មកមានក្រុមខ្មែរក្រហម មន្ត្រីខ្មែរក្រហម ទាហានបានមកដល់ហើយ ឡើងធ្វើសុន្ទរកថាដោយនិយាយអួតសរសើរពីអង្គការ និយាយអំពីជ័យជម្នះរបស់អង្គការ។ ហើយបន្ទាប់មកនិយាយថា “ពួកបរទេសមុនជ័យជម្នះយើងឲ្យចេញពីប្រទេសហើយ ហេតុអីក៏មិនចេញ? ហើយចុះអ្នកខ្មែរនៅភ្នំពេញ ហេតុអ្វីបានជាអ្នកឯងមិនធ្វើ? ហេតុអ្វីបានជាពួកអ្នកឯងនៅទីនេះ? យើងអាចបាញ់សម្លាប់ពួកអ្នកទាំងអស់គ្នាចោលបាន។ ប៉ុន្តែអ្នកឯងត្រូវតែធ្វើការ បើមិនអ៊ីចឹងទេគេសម្លាប់ចោល”។ នេះគឺជាសម្តីដែលខ្ញុំមិនដែលភ្លេចទេ។ បន្ទាប់មកគេមានក្រដាសមួយ គេប្រាប់ឲ្យយើងសរសេរអំពីប្រវត្តិរបស់យើង ហើយអង្គការត្រូវការឲ្យដឹងថាអ្នកណាជាកសិករ កម្មករ នៅទីក្រុងភ្នំពេញ គេនឹងនាំយើងទៅធ្វើការនៅរោងចក្រត្បាញ ហើយខ្ញុំឮពាក្យថា-- រោងចក្រមួយដែលខ្ញុំធ្លាប់ឮនោះ ខ្ញុំនឹកឃើញ។ ហើយបន្ទាប់មកទៀត នេះគឺគ្រាន់តែជាអន្ទាក់មួយសម្រាប់ពួកខ្មែរក្រហមដើម្បីឲ្យប្រជាជនទៅភ្នំពេញដើម្បីទៅធ្វើការ ប៉ុន្តែតាមពិតទៅមិនមែនអ៊ីចឹងទេ គឺពួកគេធ្វើ ដើម្បីស្ទូចពួកអ្នកអតីតបញ្ញវន្តដើម្បីយកទៅធ្វើការ តែតាមពិតមិនមែនយកទៅធ្វើការទេ។

[១៥:១៥:០៥]

**ស៖** តើលោកស្រីធ្លាប់ឃើញអ្នកទាំងអស់នោះ នៅមុនពេលដែលខ្មែរក្រហមដឹកនាំកិច្ចប្រជុំនោះទេលោកស្រី?

**ឆ៖** ខ្ញុំមិនដែលឃើញនោះទេ។ នេះគឺជាល្បិចមួយ ដែលខ្ញុំមិនដែលឃើញសោះក្នុងមួយជីវិតរបស់ខ្ញុំ។

**ស៖** តើគេមានប្រាប់ថា ពួកហ្នឹងមកពីណា ហើយជាមនុស្សសំខាន់បែបណាទេ?

**ឆ៖** ពួកគេមិនបង្ហាញណែនាំខ្លួនឲ្យយើងស្គាល់ទេ អត់មានការណែនាំខ្លួនអីទេ។ ពួកគេនិយាយអ្វីក៏ដោយ គឺតាងនាមឲ្យអង្គការរហូត។ គេមិននិយាយថា ពួកគេជាអីទេ ពួកគេប្រើរហស្សនាមរហូត។ យើងស្គាល់តែ តាឆេង, តាម៉ុក, តាស៊ី, តាសា គឺថាអត់មានឈ្មោះទាល់តែសោះ ឮតែតានេះតានោះអីចឹង អត់មានឈ្មោះពិតប្រាកដទេ។

[១៥:១៦:00]

**ស៖** សូមអរគុណលោកស្រី។ សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងភូមិមួយនេះ។ នៅក្នុងភូមិនោះ តើលោកស្រីមានឃើញការរើសអើងប្រជាជនផ្សេងៗនៅក្នុងភូមិនោះទេ?

**ឆ៖** នៅក្នុងភូមិនោះ មិនទាន់មានការរើសអើងនៅឡើយទេ។ បន្ទាប់ពេលដែលគេជម្លៀសយើងទៅពាយ័ព្យនោះបានមានការរើសអើង គេហៅយើងថា ប្រជាជនថ្មី ប្រជាជន១៧មេសា ហើយពួកគេ គេហៅថា ប្រជាជនចាស់ ប្រជាជនមូលដ្ឋាន។ ចាប់ពីពេលហ្នឹងហើយ បានយើងឃើញមានការប្រព្រឹត្តខុសគ្នាចំពោះប្រជាជនទាំងពីរនោះ ទាំងថ្មីទាំងចាស់នេះ។

**ស៖** នៅភូមិកោះទឹកវិលដដែល ពាក់ព័ន្ធទៅនឹងម្ហូបអាហារ តើលោកស្រីទទួលបានរបបអាហារដូចអ្នកភូមិដែរឬទេ?

**ឆ៖** នៅក្នុងជំរំការងារដំបូងនោះ យើងមិនទាន់ឃើញមានការបែងចែកខុសគ្នានៅឡើយទេ យើងអាចនៅដោយរៀងៗខ្លួនបាន ហើយគេមានចែកចាយបាយទឹក។ ក៏ប៉ុន្តែក្រោយមក យើងបានទទួលតែពោតទេ មានពោតច្រើន ហើយយើងអាចរស់នៅបានដោយសារតែយើងទៅស្ទូចត្រីនៅក្នុងទឹកទន្លេ។ នៅពេលនោះ គឺថាយើងមានឱកាសទៅស្ទូចត្រីបាននៅឡើយ។ យើងមិនទាន់ឃើញមានការប្រព្រឹត្តខុសគ្នាចំពោះប្រជាជនថ្មី និងប្រជាជនចាស់នៅឡើយនោះទេ។

[១៥:១៧:៥៤]

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីការចាកចេញពីភូមិកោះទឹកវិលរបស់អ្នកស្រី។ តើអ្នកស្រីអាចរៀបរាប់ថា នៅពេលណា ហើយនិងក្នុងកាលៈទេសៈណាដែរដែលអ្នកស្រីចាកចេញពីភូមិកោះទឹកវិលហ្នឹង?

**ឆ៖** សេង ត្រូវគេចាប់នៅខែកក្កដា ឆ្នាំ១៩៧៥ ហើយនៅប្រហែលជាខែកញ្ញា ឆ្នាំ៧៥ លោកប្រធានភូមិ ផាន នោះបានប្រមូលផ្ដុំយើង ហើយដោយមានបញ្ជីមួយ ហើយគាត់ប្រាប់ថា ឥឡូវនេះយើងទទួលបានបញ្ជីនេះពីអង្គការលើ ហើយឈ្មោះរបស់អ្នកនោះ គឺថាឈ្មោះអ្នកត្រូវចេញដែរ ហើយ

ខ្ញុំសួរថាទៅណា? គេថា អ៊ើ!ត្រូវតែចេញ។ ខ្ញុំចាប់ផ្តើមមានទម្លាប់នៅក្នុងភូមិហ្នឹងហើយ ខ្ញុំក៏អង្វរគាត់ថាតើលោកមិនអាចអន្តរាគមន៍នៅថ្នាក់អង្គការលើឲ្យខ្ញុំនៅហ្នឹង? ហើយគាត់ឆ្លើយមកវិញថា អ៊ឺ! ខ្ញុំមិនអាចជួយបានទេ បញ្ជាចេញមកពីលើឯណោះ អង្គការលើអ្នកសម្រេច ហើយមិនមែនខ្ញុំអ្នកសម្រេចទេ។ អ៊ីចឹងយើងត្រូវតែចេញ ហើយអ្នកមិនទៅភ្នំពេញទេ មិនត្រឡប់ទៅភ្នំពេញទេ ខ្ញុំក៏មិនដឹងថាគេនាំទៅណានោះទេ។ ហើយគាត់នោះចាត់ទុកថា ខ្ញុំនោះដូចកូនគាត់ដែរ តែមិនអាចជួយខ្ញុំបាន។ អ៊ីចឹងយើងត្រូវតែរៀបចំអីវ៉ាន់អីវ៉ាន់ឡើងទូកត្រឡប់ទៅវត្តដែលយើងបានទៅពីលើកមុននោះ ដើម្បីរង់ចាំឡានទាហានមកប្រមូលដឹកយើងចេញទៅនៅថ្ងៃបន្ទាប់។ ហើយនៅពេលយប់នោះ នៅពេលយើងត្រូវ -- ដែលយើងទៅវត្តនោះ -- ពេលយប់ដែលយើងត្រូវទៅវត្តនោះ។

**ស៖** តើអ្នកស្រីដឹងថា មានឈ្មោះណាផ្សេងទៀតទេនៅក្នុងបញ្ជីហ្នឹង បញ្ជីដែលលោក ផាន មាននោះ?

[១៥:២០:០២]

**ផ៖** គឺថាគ្រួសារដែលគេនាំទៅហ្នឹងឯង នៅភូមិហ្នឹង អ៊ីចឹងក្រុមគ្រួសារទាំងអស់ហ្នឹង គេចាត់ថាជាអ្នកក្បត់។ អ៊ីចឹងគេថា ចង់និយាយថា ពួកគ្រួសារដែលថាប្ដីៗទាំងអស់ហ្នឹង គេនាំយកទៅបាត់អស់ហើយនៅសល់តែប្រពន្ធទេ។

**ស៖** តើនៅក្នុងក្រុមគ្រួសារដែលមាននៅក្នុងបញ្ជីហ្នឹង មាននេះទេ មានអ្នកភូមិហ្នឹងទេ?

**ផ៖** អត់ទេ អត់មានទេ សុទ្ធតែមានអ្នកភៀសខ្លួនទាំងអស់។ អ្នកនៅភូមិនោះ គេនៅហ្នឹងទាំងអស់ គឺថាអ្នកដែលគេនាំចេញ មានតែពួកយើងនោះទេ។

**ស៖** សូមអរគុណ។ តើពេលដែលចេញនោះ អ្នកស្រីមានយកទ្រព្យសម្បត្តិទៅជាមួយខ្លួនដែរឬទេ ពេលដែលចេញពីភូមិកោះទឹកវិលនោះណា?

[១៥:២១:០៣]

**ផ៖** នៅពេលនោះ យើងលែងមានទ្រព្យសម្បត្តិអីអស់ហើយ។ គេដកហូតយកអស់ទៅហើយហ្នឹង។ សូម្បីតែឡានយើងហ្នឹង គេយកទៅហើយ ហើយយើងផ្ញើឡានហ្នឹងទៅលោក ផាន ហ្នឹង។ ប្រាប់ថា “បើអង្គការត្រូវការឡានហ្នឹង យកទៅ” ហើយយើងពេលនោះ យើងលែងមានអ្វីអស់ហើយ មានតែមុងភួយ ហើយមានតែកំសៀវមួយ ហើយនិងឆ្នាំងបាយមួយតែប៉ុណ្ណឹង។ ហើយយើងកាលនោះសឹងតែលែងមានអ្វីអស់ទៅហើយ ហើយនិងខោអាវពណ៌ខ្មៅតែប៉ុណ្ណឹង គឺថាមានតែពីរកំប្លេទេ គឺថាវា

អស់ ស្បែកជើងក៏អស់ដែរ នៅដើរតែជើងទទេ។ ហើយលុយ២លានដែលយើងរក្សាទុកនោះ។ ហើយ អ៊ីចឹងយើង យើង -- អ៊ីចឹងគឺថាលុយហ្នឹងទិញអង្ករបានដាំបាយ។ ២លានរៀលអស់មួយពេលហ្នឹង បណ្ដោយទៅ។

**ស៖** បាទ សូមអរគុណ។ តើអ្នកស្រីអាចរៀបរាប់ពីដំណាក់កាលផ្សេងៗ ពីការជម្លៀសអ្នកស្រី ពីភូមិកោះទឹកវិលទៅភូមិភ្នំលាបដែរឬទេ? ហើយនិងរៀបរាប់អំពីមធ្យោបាយដឹកជញ្ជូន ដែលគឺថាគេដឹក អ្នកស្រីតាមមធ្យោបាយអីដែរ?

[១៥:២២:៣៤]

**ឆ៖** នៅថ្ងៃបន្ទាប់ គេដាស់យើង គឺថាទាហានខ្មែរក្រហមដាស់យើង មានអាវុធកាន់។ នៅផ្លូវ នោះ យើងឃើញមានឡានយោធាដែលផលិតនៅប្រទេសចិន។ ឡានគេចាំយើង មុននឹងឡើងឡាននោះ គេធ្វើការបែងចែកម្ដងទៀត។ កាលណោះនៅមានកូនចៅបងថ្លៃខ្ញុំនៅឡើយ គេបានយករូបថតយើង សៀវភៅរូបថតហ្នឹង។ អ៊ីចឹងមានរូបថតឪពុកខ្ញុំជ្រុះ ហើយខ្ញុំរើសយកវិញ ហើយខ្ញុំយំ គេមិនព្រមឲ្យទេ គេ -- អូ៎! ពេលនោះ គេសុខចិត្តឲ្យរូបថតហ្នឹងខ្ញុំវិញ។ ហើយអ៊ីចឹងគេ -- យើងបោះអីវ៉ាន់មួយចំនួន ចោល ហើយយើងឡើងឡានទៅ។ ហើយយើងចាប់ផ្ដើមចេញដំណើរ ប្រហែលជាខ្ទង់ម៉ោងប្រាំបួនព្រឹក ហើយមានថ្ងៃ រាងក្ដៅបន្តិចហើយពេលនោះ។ ហើយកាលណោះ បើថាគឺថាត្រូវតែ -- បើថាជិះផ្លូវត្រង់ ថាចេញពីកោះទឹកវិលទៅភ្នំពេញនោះ គឺគេវាងទៅតាមខាងលិចនោះ ហើយចូលមកតាមពោធិចិនតុង វិញ។ អ៊ីចឹងមួយថ្ងៃវាស់ល្ងាចជិះឡានអត់មានសម្រាកអីទេ។

[១៥:២៤:០០]

ហើយម្នាក់ៗហ្នឹងចង់សម្រាក ប៉ុន្តែខ្មែរក្រហមមិនព្រមសម្រាកទេ។ យើងសួរគេថា "នាំយើង ទៅណា? គេមិនព្រមឆ្លើយ។ ហើយជិះកាត់ក្រុងនោះ ឃើញថាស្ងាត់ជ្រងំ។ ក្រោយមកទៀត ឃើញ មានចម្ការពោត ចម្ការអី។ ហើយខ្ញុំសង្ឃឹមថា គេឈប់ ប៉ុន្តែគេនៅតែអត់ឈប់ នៅបន្តទៅខាងទិសខាង ជើងទៀត។ ខ្ញុំជិះកាត់រោងចក្រស៊ូគីឡូរបស់ខ្ញុំ ហើយជិះរហូតដល់ពេលល្ងាចថ្ងៃលិចតែម្ដង។ ហើយ កាលណោះព្រះខែបានរះហើយ ហើយយើងមិនដឹងថា យើងឯណាទេ គិតតែជិះឡានទៅរហូត។

ហើយពេលដែលទៅដល់ហ្នឹង ដល់ពោធិ៍សាត់ យប់ទុំង។ ហើយគេដាក់ឲ្យយើងចុះនៅកន្លែង មួយដូចសត្វធាតុអ៊ីចឹង ហើយបាយអង្ករបន្តិចបន្តួច ហើយអត់មានបាយ អត់មានទឹក អត់ភ្លើង អត់មាន ទៀន។ គេប្រាប់យើងថា នោះ នៅកន្លែងនោះមានត្រពាំងមួយ។ យើងទៅត្រពាំងហ្នឹងទៅ ហើយងងឹត

ឈឹង ហើយកូនៗខ្ញុំនោះឃ្លាន ហើយនៅ -- ហើយរកទឹកមកដាំបាយឲ្យកូនញ៉ាំ។ មានមនុស្សឈឺនៅក្នុងឡានហ្នឹង ហើយស្លាប់នៅលើឡានហ្នឹងទៀត។ យើងហៅគាត់ថា "មិត្តៗ" កាលនោះពួកខ្មែរក្រហមនោះប្រាប់ថា -- អ៊ូ! មានមនុស្សឈឺហើយលើឡាន ហើយពួកគេនោះ គេអត់មានស្តាប់អីទេ។ គេៗថាអង្គការនឹងប្រាប់ថា អ្នកឯង នាំអ្នកឯងទៅណាហើយ កុំឆ្ងល់។ ហើយអ៊ីចឹងកាលនៅពោធិ៍សាត់នោះយើងចាំ៣ថ្ងៃនៅទីនោះ។ ហើយក្រោយមក ផុតពី៣ថ្ងៃហ្នឹងមក ខ្ញុំឃើញថាមានផ្លូវដែកមួយ ហើយមានកន្លែង -- យើងនៅរ៉ារទេះភ្លើងហ្នឹង អ៊ីចឹងឃើញគេដឹកយើងក្នុងទូរដឹកទំនិញចេញទៅ។

[១៥:២៥:៥៨]

**ស៖** សូមទោសអ្នកស្រី។ អ្នកស្រីបាននិយាយថា អត់មានទឹកទេនៅកន្លែងនោះ។ តើអ្នកស្រីអាចបញ្ជាក់បានទេ អត់មានទឹក?

**ឆ៖** អង្កាល់ហ្នឹងមានត្រពាំង ប៉ុន្តែត្រពាំងអត់ទឹក។ មិនមែនជាបឹងទេ គ្រាន់ -- អត់ៗមានទឹកទេ មានតែភក់។

**ស៖** អ៊ីចឹង ដូច្នេះយើងត្រូវតែបង្ខំផឹកទឹកហ្នឹងទៅ ទឹកភក់ហ្នឹងទៅ?

**ឆ៖** ត្រូវហើយ គឺថាយើងទឹកហ្នឹងមកដាំបាយ ហើយមកដាំនោះ។ ហើយនៅជិតហ្នឹងៗឃើញសុទ្ធតែមានអាចម៍ លាមកនៅជុំវិញត្រពាំងហ្នឹង។ កាលយប់នោះអត់ឃើញ ដល់ភ្លឺឡើងបានឃើញ។ ហើយនៅពេលដែលគេដាក់យើងក្នុងទូរទេះភ្លើងនោះ យើងត្រូវចេញថ្ងៃហ្នឹងៗ ហើយនៅពេលដែលយើងឡើងយប់ហើយ ឡើងលើរទេះភ្លើងហើយ គេថា "អ្ហ៎! មិនចេញទេថ្ងៃហ្នឹង" អ៊ីចឹងយើងនៅក្នុងទូហ្នឹងចាំទៅ កម្រើកខ្លួនមិនរួច អីមិនរួច ហើយដល់ថ្ងៃបន្ទាប់មកទៀតនោះ បានគេចេញដំណើរ។ អ៊ីចឹងយើងដេកអង្គុយ ឱបក្បាលជង្គង់នៅលើទូរទេះភ្លើងហ្នឹង។

[១៥:២៧:២៦]

**ស៖** តើការធ្វើដំណើរតាមរទេះភ្លើងហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** រយៈពេលនោះ ខ្ញុំមិនអាចឆ្លើយប្រាប់ទេ អ្វីដែលខ្ញុំអាចឆ្លើយប្រាប់បានគឺថាពេលធ្វើដំណើរនោះពេញមួយពេលធ្វើដំណើរនោះ តាមផ្លូវហ្នឹង បាត់ដំបង ស្វាយស៊ីសុផុន ឬតាមស្រុកភូមិអស់ហ្នឹង។ អ៊ីចឹង ព្រោះតាមទ្វារទូរហ្នឹងយើងអាចមើលឃើញដោយសារបិទមិនជិតទេ។ អ៊ីចឹងគេតាមកន្លែងមួយៗគេដាក់យើងចុះ ហើយគេយកប្រមូលក្រុមគ្រួសារដាក់ជាក្រុមៗ។ ឧទាហរណ៍ដូចជា ១០គ្រួសារអ៊ីចឹងជាមួយក្រុម។ ហើយពេលនុ៎ងហើយមានត្រាក់ទ័រមកនាំយកយើងទៅតាមតំបន់ភ្នំ ទៅភ្នំបី គឺថាភ្នំលាភ

ភ្នំត្រឡោក ភ្នំត្រយុង។ អ៊ីចឹងមាន -- អង្កាល់នោះមានមនុស្សចាស់បីនាក់ដែលស្លៀកពាក់ខ្មៅមកចាំយើង។ ឪពុក ឆេង ហើយពុកអីទៀតទេ អត់ចាំទេ។ ហើយខ្ញុំនោះមានពុក សែម មកយកយើង។ ឈ្មោះភូមិគាត់នោះ ឈ្មោះភូមិត្រឡោក ហើយនៅពេលនោះ ថាមានមនុស្សម្នាក់ពាក់វ៉ែនតា ហើយគាត់មកសួរថា សួរអ្នកនោះថា មនុស្សម្នាក់ "ត្រូវការវ៉ែនតាទេ? អត់ត្រូវការ"។ អ៊ីចឹងគាត់ ក៏យកវ៉ែនតាហ្នឹងកាច់ចោល។ អ៊ីចឹងលោកហ្នឹងបាត់វ៉ែនតាទៅ។ ហើយពេលនោះ ខ្ញុំថា -- ពេលនុំងហើយដែលខ្ញុំថាឥឡូវនេះឋាននរកចូលមកដល់ហើយ។ ហើយពេលដែលគេជម្លៀសយើងចេញពីភូមិមួយទៅភូមិមួយនោះ គេថា "អ៊ូ! ទៅកន្លែងនោះវាសប្បាយ វាល្អជាង ស្រួលជាងរហូត" ប៉ុន្តែមិន -- ហើយទៅដល់គេឲ្យយើងធ្វើការជាទម្ងន់រាល់ដង។

[១៥:២៩:៣៣]

**ស៖** អ្នកស្រី អាហ្វុងសូ ដើម្បីបញ្ចប់ទាក់ទងពីការជម្លៀសពីៗពោធិ៍សាត់ទៅដល់ស្វាយស៊ីសុផុន ហើយចេញពីនុំងទៅជិះត្រាក់ទ័រទៅដល់ភ្នំលាបនោះ តាមផ្លូវនោះ តើអ្នកស្រី--

**ឆ៖** ហើយបន្ទាប់មកទៀត យើងដើរ ដំណើរដោយថ្មើរជើងទៅដល់ភូមិ។

**ស៖** តាមដំណើរជាច្រើនដំណាក់នេះ តើអ្នកស្រីមានអារម្មណ៍ថា ការធ្វើដំណើរនេះសុទ្ធតែត្រូវបានរៀបចំមុនជាស្រេចហើយ តើអ្នកស្រីមានអារម្មណ៍អ៊ីចឹងទេ?

**ឆ៖** ចំពោះខ្ញុំគឺថា មានផែនការគេច្បាស់លាស់ គេរៀបចំច្បាស់លាស់ ហើយជារបៀបគេថាសម្លាប់យើងបន្តិចម្តងៗឲ្យទាំងវេទនា ឲ្យយើងវេទនា យើងនៅក្នុងប្រទេសមួយដែលថា ពីមុនមកប្រទេសហ្នឹងគេដឹកស្រូវចេញទៅលក់ឯក្រៅ ហើយក្រោយមកឥឡូវខ្វះស្រូវនៅក្នុង -- ហើយនិងក្រូចហើយនិងក្នុងរយៈពេល៤ឆ្នាំហ្នឹង ក្រូចក៏អត់មានញ៉ាំ ហើយថ្នាំក៏អត់មាន ហើយអ៊ីចឹង ហើយអត់មានអគ្គិសនី អត់មានភ្លើង។ អ៊ីចឹងហើយ៤ឆ្នាំ រស់ដូចនៅសម័យបុរេប្រវត្តិអ៊ីចឹង។ អ៊ីចឹងពន្យល់ហេតុផលហ្នឹងយ៉ាងម៉េចឥឡូវហ្នឹង។

[១៥:៣១:០៧]

**ស៖** តើនៅពេលជម្លៀសនោះ ខ្មែរក្រហមគេអ្នក ជាអ្នកអមយើងទេ គ្រប់គ្រងមើលលើយើងទេ?

**ឆ៖** ពីស្វាយស៊ីសុផុន -- (សូមទោស) ពីពោធិ៍សាត់ គឺថាជិះរទេះភ្លើងទៅ ហើយនិងពីស្វាយស៊ីសុផុនទៅភ្នំលាភ ពួកគេអមយើង។ គេមើលខុសត្រូវលើយើង។ ហើយពេលទៅដល់ភ្នំលាបនោះ គេ

ឲ្យប្រធានភូមិទាំងបីហ្នឹងមើលខុសត្រូវលើយើង។ ហើយនៅពេលដែលយើងទៅដល់ភូមិពូកសិន នៅកន្លែងនោះហើយដែលគេពន្យល់ គេប្រាប់យើងថា "យើងជាប្រជាជនថ្មី ហើយពួកអ្នកនៅភូមិហ្នឹងស្រាប់ជាប្រជាជនចាស់"។ ហើយពេលនោះហើយដែលគេឲ្យកូនខ្ញុំទាំងបីហ្នឹង ឲ្យយកសម្លៀកបំពាក់អីអ៊ីវ៉ាន់របស់គេ ដើរតាមគេព្រោះអង្គការត្រូវការពួកគេ។ ហើយខ្ញុំមិនដឹងថា គេយកទៅណាទេ។ អ៊ីចឹងគេដកហូតកូនខ្ញុំពីខ្ញុំអ៊ីចឹងទៅ តាំងពីថ្ងៃទី១ ម្ល៉េះ។ អ៊ីចឹងគេបំបែកកូនចៅខ្ញុំតាំងពីថ្ងៃនុ៎ងមក។ ខ្ញុំទុកកូនតូចជាងគេនៅខ្ញុំ កូនស្រីខ្ញុំហ្នឹង ហើយគេថា "កូនហ្នឹងឥតប្រយោជន៍ទេ ស៊ីបំផ្លាញតែអង្ករ" ហើយដល់អ៊ីចឹងអង្គការគេមិនត្រូវការមនុស្សអ៊ីចឹងទេ ហើយងាប់ក៏ងាប់ទៅគ្មានតម្លៃអីទេចំពោះអង្គការនោះ។ ហ្នឹងហើយ អានេះជាមេរៀនដែលយើងចាំនៅពេលនុ៎ង។

[១៥:៣២:៤៣]

**ស៖** បាទ ខ្ញុំអត់ទាន់ឮការបកប្រែ។ តើអ្នកស្រីអាចរៀបរាប់អំពីជីភាពនៅក្នុងភូមិនុ៎ង អាចថាអ្នកស្រីមានអាហារហូបចុកគ្រប់គ្រាន់ទេ? ហើយផ្នែកអនាម័យវិញ តើមានថ្នាំសង្កូវអីទេ?

**ឆ៖** ចាប់ពីពេលនោះមកអស់រលីងហើយ។ កាលនៅកោះទឹកវិលហ្នឹង គឺថាយើង -- ដូចពេលដែលគេសួរចម្លើយ ចូលទៅដល់កន្លែងនោះ គឺថាជាឋាននរកតែម្តង លែងមានទឹក ដើម្បីបានទឹកនោះទាល់តែទៅដើររាប់គីឡូម៉ែត ហើយទឹក -- មេឃក្តៅ ហើយយកមកដាំផឹក ហើយស្រូវក៏ខ្វះ យើងបានតែ យើងបានស្រូវហ្នឹងយកមកៗដាំបាយ យកមក ខ្ញុំមិនដឹងថាដាំបាយយ៉ាងម៉េចជាមួយស្រូវ។ អ៊ីចឹងកាលនោះ នោះលែងមានអ្វីទៀតហើយ ថ្នាំសង្កូវក៏លែងមានដែរ។ អ៊ីចឹងគឺថា ពេលនុ៎ងជាការចាប់ផ្តើមនៃឋាននរកហើយ។ ហើយយើងឈឺអីគ្មានអ្នកណាព្យាបាលយើងទេ ហើយចាប់ពីពេលនោះហើយដែលគេ -- យើងមានជំងឺគ្រុនចាញ់អីជាដើមហ្នឹង ហើមអីជាដើមហ្នឹង។ ហើយអត់មានពេទ្យមានអីទេ អត់មានថ្នាំអីទេ។

[១៥:៣៤:២៧]

**ស៖** នៅក្នុងពាក្យបណ្តឹងរបស់អ្នកស្រី។ អ្នកស្រីនិយាយថា អ្នកស្រីកើតជំងឺគ្រុនចាញ់ ហើយទាំងឈឺហ្នឹងគេបង្ខំឲ្យអ្នកស្រីធ្វើការ មែនដែរទេ? ពិតមែនដែរឬទេ? អ្នកស្រីអាចរៀបរាប់បានទេ?

**ឆ៖** ពិតណាស់ ចំពោះខ្មែរក្រហម គេហៅខ្ញុំ យាយបារាំង១ គេនៅអ៊ីចឹង។ គេដឹងឈ្មោះ ខ្ញុំគេហៅថា យាយ អាហ្វុងស្វ។ ហើយអ៊ីចឹងគេនិយាយរុករានខ្ញុំ ដៀមដាមខ្ញុំ ទោះបីពេលខ្ញុំឈឺជំងឺគ្រុនចាញ់ហ្នឹងក៏ដោយ គេមកទាត់ខ្ញុំ អីខ្ញុំ គេមកទាញកអាវខ្ញុំ ឲ្យខ្ញុំទៅធ្វើការ។ គេថាខ្ញុំពុត គេថាអ្នកឯងមិនឈឺទេ

ទៅធ្វើការ គេទាត់ខ្ញុំឲ្យទៅធ្វើការ។ ហើយពួកគេមិនដឹងថាឈឺហ្នឹងយ៉ាងម៉េចទេ? អ៊ីចឹងអាខ្មែរក្រហមហ្នឹង ខ្មែរក្រហមហ្នឹងកាលនោះដូចមានអាយុពី១៥ ឬក៏១៦ឆ្នាំទេ ហើយហ្នឹងមនុស្សមិនចេះអក្សរអីទេ ហើយម្នាក់ទុំងរុករានខ្ញុំរហូត។

**សៈ** អ្នកស្រីនិយាយថា ពួកគេហ្នឹងយាយីអ្នកស្រី ហើយមានអ្នកផ្សេងនៅជាមួយអ្នកស្រីហ្នឹង គេធ្វើបាបដែរទេ?

[១៥:៣៦:១០]

**ឆះ** ខ្ញុំមិនបានឃើញកូនខ្ញុំ ក្មួយខ្ញុំក៏អ៊ីចឹងដែរ ហើយពួកគេទាំងអស់ក៏ត្រូវបង្ខំចិត្តទៅ ធ្វើការដែរ ពេលឈឺនោះ ហើយអ្នកផ្សេងទៀតអាចចៀសរួចពីការប្រព្រឹត្តអ៊ីចឹងបាន ដោយសារមានមាស មានអីដូរនឹងគេទៅ ដូរយកបាយ យកត្រី អ៊ីចឹងពេលហ្នឹងហើយ គេលែងរុកកួនអីទៀតហើយ កាលណាយើងមានមាសមានអីដូរគេ។

**សៈ** នៅពេលដែលអ្នកស្រីឈឺ ហើយបងថ្លៃអ្នកស្រីហ្នឹងក៏ឈឺដែរ ហើយកាលណោះធ្វើយ៉ាងម៉េចដើម្បីព្យាបាលខ្លួន?

**ឆះ** អ្នកភូមិគេណែនាំឲ្យយើងផឹកថ្នាំស្ងោរ ដូចផាងស្វាយ ឬផាងខ្នុរអ៊ីចឹងទៅ យកទៅស្ងោរ ដូចស្លឹកគ្រៃជាដើមយកទៅស្ងោរផឹកទៅ វាពិតហើយផឹកទៅវាមិនទៅជាអីទេ។ អ៊ីចឹងបងស្រីខ្ញុំ ប្អូនថ្លៃខ្ញុំអត់ជា ស្លាប់ទៅ។ កាលនោះគេវាគ្មានការស្រង់ស្ថិតិ អត្តសញ្ញាណអីទេ កាលណាមានមនុស្សងាប់អ៊ីចឹងទៅ គេថា "អើ! អ៊ីចឹងចូរដែរវាអត់សូវអស់អង្ករ"។ កូនប្រុសខ្ញុំនោះក៏គេធ្វើបាបដែរ រហូតដល់ថ្ងៃនេះគាត់ នៅតែមានជំងឺ*ត្រូម៉ា*នៅឡើយទេ។ ខ្ញុំមិនអាចសុំឲ្យកូនខ្ញុំជួយផ្តល់សក្ខីកម្មបានទេ ពីព្រោះកូនខ្ញុំលែងចង់ឮអ្វីទាំងអស់នៅក្នុងសម័យនុំងហើយ ព្រោះថាកាលនោះគេវៃធ្វើបាបគ្នាខ្លាំងពេក។

[១៥:៣៨:២៤]

**សៈ** តើអ្នកស្រីដឹងទេ ហេតុអីបានជាគេវៃធ្វើបាបគាត់កាលនោះ?

**ឆះ** ដូចក្មេងដទៃទៀតដែរ គឺថានៅពេលមួយនោះទៅរកឧស អ៊ីចឹងទៅរកឧសដែលគេកាប់ហើយស្រេច អ៊ីចឹងទៅក៏គេវាយ គេចោទថាជាចោរជាអី លួចឧសគេ ហើយអ៊ីចឹងគេនាំគាត់ទៅកន្លៀតកោះមួយ នៅជ្រុងកោះមួយ ឲ្យគាត់កាប់ -- ឲ្យកូនខ្ញុំហ្នឹងធ្វើការកាប់កាស់អ៊ីចឹងអត់ឲ្យទឹកអត់ឲ្យអីផឹកទេ ហើយពេលត្រឡប់មកវិញ ខ្ញុំឃើញមានស្នាមកន្ទួលពេញខ្លួន បែកឈាម ប៉ុន្តែកូនខ្ញុំមិនបានប្រាប់ខ្ញុំថាគេធ្វើអីទេ។

**ស៖** អ្នកស្រីនិយាយថាប្អូនថ្លៃរបស់អ្នកស្រីស្លាប់ ដោយសារខ្វះការព្យាបាល។ អ៊ីចឹងជួយពន្យល់បន្តិចទៅមើល៍ តើមូលហេតុអ្វី?

**ឆ៖** រាល់ថ្ងៃ មនុស្សស្លាប់រាល់ថ្ងៃនៅក្នុងភូមិ ឲ្យតែរាល់ព្រឹកមានមនុស្សស្លាប់ហើយ។ គ្រួសារយើងមិនមែនជាគ្រួសារតែមួយដែលកាន់ទុក្ខ មានអ្នកផ្សេងទៀតស្លាប់រាល់ថ្ងៃ ដោយសារខ្វះថ្នាំព្យាបាល ឬក៏ដោយសារខ្វះអាហារ។ រកពាក្យអត់ឃើញ ហ្នឹងនិយាយថា ដោយខ្វះអាហារ ឬក៏ដោយជំងឺ។

**ស៖** អ្នកស្រីបាននិយាយអម្បាញ់មិញថា នៅក្នុងភូមិហ្នឹង ការបែងចែក ការរើសអើងរវាងប្រជាជនចាស់ ប្រជាជនថ្មីហ្នឹង មានលក្ខណៈធ្ងន់ធ្ងរណាស់។ តើអ្នកស្រីអាចរៀបរាប់អំពីផលវិបាកនៃការរើសអើងនេះបានដែរឬទេ?

[១៥:៤០:៥៥]

**ឆ៖** ការរើសអើងនេះធ្ងន់ធ្ងរ ដោយសារនៅក្នុងការចែកស្បៀង -- ចែកអង្ករចែកបាយ។ កាលណាយើងបានមួយភាគ គេបានពីរភាគ ស្រីៗមិនធ្វើការទេ ប្រជាជនចាស់នោះ ហើយគេមានសិទ្ធិមានកូន -- យកកូនយកអីបាន ហើយកាលនោះ យើងមាន -- បើថាគេមានត្រី យើងមានត្រឹមតែអំបិលទេ។ អ៊ីចឹងយើងញ៉ាំតែបបរ យើងមានសិទ្ធិទទួលបានអាហារតែពីរពេលទេ ក្នុង១ថ្ងៃ ហើយមានអង្ករមួយវែកៗ ហើយ២ថ្ងៃហ្នឹង -- ក្រៅពីហ្នឹងយើងរើសចាប់អីបាន យកហ្នឹងទៅដូចជា សូម្បីតែកន្លាតមិនសល់ ចាប់ទាំងអស់ កណ្តូបអីៗ ចាប់។ អ៊ីចឹងយើងឈ្លោះគ្នាជាមួយឆ្កែប្រជាជនចាស់ទៀតផង ព្រោះអាឆ្កែហ្នឹងមានម្ហូបអាហារគ្រាន់បើជាងយើង។ អ៊ីចឹងបើអត់មានភាពស្មើគ្នានៃការប្រព្រឹត្តមកលើប្រជាជនចាស់ ប្រជាជនថ្មីទេ។

**ស៖** លក្ខខណ្ឌជីវិតដែលអ្នកស្រីទទួលរងនោះ តើអ្នកស្រីមានបាត់បង់សមាជិកគ្រួសារអីទេ?

**ឆ៖** បងថ្លៃខ្ញុំស្លាប់--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! មានការជំទាស់តវ៉ាពីមេធាវីការពារក្តី។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ក្រែងលោខ្ញុំខុស ខ្ញុំមិនដឹងថា សាក្សីរូបនេះត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មពេញមួយសំណុំរឿង០០២ នេះតែម្តង ឬតែ០០២/០១ នេះទេ។

បើសិនជាអនុញ្ញាតឲ្យផ្តល់សក្ខីកម្មពេញមួយសំណុំរឿងនេះតែម្តង ក្នុងករណីពិសេសណាមួយនោះ ខ្ញុំបាទមិនមានការជំទាស់ទេ ប៉ុន្តែបើសិនជាអនុញ្ញាតឲ្យតែផ្តល់សក្ខីកម្មលើសំណុំរឿង០០២/០១ ទេ ខ្ញុំគិតថា អង្គហេតុដែលកំពុងលើកចេញនេះ វាចាកចេញពីវិសាលភាពនៃសំណុំរឿងយើងហើយ។ នេះមួយ។ នេះពីរ អំមិញលោកមេធាវីស្នើសុំឲ្យលោកស្រី អះអាងពីការបាត់បង់សមាជិកគ្រួសារ ខ្ញុំគិតថា នេះប្រហែលជាចូលទៅដល់ក្នុងសម្តីចុងក្រោយរបស់សាក្សី ក្នុងការថ្លែងពីទុក្ខសោកនោះទេ។

សូមអរគុណ។

[១៥:៤៣:៤៤]

**អ្នកបកប្រែ៖**

លោកប្រធាន ពីសំណាក់អ្នកបកប្រែ សូមឲ្យលោកមេធាវីគាត់និយាយផ្អាកបន្តិចសិន ព្រោះអីខាងបារាំងនៅស្រុកបារាំងនោះក៏និយាយលឿន គាត់ក៏និយាយលឿន ចប់ភ្លាមឆ្លើយភ្លាមអ្នកបកប្រែតាមអត់ទាន់លោកប្រធាន សូមឲ្យគាត់បន្ថយបន្តិច។

**លោក អេម៉ានូអ៊ែល ហ្សាកូមី៖**

បាទលោកប្រធាន នេះមិនឲ្យរៀបរាប់អង្គហេតុទាំងអស់ទេ គ្រាន់តែនិយាយពីផលវិបាកនៃការជម្លៀសដោយបង្ខំប៉ុណ្ណឹងទេ អ្នកស្រី អាហ្សុងសូ បានប្រាប់ថា លក្ខខណ្ឌជីវិត ឬក៏លក្ខខណ្ឌអនាម័យស្បៀងអាហារនៅក្នុងភូមិនោះមានការប៉ះពាល់លើសមាជិកក្រុមគ្រួសារគាត់។ ដូច្នេះ ខ្ញុំគ្រាន់តែសុំឲ្យគាត់បញ្ជាក់ពីផលវិបាក ហើយបើយើងអាចពង្រីកប្រធានបទនេះបាន បើសិនជាអនុញ្ញាត។ អ៊ីចឹង ខ្ញុំគ្រាន់តែសុំអំពី ឲ្យអ្នកស្រី អាហ្សុងសូ រៀបរាប់អំពីការប៉ះពាល់ទៅលើក្រុមគ្រួសារគាត់តែប៉ុណ្ណឹងទេ។

**លោកស្រី ដេនីស អាហ្សុងសូ៖**

**ឆ៖** នៅក្នុងភូមិហ្នឹងគឺថា ប្អូនថ្លៃស្រីរបស់ខ្ញុំគាត់ឈឺមុនគេ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយលោកស្រី! អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់ភាគីជាមុនសិន។

[១៥:៤៥:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៨:៣១]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីឲ្យលោក អៀង សារី នៅលើសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិហ្នឹងគឺមិនមានមូលដ្ឋានត្រឹមត្រូវទេ។ បញ្ហាដែលកើតមានឡើងគឺវាក្នុងអំឡុងពេលជិត កៀកជាមួយនឹងផលបច្ច័យដែលកើតមានឡើងដោយ -- កើតឡើងដោយការជម្លៀសឡើងទី២។ ដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលសួរលោកស្រីអម្បាញ់មិញនេះ។ ប៉ុន្តែដោយសារឥឡូវនេះ យើងអស់ ឌី.វី.ឌី ហើយ។ អ៊ីចឹងបង្អង់ ផ្អាកបន្តិច ដើម្បីឲ្យអ្នកបច្ចេកទេសប្ដូរ ឌី.វី.ឌី ថ្មីជាមុនសិន។

[១៥:៤៩:២១]

*(សម្រាករយៈពេលខ្លី)*

[១៥:៤៩:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រី អាហ្វុងសូ ឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ!

**លោកស្រី ដេនីស អាហ្វុងសូ៖**

**ឆ៖** អម្បាញ់មិញនេះខ្ញុំនិយាយថា នៅពេលនុ៎ង ខ្ញុំបាត់បង់ប្អូនថ្លៃស្រីរបស់ខ្ញុំ បន្ទាប់មកកូនស្រីរបស់ខ្ញុំដែលស្លាប់ដោយអត់អាហារ ព្រោះនៅពេលព្រឹកដែលគ្នាស្លាប់នោះ អ្វីដែលគ្នាសុំនោះគឺថា "ម៉ាក់ៗ ខ្ញុំសូមបាយមួយកូនចាន ហើយខ្ញុំអត់មានបាយឲ្យ"។ អ៊ីចឹង ហើយ១ម៉ោងក្រោយមក វាស្លាប់។ ហើយបន្ទាប់មកទៀត មានក្មួយខ្ញុំមួយទៀតស្លាប់ដែរ។ ហើយថ្ងៃនោះ១ពីរនាក់ហ្នឹងស្លាប់ ខ្ញុំកប់ទាំងពីរនាក់ ហើយ១អាទិត្យក្រោយមកទៀតនោះថា ក្មួយខ្ញុំមួយទៀត ស្លាប់ដោយអស់កម្លាំង និងអស់រដូវអស់អីផង អាយុ១៨ឆ្នាំ ល្អិតល្អៃ ស្លាប់ទៅ។ ហើយក្មួយមួយទៀតស្លាប់ដែរ។ អ៊ីចឹងខ្ញុំបាត់បងប្អូនទាំងអស់ហ្នឹង។ ហើយក្មួយប្រុសមួយទៀត ខ្មែរក្រហមសម្លាប់ដោយសារ គេទៅលួចៗអាហារ ទៅលួចអាហារប្រពន្ធប្រធានភូមិ អ៊ីចឹងគេក៏សម្លាប់ទៅ។

[១៥:៥១:៥០]

**ស៖** សូមអរគុណអ្នកស្រី អាហ្វុងសូ ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងព្រឹត្តិការណ៍ទាំង

អស់នេះ ហើយខ្ញុំសូមដកស្រង់កំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីកាលពីខែកញ្ញា ឆ្នាំ២០០៩ ដើម្បីជា -- កំណត់ហេតុប្រតិចារឹកគឺថាឯកសារ D199/15 ទំព័រទី៧។ ERN 00342184 ជាភាសាបារាំង, 00346936 ជាភាសាអង់គ្លេស, និង 00349120 ជាភាសាខ្មែរ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ អ្នកស្រីបានឆ្លើយថា "អង្គការខ្មែរក្រហម មានរចនាសម្ព័ន្ធច្បាស់លាស់ ហើយការសម្រេចទាំងអស់នោះសុទ្ធតែសេចក្តីសម្រេចចេញពីអង្គការ"។ ហើយអ្នកស្រីក៏បានឆ្លើយផងដែរថា -- អ្នកស្រីសូមបញ្ឈប់ដកស្រង់សិន ហើយខ្ញុំនឹងទុកឲ្យអ្នកស្រីឆ្លើយ និងពន្យល់នៅពេលក្រោយ។ អ្នកស្រីក៏បាននិយាយផងដែរថា "ខ្ញុំគិតថា អ្នកដឹកនាំខ្មែរក្រហមចង់កម្ទេចប្រជាជនថ្មី។ អ្វីដែលគេហៅថាប្រជាជន? ដោយទុកឲ្យយើងរស់ទាំង ដោយអត់អាហារ ហើយនិងដោយជំងឺ ស្លាប់ដោយជំងឺ និងអត់អាហារ"។ តើអ្នកស្រីអាចពន្យល់បានទេ ហេតុអ្វីក៏អ្នកស្រីទាញការសន្និដ្ឋានយ៉ាងដូច្នេះ?

[១៥:៥៣:៤០]

**ឆ៖** នៅឆ្នាំ២០០៩ ខ្ញុំបាននិយាយអ៊ីចឹង ហើយឥឡូវក៏ខ្ញុំនិយាយអ៊ីចឹងដែរ។ នៅឆ្នាំ១៩៧៩ ក៏ខ្ញុំគិតអ៊ីចឹងដែរ ឥឡូវខ្ញុំរក្សាចម្លើយខ្ញុំ។ ខ្ញុំនៅតែគិតថា អង្គការចង់កម្ទេចវណ្ណៈសង្គម ដូចបញ្ញវន្ត។ នេះគឺជាមានការគ្រោងទុក ហើយដោយចេតនា ទុកឲ្យគេស្លាប់ដោយអត់អាហារ ពីព្រោះថារាល់ -- ក្រោយរដូវចម្រូតនោះ គេមកដឹកស្រូវចេញទៅទាំងអស់ ហើយទុកតែបន្តិចបំផុត ទុកឲ្យយើងហូបតែពីរកូនចានចង្កឹះ១ថ្ងៃ ហើយគេយកទៅទាំងអស់។ អ៊ីចឹងហើយ -- អ៊ីចឹងរាល់ៗដង គេធ្វើយ៉ាងអ៊ីចឹង។ ហើយនៅពេលដែលរដូវច្រូតហ្នឹង គេឲ្យយើងរាងច្រើនបន្តិចទៅ ឲ្យយើងមានកម្លាំងច្រូតកាត់ ហើយពេលច្រូតកាត់ហើយហ្នឹង គេៗដឹកស្រូវទៅទាំងអស់ ហើយអ៊ីចឹងទុកតែបន្តិចបន្តួចឲ្យយើង។ អ៊ីចឹងយើងពេលដែលជិតច្រូតហើយហ្នឹង មករបបអាហារហ្នឹងបបរដដែល។ អ៊ីចឹងខ្ញុំសន្និដ្ឋានថា នេះវាដោយចេតនា ហើយការដែលមិនឲ្យថ្នាំ មិនឲ្យអាហារនេះ នេះក៏ជាចេតនាដែរ គឺជាការរៀប ការរៀបចំដែលគ្រោងទុកជាមុន ហើយខ្ញុំគិតថា គ្រោងទុកដោយហ្មត់ចត់ទៀតផង។

[១៥:៥៥:០៩]

**ស៖** នៅក្នុងចម្លើយរបស់អ្នកស្រីដដែលនុ៎ង អ្នកស្រីថា សុទ្ធតែជាសេចក្តីសម្រេចចេញពីអង្គការ តើអ្នកស្រីអាចផ្តល់ឧទាហរណ៍មួយ ឬពីរបានដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចផ្តល់ឧទាហរណ៍ជាក់លាក់ទេ។ ក៏ប៉ុន្តែរាល់ដងដែលគេសន្យាយើង គេសន្យាជួសមុខឲ្យអង្គការ។ គេនិយាយថា ឥឡូវនេះថា បងប្អូនទាំងអស់គ្នាធ្វើឲ្យខ្លាំងជាងមុនទៅ អង្គការសុំឲ្យ

ធ្វើការខ្លាំងជាងមុន។ បើសិនជាយើងអាចដាំស្រូវបានបីដងក្នុងមួយឆ្នាំនោះ គឺជាការល្អ ហើយធ្វើលើកទំនប់អីជាដើម។ ហើយគេនិយាយរាល់ដងថា អង្គការសម្រេចថា ទំនប់នេះ លើកទំនប់ អ៊ីចឹងគេប្រាប់ថា អង្គការប្រាប់ថា លើកទំនប់ហ្នឹង ទំនប់ឈ្មោះទំនប់មេម៉ាយ។ ព្រោះថា ពេលគេសង់ទំនប់នោះសុទ្ធតែស្រីមេម៉ាយទាំងអស់ ហើយខ្ញុំក៏ចូលរួមលើកទំនប់ហ្នឹងដែរ។ ទំនប់នោះឈ្មោះថា “ទំនប់មេម៉ាយ”។

[១៥:៥៦:៣២]

**លោក អេម៉ានូអ៊ែល ហ្សាកូមី៖**

បាទ សូមអរគុណអ្នកស្រី អាហ្សុងសូ។ លោកប្រធានខ្ញុំអស់សំណួរហើយ។ បាទ ឥឡូវនេះខ្ញុំសូមផ្តល់វេទិកាទៅខាងសហព្រះរាជអាជ្ញាម្តងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោកស្រី អាហ្សុងសូ ដែលបានធ្វើសក្ខីកម្មតាំងពីប្រទេសបារាំង។ ដូច្នេះសូមថ្លែងអំណរគុណលោកស្រីច្រើនណាស់។ យើងមានពេលនៅសល់៣០នាទីទៀតដើម្បីចោទសួរលោកស្រី សំណួរទាំងអស់នេះសុទ្ធតែជាសំណួរបន្តទេ ពីព្រោះថា លោកស្រីបានរៀបរាប់អំពីស្ថានការណ៍ដែលបានកើតឡើងយ៉ាងលម្អិតរួចមកហើយ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីពេលជម្លៀសចេញពីទីក្រុងភ្នំពេញ គឺប៉ុន្មានថ្ងៃក្រោយពេលជម្លៀសចេញពីទីក្រុងភ្នំពេញ។ លោកស្រីថា មានការទម្លាក់គ្រាប់បែក មានការបាញ់រ៉ូក្កែតគ្រាប់រ៉ូក្កែត មានការវាយប្រយុទ្ធគ្នា។ តើនៅពេលនោះ មានអ្នកជំងឺ អ្នករបួសច្រើនទេ នៅតាមមន្ទីរពេទ្យនៅទីក្រុងភ្នំពេញនោះ នៅសម័យនោះ?

**លោកស្រី ដេនីស អាហ្សុងសូ៖**

**ឆ៖** ពិតណាស់គឺជារឿងរាល់ថ្ងៃ មានអ្នករបួស មានទាហានដែលមកពីសមរភូមិ ទាហានលន់ នល់ ដែលរងរបួស។ មន្ទីរពេទ្យគឺថា មានអ្នកជំងឺហៀរហូរពេញទាំងអស់។ ខ្ញុំ ខ្ញុំស្គាល់ស្ថានភាព

ច្បាស់ណាស់ ពីព្រោះថា ខ្ញុំស្គាល់ប្រធានខាងផ្នែកសោធននិវត្សយោធាច្បាស់ណាស់ ហើយពួកគេបានប្រាប់ខ្ញុំអំពីហេតុការណ៍ដែលបានកើតឡើងនៅសមរភូមិ។

**ស៖** លោកស្រីថា លោកស្រីរស់នៅជិតពេទ្យចិន ហើយឃើញអ្នកជំងឺចេញពីពេទ្យចិន បើតាមលោកស្រីដឹង តើអ្នកជំងឺ ឬក៏អ្នករបួសទាំងអស់នុំងក៏ត្រូវគេជម្លៀសចេញពីពេទ្យឲ្យអស់ដែរមែនទេ?

[១៥:៥៨:៤៥]

**ឆ៖** ពិតណាស់ អ្នកជំងឺទាំងអស់ត្រូវតែជម្លៀសចេញពីមន្ទីរពេទ្យ គឺថាគ្មានអ្នកណាអាចនៅបានទេ ត្រូវតែចេញឲ្យអស់។ នៅពេលដែលយើងនៅជិតពេទ្យនោះ យើងឃើញអ្នកជំងឺចេញបន្តកន្ទុយគ្នា ចេញអស់រលីងពីមន្ទីរពេទ្យ គ្មានសល់ម្នាក់ទេ។

**ស៖** សូមអរគុណ។ កាលនៅថ្ងៃទី១៧ មេសា លោកស្រីថា ប្រជាជនបានស្រែកអបអរទទួលខ្មែរក្រហមយ៉ាងពុះកញ្ជ្រោល ចុះខ្មែរក្រហមធ្វើយ៉ាងម៉េច -- មានប្រតិកម្មយ៉ាងម៉េចដែរចំពោះប្រជាជននោះ ពួកគេរីករាយ ចែករំលែកសេចក្ដីសប្បាយជាមួយប្រជាជនដែរ ឬក៏ពួកគេមានឥរិយាបថផ្សេងចំពោះប្រជាជនដែលហ៊ោកញ្ជៀវអបអរសាទរនោះ?

[១៥:៥៩:៣០]

**ឆ៖** ពួកគេមើលមកប្រជាជនដោយការមើលងាយបំផុត ពួកគេដូចជាមិនចង់នៅក្បែរប្រជាជនអ៊ីចឹង។ ដូចខ្ញុំបានប្រាប់ហើយ ពួកគេមិនញញឹម សូម្បីតែញញឹមដាក់យើងក៏មិនញញឹមដែរ។ គឺថាមើលមកដោយមើលងាយតែម្ដង អាការក្រឡេកមើលនោះ។

**ស៖** សូមអរគុណ។ នៅពេលដែលគេចេញបញ្ជាឲ្យជម្លៀសចេញពីទីក្រុងភ្នំពេញ តើលោកស្រីឮខ្មែរក្រហមស្រែកបញ្ជានៅតាមផ្លូវ ឬក៏មានខ្មែរក្រហមខ្លះមកផ្ទះលោកស្រី ហើយស្រែកបញ្ជាឲ្យលោកស្រីចេញពីផ្ទះទេ។

**ឆ៖** ពួកវាដើរតាមផ្លូវ ហើយស្រែកបញ្ជាឲ្យប្រជាជនចេញ ហើយមានអ្នកខ្លះនោះទៅតាមផ្ទះនីមួយៗ ហើយបញ្ជាស្រែកឲ្យយើងចេញពីផ្ទះជាបន្ទាន់។

[១៦:០០:៣១]

**ស៖** អម្បាញ់មិញនេះ លោកស្រីបញ្ជាក់ថា បញ្ជានោះគឺឲ្យចេញពីទីក្រុងតែ ២, ៣ថ្ងៃនេះ ខ្លាចអាមេរិកទម្លាក់គ្រាប់បែកងាប់។ តើលោកស្រីធ្លាប់ឮខ្មែរក្រហមនិយាយនៅថ្ងៃទី១៨ មេសា នៅពេលព្រឹក ថាពួកគេត្រូវការបោសសម្អាតទីក្រុងឲ្យមានសណ្ដាប់ធ្នាប់របៀបរៀបរយឡើងវិញទេ?

**ឆ៖** លេសដែលឲ្យយើងចេញពីផ្ទះនោះគឺថា អាមេរិកទម្លាក់គ្រាប់បែក គឺគេប្រាប់ថា អាមេរិកនឹងទម្លាក់គ្រាប់បែកទីក្រុង។ ដូច្នេះ គេឲ្យយើងចេញ ដើម្បីឲ្យមានសុវត្ថិភាពត្រូវចេញទៅតាមស្រុកស្រែនោះ។

**ស៖** សូមអរគុណ។ លោកស្រីបានឆ្លើយថា ខ្មែរក្រហមមានកាន់កាំភ្លើងនៅពេលដែលស្រែកបញ្ជាឲ្យចេញពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែគេមិនភ្ជង់កាំភ្លើងទេ គ្រាន់តែគេកាន់តែប៉ុណ្ណោះ។ ទោះបីជាពួកវាមិនបានគំរាមកំហែងលោកស្រីក៏ដោយ នៅពេលដែលគេចេញបញ្ជាឲ្យចេញនោះ តើលោកស្រីអាចយល់ថា លោកស្រីអាចមានជម្រើសទេ ថាចង់ចេញក៏បាន ឬមិនចេញក៏បានស្រេចចិត្តនោះ?

**ឆ៖** យើងគ្មានជម្រើសទេ បញ្ជាគឺច្បាស់ណាស់ ត្រូវតែចេញ គេមិនឲ្យយើងជ្រើសរើសថា ចង់ចេញក៏ចេញ ចង់ទៅក៏ទៅ ស្រេចចិត្តទេ។ គឺថា ត្រូវតែចេញជាដាច់ខាត គឺដាច់អហង្កាតែម្តង ត្រូវតែចាកចេញភ្លាម។

[១៦:០២:០៧]

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកស្រី នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺក្នុងឯកសារ D199/15 នៅទំព័រ៣ គ្រប់ភាសា (សូមទោស) គឺទំព័រ៣ ជាភាសាបារាំង, ៣ ជាភាសាខ្មែរ(ស៊ុក), ៦ ជាភាសាខ្មែរ, គឺERN 00349109។ លោកស្រីបានឆ្លើយថា "នៅពេលចាកចេញពីទីក្រុងភ្នំពេញដោយជិះរថយន្តនោះ ឡាននោះគឺថាតូចពេកមិនអាចជិះអស់បានទាំងអស់គ្នាទេ ហើយប្អូនថ្លៃរបស់លោកស្រីនោះ ក៏តាមលោកស្រីពីក្រោយដោយជិះកង់"។ លោកស្រីអាចបញ្ជាក់អំពីអ្វីដែលបានកើតឡើង អំពីប្អូនថ្លៃរបស់លោកស្រីនៅថ្ងៃនោះ តើលោកស្រីមានបានឮដំណឹងរបស់គាត់ទេ តាំងពីពេលនោះមក?

**ឆ៖** យើងអត់បានទទួលដំណឹងទេ យើងបាត់គេតែម្តង ពីព្រោះថាទាហាននៅលើដំបូលផ្ទះនោះវាបញ្ជាឲ្យយើងចេញភ្លាមតែម្តង។ ហើយឡានចេញទៅលឿនណាស់ ហើយប្អូនថ្លៃរបស់ខ្ញុំដែលជិះកង់នោះមានសំបុកមាន់ មានអីផង ហើយយើងបាត់លែងឃើញប្អូនហ្នឹងតែម្តង ហើយតាំងពីពេលនោះមកខ្ញុំអត់ដែលមានដំណឹងពីប្អូនថ្លៃរបស់ខ្ញុំហ្នឹងទេ។ ហើយក្មេងហ្នឹងវាដូចជារាងឡប់ៗផង ដូចមិនសូវគ្រប់ទឹកទេ ប្អូនថ្លៃប្រុសខ្ញុំហ្នឹង។

[១៦:០៣:៤៤]

**ស៖** អម្បាញ់មិញនេះ លោកស្រីបាននិយាយអំពីមនុស្សផ្សេងៗទៀត ដែលងាយរងគ្រោះដូចជា

គេជម្លៀសចេញពីមន្ទីរពេទ្យ។ តើខ្មែរក្រហមមានចាត់វិធានការ ដើម្បីធានាថាប្រជាជនងាយរងគ្រោះនោះអាចត្រូវរស់បាន នៅពេលដែលជម្លៀសចេញក្រោមកំដៅថ្ងៃក្ដៅហែង មានការរៀបចំការដឹកជញ្ជូនមាន មានទឹក មានអាហារ មានថ្នាំសង្កូវចែកជូនដល់ប្រជាជនដែលងាយរងគ្រោះដែរឬទេ?

**ផ៖** អត់ទេលោកសហព្រះរាជអាជ្ញា។ មិនមានការជំនួយពីទាហានខ្មែរក្រហមទេ ខ្មែរក្រហមមិនរវល់អីទាំងអស់ គឺមិនមានជួយទេ គ្មានការជួយណាមួយពីខ្មែរក្រហមឡើយ។ ដូចដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញហើយ សក់អ្នកណាក្បាលអ្នកហ្នឹង គ្មានអ្នកណាជួយយើងទេ គ្មានអ្នកណាជួយអ្នកណាទេ។

**ស៖** ប្រសិនបើសក់អ្នកណាក្បាលអ្នកហ្នឹង នៅពេលដែលចាកចេញពីក្រុងក្នុងឡានរបស់លោកស្រីនោះ លោកស្រីមានឃើញអ្នកមិនអាចដើរបាន ហើយលែងដើរទៅមុខ ហើយសុខចិត្តនៅតាមផ្លូវ ពីព្រោះថា ពួកគេមិនអាចតាមដើរទៅមុខបានទៀតទេនោះ មានឃើញទេ?

[១៦:០៥:០០]

**ផ៖** មានច្រើនណាស់ មានមនុស្សចាស់ច្រើនពិបាកដើរត្រដរៗ ត្រដេវត្រដរដើរមិនរួច ហើយចំពោះយើង យើងមិនអាចឈប់ដើម្បីជួយពួកគាត់ទាំងអស់នោះបានទេ។ ក៏ប៉ុន្តែមានៗអ្នកលំបាកក្នុងការដើរ ហើយពេលនោះគឺថា ក្ដៅណាស់ អាកាសធាតុក្ដៅហែង ហើយយើងក៏មិនដឹងថា យើងទៅណាទៀត។ ដូច្នេះ វាជារឿងមួយគួរឲ្យសោកសង្រេងណាស់។

**ស៖** អម្បាញ់មិញលោកស្រីនិយាយថា លោកឃើញសពនៅចំការមន គឺជាសពរបស់ទាហានលន់ នល់។ ក្រោយពេលលោកស្រីចាកចេញពីភ្នំពេញទៅតាខ្មៅ ហើយបន្ទាប់មកទៅដល់កោះទឹកវិលតើលោកស្រីមានឃើញសពផ្សេងៗទៀតទេ នៅតាមផ្លូវ ពីតាខ្មៅទៅកោះទឹកវិលនោះ? ហើយលោកស្រីអាចដឹងទេថាសពហ្នឹងជាសពអ្នកណាខ្លះនៅតាមផ្លូវនោះ?

**ផ៖** សពដំបូងដែលខ្ញុំឃើញនោះ គឺពិតជាយោធាហើយ ព្រោះថាស្លៀកឯកសណ្ឋានយោធាលន់ នល់ ក៏ប៉ុន្តែតាមផ្លូវក្រោយមកទៀតនោះ មានអ្នកផ្សេងៗទៀត សុទ្ធសឹងតែជាជនស៊ីវិល។ ហើយយើងឃើញមានសាកសពច្រើនណាស់នៅតាមផ្លូវ ក៏ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់បានឈប់ទេ ខ្ញុំអត់បានទៅបែរទៅបង្វែរមើលថា ពួកហ្នឹងយ៉ាងម៉េចៗទេ ព្រោះថាអត់មានអាចឈប់បានទេ គ្រាន់តែខ្ញុំឃើញសពនៅតាមផ្លូវ។

[១៦:០៦:៤០]

**សៈ** ហើយសាកសពទាំងអស់នោះ គឺអត់មានឯកសណ្ឋានទេ មែនទេ ពាក់ស៊ីវិល?

**ឆៈ** ចាស១ ចម្លើយពិតមែនហើយ សុទ្ធតែជាជនស៊ីវិល។

**សៈ** សូមអរគុណលោកស្រី។ នៅពេលដែលលោកស្រីទៅដល់កោះទឹកវិល នៅថ្ងៃទី១៩ ខែមេសា លោកស្រីឆ្លើយថា បន្ទាប់មកលោកស្រីទៅលើកោះទឹកវិលហ្នឹង។ នៅថ្ងៃទី២០ មុននឹងគេបញ្ជូនលោកស្រីទៅកោះនោះ តើគេមានសួរលោកស្រីថា ចង់ទៅ ឬមិនចង់ទៅអីទេ?

**ឆៈ** គឺអត់ទេ គ្មានទាល់តែសោះតែម្ដង លោកសហព្រះរាជអាជ្ញា គេមិនសួរទេ គេមិនខ្វល់ថាយើងចង់មិនចង់ទេ មេភូមិមកដល់ មកមួយក្រុម ហើយពួកគេជ្រើសរើសយើងតែម្ដង ចង្អុលដៃយកតែម្ដង នេះៗអានេះអានោះទៅ អានេះអ្នកនេះនៅម៉្លុំ អ្នកនេះឡើងឡាន គឺអត់មានឲ្យយើងជ្រើសរើសអីទេ គឺចង្អុលដាក់ៗ ចាប់យកទៅតែម្ដង។

**សៈ** ដូច្នេះ សរុបទៅនៅពេលដែលលោកស្រីទៅដល់លើកោះនោះ ហើយនិងប៉ុន្មានថ្ងៃក្រោយមកនោះ តើមានប្រហែលជាប៉ុន្មានគ្រួសារដែរ ដែលគេជម្លៀសពីភ្នំពេញ ហើយនិងពីទីក្រុងផ្សេងទៀតនោះ ត្រូវបានគេជ្រើសរើសយកឲ្យទៅរស់នៅលើកោះទឹកវិលនោះ?

[១៦:០៨:០២]

**ឆៈ** ប្រសិនបើខ្ញុំចងចាំមិនច្រឡំនោះទេ គឺប្រហែលជាគ្រួសារដប់ប្លាយជាង ក៏ប៉ុន្តែខ្ញុំមិនមែនជាអ្នកគណនេយ្យទេ ខ្ញុំអត់អាចគិតលេខឲ្យបានច្បាស់លាស់ទេ គឺរឿងរ៉ាវវាកើតឡើងរាប់សិបឆ្នាំមក ហើយខ្ញុំមិនអាចចាំទេ។ ខ្ញុំអត់ចាំទេ ខ្ញុំប្រហាក់ប្រហែលជាងដប់គ្រួសារប្លាយ។

**សៈ** បាទសូមអរគុណ។ នៅថ្ងៃទី២០ មេសា លោកស្រីទៅដល់កោះ អ៊ីចឹងមានន័យថា បីថ្ងៃក្រោយពីជម្លៀស បីថ្ងៃក្រោយពីការជម្លៀស លោកស្រីទៅដល់។ តើនៅពេលណាមួយនោះ ទាហានខ្មែរក្រហម ឬក៏មន្ត្រីខ្មែរក្រហមនោះមានបានប្រាប់ថា ហេតុអ្វីបានជាលោកស្រីមិនអាចត្រឡប់ទៅទីក្រុងវិញបានក្រោយរយៈពេលបីថ្ងៃ មិនអាចចូលទៅក្នុងទីក្រុងភ្នំពេញវិញបាននោះ មានគេមានពន្យល់មូលហេតុអ្វីទេ?

**ឆៈ** អត់ទេ គេមិននិយាយអ្វីទាល់តែសោះ បីថ្ងៃក្រោយមកយើងអត់មានបានទទួលពត៌មានអីទេ គឺស្ងាត់ជ្រាបតែម្ដង។ មេភូមិដែលឈ្មោះថា លោក ផាន នោះ ក៏មិនបានប្រាប់ពត៌មានលម្អិតអីដែរ ហើយមួយសប្ដាហ៍ក្រោយមក គេកោះឲ្យយើងទៅប្រជុំនៅក្នុងវត្តមួយ ហើយដែលក្នុងវត្តនោះគេនិយាយអំពីជ័យជម្នះ ហើយក៏គេនិយាយអំពីជោគវាសនាពិតប្រាកដរបស់ពួកយើង។

[១៦:០៩:៣០]

**ស៖** ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនៅវត្តព្រៃទូត អម្បាញ់មិញនោះ លោកស្រីបាននិយាយអំពីឈ្មោះមួយចំនួន ដូចជា តាឆេន, តាម៉ុក, តាស៊ី, តាសា, តាអីអ៊ីចឹងជាដើម។ តើអ្នកទាំងអស់ហ្នឹង មានវត្តមានហើយឡើងនិយាយនៅវត្តព្រៃទូតហ្នឹងដែរឬទេ?

**ឆ៖** ពួកអ្នកទាំងអស់នោះ អត់មានវត្តមាននៅទីនោះទេ។ ពួកគេអត់ណែនាំខ្លួនអីទេ គឺមកមិនណែនាំខ្លួនទេ។ ដូច្នេះយើងអត់បានឃើញអត់បានដឹងអ្នកណាជាអ្នកណាទេ ពេលនិយាយនោះ។

**ស៖** សូមអរគុណ។ នៅពេលប្រជុំនៅវត្តនោះ គេប្រាប់ថាអ្នកឯងជាអ្នកទោសរបស់អង្គការ។ ពាក់ព័ន្ធទៅនឹងពាក្យអ្នកទោសអង្គការនោះ លោកស្រីក៏បាននិយាយថា លោកស្រីដូចជានៅក្នុងគុកឥតជញ្ជាំងអ៊ីចឹង។ តើនៅចន្លោះថ្ងៃទី១៧ មេសា ៧៥ រហូតទៅដល់ថ្ងៃទី០៧ មករា ៧៩ នៅពេលដែលគេជម្លៀសទៅកោះទឹកវិល ទៅពាយ័ព្យ ទៅអីជាដើមនោះ តើលោកស្រីមានទទួលបានសេរីភាពផ្ទាល់ខ្លួន ឬក៏សេរីភាពជាសមូហភាពដែលធ្វើឲ្យលោកស្រីគិតថា លោកស្រីមិនមែនជាអ្នកទោសអង្គការទេ។ មានធ្លាប់មានអ៊ីចឹងទេ?

[១៦:១០:៥១]

**ឆ៖** ខ្ញុំគិតថា គឺជាគុកឥតជញ្ជាំងហើយ ហើយយើងគឺជាអ្នកទោសរបស់ខ្មែរក្រហម។ ពីព្រោះថានៅពេលដែលយើងទៅណានោះ គេជ្រើសរើសយើង គេបែងចែកយើង គេប្រាប់យើងថាអ្នកឯងនៅក្នុងភូមិនេះ អ្នកឯងនៅក្នុងភូមិនោះ អ្នកឯងមិនអាចចេញពីភូមិនោះបាន ហើយមិនអាចទៅភូមិផ្សេងនោះបានទេ។ នៅពេលដែលយើងទៅស្រែចម្ការនោះ ឬក៏ទៅណាក៏ដោយ គឺគេឃាមកាមជាប់ជាប្រចាំតឹងរ៉ឹងណាស់ យើងមិនអាចចេញទៅណាមកណាបានទេ វានៅក្រោយយើង មើលយើង ឃ្លាំមើលយើងធ្វើការ ហើយពេលល្ងាចឡើងនាំមកយើងមកផ្ទះវិញ អត់មានឲ្យយើងមកណាទៅណាផ្ដេសផ្ដាសបានទេ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះលោកបាននិយាយថា នៅភូមិកោះទឹកវិល គេនិយាយអំពីវិន័យ និយាយអំពីការស្លៀកពាក់ ត្រូវតែស្លៀកពាក់ខ្មៅ ហើយគេចាត់តាំងបង្ខំឲ្យធ្វើការ។ តើលោក ផាន នោះមានប្រាប់អំពីន័យរបស់អង្គការទេ?

**ឆ៖** គេទទួលបានបញ្ហាទាំង១០របស់អង្គការ។ ខ្ញុំមិនអាចរៀបរាប់បានទេ ព្រោះថាខ្ញុំអត់ចាំទេ ក៏ប៉ុន្តែគឺថាមានបទបញ្ជាដែលថាត្រូវធ្វើ ឬមិនត្រូវធ្វើ គឺដូចជាថា ត្រូវរិះគន់គ្នា មិនត្រូវរើកូនទេ កូនគឺ

ជាកម្មសិទ្ធិរបស់អង្គការ។ លោកស្រីត្រូវ -- លោក អ្នកនេះឯងត្រូវតែធ្វើការ ហើយការបញ្ជាទាំងអស់ហ្នឹង គឺថាយើងត្រូវតែសូត្រឡើងវិញរហូតនៅពេលប្រជុំម្តងៗនោះ គេឲ្យយើងឡើងសូត្រនៅពេលប្រជុំទិតៀននោះ គឺថាគេឲ្យយើង -- គេលាងខួរក្បាលយើង។ គឺថា ខ្ញុំអត់មានអីសរសេរទេ ពេលហ្នឹងដឹងហើយ ខ្ញុំព្យាយាមចងចាំ ហើយខ្ញុំសរសេរអាបញ្ជាហ្នឹងនៅលើដៃ ហើយទន្ទេញឲ្យចាំផ្ទាល់មាត់ ដើម្បីសូត្រនៅពេលប្រជុំម្តងៗ ព្រោះថាគេឲ្យឡើងនិយាយ។

[១៦:១៣:០៣]

**ស៖** ក្នុងចំណោមវិន័យ ឬក៏បញ្ជារបស់អង្គការនោះ តើលោកស្រីស្តាប់បង្គាប់ទាំងស្រុងតែម្តងក្នុងឋានៈជាអ្នកដែលត្រូវគេជម្លៀស ហើយនិងក្នុងឋានៈជាប្រជាជនសាមញ្ញនោះ?

**ឆ៖** គេប្រាប់ថា ចាប់ពីថ្ងៃនេះទៅ អ្នកឯងជាកម្មសិទ្ធិរបស់អង្គការ គឺគេប្រកាសយ៉ាងច្បាស់ណាស់ ច្បាស់មែនទែន។

**ស៖** សូមអរគុណ។ នៅពេលដែលលោក ផាន ប្រាប់ឲ្យចេញដោយមានបញ្ជីឈ្មោះអ្នកដែលត្រូវចេញ ហើយគេមិនប្រាប់ថាចេញទៅណា មកណាទេ? គឺថាបញ្ជាហ្នឹងមិនអាចជជែកតវ៉ាបានទេមែនទេ ដូចដែលគេបញ្ជាចេញពីភ្នំពេញអ៊ីចឹង គឺថាដាច់អហង្ការតែម្តង មិនអាចជជែកតវ៉ាទេ?

**ឆ៖** បញ្ជីឈ្មោះដែលលោក ផាន មាននៅក្នុងដៃនោះ គឺថាមកពីថ្នាក់លើតែម្តង គឺមិនអាចតវ៉ាមិនអាចអីបានទេ។ ប្រហែលជាគាត់អាចដឹង ក៏ប៉ុន្តែគាត់មិនចង់ប្រាប់យើង ថាគេឲ្យយើងទៅណា។ យើងមិនដឹងថា យើងទៅណាទេ គោលដៅទី២ហ្នឹង មិនដឹងថាគេបញ្ជូនទៅណាទេ។

[១៦:១៤:១៤]

**ស៖** នៅពេលដែលគេបញ្ជូនលោកស្រីទៅពាយ័ព្យតាមឡានទៅកាន់ពោធិ៍សាត់។ ក្រៅពីអ្នកដែលគេជម្លៀសពីកោះទឹកវិលជាមួយលោកស្រីនោះ តើមានអ្នកមកពីតំបន់ផ្សេងទៀតទេ មានអ្នកមកពីជុំវិញភូមិហ្នឹងមក ជម្លៀសទៅជាមួយលោកស្រីទេ មានភូមិផ្សេងទេ?

**ឆ៖** គឺថាសុទ្ធតែជាអ្នកជម្លៀសមកពីទីក្រុងភ្នំពេញ។ នៅពេលហ្នឹង គេហៅជនភៀសខ្លួននៅឡើយទេ។ មិនមានអ្នកភូមិ មិនមែនមានតែអ្នកភូមិប៉ុណ្ណឹងទេ មានអ្នកជុំវិញហ្នឹងទៀត ក៏គេបញ្ជូនទៅដែរ មានឡានប្រហែលជា១០ គេរៀបចំបន្តុកន្ទុយគ្នាសម្រាប់ដឹកប្រជាជនចេញទៅ ដាក់នៅតម្រៀបគ្នានៅលើផ្លូវ។

**ស៖** ក្រោយពីលោកស្រីធ្វើដំណើរតាមឡាន ជាមួយនឹងអ្នកទាំងអស់ហ្នឹង លោកស្រីទៅដល់

ពោធិ៍សាត់ តើមានមនុស្សច្រើនដែលគេជម្លៀសមកពីភូមិ ឬក៏ពីក្រុងណាផ្សេង ហើយនៅកន្លែងហ្នឹងស្រាប់តែម្ដងហើយទេ។

**ផ៖** ពិតណាស់ គឺថាមានអ្នកមនុស្សពេញទៅហើយ ពេលដែលទៅដល់នោះ។ មានអ្នកទៅដល់មុនយើងទៀត គេជម្លៀសទៅមុនយើងទៀត គឺអ្នកភ្នំពេញក៏មាន អ្នកអីផ្សេងគេជម្លៀសទៅដល់នុំងមុនយើងទៅហើយ។ ហើយមិនមែនមានតែអ្នកភ្នំពេញទេ អ្នកមកពីក្រុងផ្សេងទៀតក៏មានដែរ។

[១៦:១៥:៤៨]

**ស៖** សូមអរគុណ។ អ៊ីចឹងលោកស្រីដឹងច្បាស់ទេ ថាអ្នកទាំងអស់នោះគេទើបតែជម្លៀសមកពីណា គឺពេលទៅដល់ពោធិ៍សាត់ហ្នឹង?

**ផ៖** ខ្ញុំអត់ដឹងទេ ពីព្រោះថានៅពេលនោះ គឺថាខ្ញុំមិនចាប់អារម្មណ៍ទៅលើចំណុចអស់ហ្នឹងទេ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះគឺថាមើលថែកូនរបស់ខ្ញុំ ពិសេសកូនពៅរបស់ខ្ញុំដែលៗឃ្លាន អត់មានបាយនោះ យើងមិនខ្វល់ថាអ្នកណាមកពីណាទេ យើងគិតថាធ្វើម៉េចឲ្យកូនចៅយើងបានហូបចុកតែប៉ុណ្ណោះ។

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំសង្ខេបទៅអំពីអ្វីដែលលោកស្រីនិយាយអំពីការជម្លៀសលើកទី២នេះ គឺថាលោកស្រីចេញពីកោះទឹកវិល ដោយផ្អែកទៅលើបញ្ជីឈ្មោះ ហើយនេះគឺជាបញ្ជាដែលនាំមកដោយលោក ផាន ហើយគេដឹកលោកស្រីតាមឡានជាមួយអ្នកជម្លៀសផ្សេងៗទៀត ហើយចេញទៅពោធិ៍សាត់ជិះរថភ្លើង។ ហើយពោធិ៍សាត់នេះគឺជាកន្លែងប្រមូលផ្ដុំរង់ចាំ ហើយបន្ទាប់មកទៅគេបញ្ជូនទៅភ្នំលាភ ហើយនៅភ្នំលាភនោះ គេបែងចែកប្រជាជនទៅដាក់តាមភូមិផ្សេងៗគ្នា។ តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំអាចនិយាយថា ការជម្លៀសនេះគឺថាមានការរៀបចំត្រឹមត្រូវហើយពីខ្មែរក្រហមនោះ គឺថាផ្ទុយពីអាជម្លៀសនៅភ្នំពេញ គឺថាអត់មានរៀបចំការដឹកជញ្ជូនអីទេ ប៉ុន្តែជម្លៀសនេះគឺរៀបចំត្រឹមត្រូវ?

[១៦:១៧:២១]

**ផ៖** មុនភ្នំលាភ គឺយើងទៅដល់ស្វាយស៊ីសុផុន ចេញពីពោធិ៍សាត់មក យើងជិះត្រាក់ទ័រទៅស្វាយស៊ីសុផុន។ នៅកន្លែងនោះគេៗរៀបចំប្រជាជនដាក់ជាក្រុមៗហើយ គេដាក់១០គ្រួៗអ៊ីចឹង គេដាក់មួយក្រុម ហើយយើងៗនៅលេខ៦២។ ហើយបន្ទាប់មកគេដឹកតាមត្រាក់ទ័រៗទៅដល់ភ្នំលាប។ អ៊ីចឹងអ្វីដែលគេរៀបចំហើយ ច្បាស់ហើយ គេមើលឃើញថាមានការរៀបចំត្រឹមត្រូវ រៀបចំជាក្រុម ជាពួកអ៊ីចឹង។ ហើយយើងគឺយើងអត់ដឹងទេ អត់ដឹងថាយើងត្រូវទៅណាទេ មិនដឹងថាគេបញ្ជូនទៅណាទៅណី

ទេ។ យើងមិនដឹងថា ទាំងយើងមិនទាំងដឹងថា គេនឹងមកបំបែកកូនយើងចេញពីយើងទៀតផង។

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំមិនច្រឡំទេ លោកស្រីនិយាយជាច្រើនលើកច្រើនសាថា គេដឹកដូចសត្វធាតុអ៊ីចឹងដាក់នៅក្នុងឡាន ហើយក្នុងរទេះភ្លើងជាដើម។ តើលោកស្រីមានទទួលបានការជំនួយផ្នែកម្ហូបអាហារ និងទឹកទេ នៅក្នុងពេលធ្វើដំណើរជម្លៀសនុ៎ង?

[១៦:១៨:២៦]

**ឆ៖** អត់មានទាល់តែសោះ គឺទទេ។ គឺយើងអាចឲ្យកូនយើងផឹក ហើយនិងញ៉ាំបាននោះ គឺជាចំណីអាហារដែលយើងសល់ពីវត្តមកទេ យើងយកពីវត្តមក យើងឲ្យកូន ហើយនៅក្នុងឡាននោះគ្មានអ្នកណាគេខ្វល់ គេឲ្យយើងហូបចុកអីទេ គេមិនប្រាប់យើងថា យើងទាំងយើងទៅណា យើងឈប់សម្រាកយ៉ាងម៉េច គេអត់ទាំងឈប់ឲ្យយើង ឲ្យបត់ដៃបត់ជើងអីផង គឺអត់មានទាល់តែសោះ។ គឺថាត្រូវតែនៅក្នុងឡានហ្នឹងរហូតតែម្តង អត់មានឲ្យចុះទៅណាមកណាទេ។ គ្មានការជួយអីទាំងអស់ យើងហូបចុកដោយខ្លួនឯង ឲ្យកូនឲ្យអី។

**ស៖** បាទ មុននឹងផ្តល់វេទិកានេះជូនសហការីខ្ញុំ ខ្ញុំមានសំណួរមួយទៀត។ នៅភ្នំលាភ នៅពេលដែលគេចាត់ឲ្យទៅភ្នំត្រឡោក -- ភ្នំត្រឡួច តើលោកស្រីអាចបញ្ជាក់បានទេថា លោកស្រីអាចរើសកន្លែងណាដែលលោកស្រីចង់នៅ ហើយចង់ធ្វើការទេ មានអាចរើសបានទេ?

**ឆ៖** ជាអកុសល គឺគ្មានទេ។ បើសិនបើខ្ញុំមានជម្រើស ខ្ញុំទៅកន្លែងពិសេសហើយមិនទៅអាកន្លែងហ្នឹងទេ ខ្ញុំទៅពិភពផ្សេងតែម្តង។ គឺថាយើងអត់មានជម្រើសទេ ត្រូវតែទៅតាមគេ គេឲ្យទៅណាទៅនុ៎ងហើយ។

**ស៖** សូមអរគុណលោកស្រី អាហ្យុងសួ។ ខ្ញុំសូមផ្តល់វេទិកានេះជូនទៅសហការីរបស់ខ្ញុំ នៅសល់ពេល១០នាទីទៀតដែរ។

**ឆ៖** សូមអរគុណលោកសហព្រះរាជអាជ្ញា។

[១៦:២០:០០]

**លោក ច័ន្ទ តាារស្មី៖**

សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**សួរដោយលោក ច័ន្ទ តាារស្មី៖**

**ស៖** ជម្រាបសួរលោកស្រី អាហ្យុងសួ។ ខ្ញុំឈ្មោះ ច័ន្ទ តាារស្មី ជាសហព្រះរាជអាជ្ញារងជាតិ

នៃអង្គជំនុំជម្រះតុលាការកម្ពុជានៅទីនេះ។ សូមជម្រាបសួរសំណួរមួយចំនួនទៅលោកស្រីបន្ថែមលើសហការីខ្ញុំបានសួរអម្បាញ់មិញនេះបាទ។ សូមលោកស្រីជួយបញ្ជាក់បន្ថែមពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៨ មេសា ឆ្នាំ១៩៧៥ ទាក់ទងនឹងការបញ្ជាក្នុងការជម្លៀសប្រជាជន។ ខ្ញុំសូមសួរថាតើពួកខ្មែរក្រហមបាននិយាយប្រាប់ដែរឬទេពីការដឹកជញ្ជូនប្រជាជនចេញពីទីក្រុង តើគេមានបានប្រាប់អំពីមធ្យោបាយដែលត្រូវដឹកប្រជាជនចេញដូចជារថយន្ត ក៏ឡានតាក់ស៊ី ឬក៏រថភ្លើង ឬក៏ប្រើឡានក្រុង ដើម្បីសម្រួលដល់ការជម្លៀសនេះដែរឬទេបាទ?

**លោកស្រី ដេនីស អាហ្វុងសូ៖**

**ឆ៖** នៅពេលដែលគេបញ្ជាឲ្យយើងចេញភ្នំពេញ ដូចខ្ញុំបាននិយាយម្ដងហើយម្ដងទៀត គឺថាគេគ្រាន់តែប្រាប់ថា "ចេញទៅៗ ចេញតែ ២, ៣ថ្ងៃទេ មិនបាច់យកអីវ៉ាន់អីច្រើនទេ យកតែរបស់របរណាចាំបាច់ទៅបានហើយ គឺថានឹងមកវិញហើយ ហើយមុននឹងចេញសូមទុកសោមក។ ដូចគេមិនប្រាប់យើងទៀតថា យើងត្រូវចេញតាមណាៗទេ គ្មានអ្នកណាប្រាប់ទេ។ គេគ្រាន់តែប្រាប់ថា ទៅតាមនេះទៅអង្គការចាំហើយ កន្លែងនេះអង្គការចាំ!"។ ដូច្នេះ អត់មានការជួយអីទាំងអស់ ប្រាប់ឲ្យយើងចេញ គឺចេញទៅតែម្ដង។

[១៦:២២:០៦]

**ស៖** បាទ អរគុណ។ តើគេបានប្រាប់អំពីមធ្យោបាយធ្វើដំណើរតាមមធ្យោបាយណាដែរទេ? តើគេបានប្រាប់ថាឲ្យយកចំណីអាហារ ឬក៏ថ្នាំពេទ្យទៅជាមួយដែរឬទេ?

**ឆ៖** គេមិនបានប្រាប់ថា យើងជិះអីៗទេ គេគ្រាន់តែប្រាប់ថា "អ្នកឯងត្រូវតែចេញពីផ្ទះជាដាច់ខាត ហើយយករបស់របរដែលចាំបាច់ទៅបានហើយ" នេះគឺជាការបញ្ជា។ ក៏ប៉ុន្តែចំពោះខ្ញុំ ខ្ញុំយកឯកសារអត្តសញ្ញាណទៅទាំងអស់ ដើម្បីអាចបញ្ជាក់ប្រាប់ពួកវាថា ខ្ញុំជាជនជាតិបារាំង ហើយគេឲ្យខ្ញុំ -- ប្រហែលជាគេអាចឲ្យខ្ញុំទៅស្ថានទូតបារាំង ក៏ប៉ុន្តែអត់ទេ គេអត់មានឲ្យទៅទេ។ ប្ដីខ្ញុំនិយាយចិននិយាយខ្មែរ ដូច្នេះគេគិតថា ខ្ញុំត្រូវតែជាខ្មែរដែរ។ អ៊ីចឹងគេអត់មានអនុគ្រោះត្រាប្រណីខ្ញុំ ឲ្យខ្ញុំទៅស្ថានទូតទេ គឺត្រូវតែទៅជាមួយប្ដីខ្ញុំ។

[១៦:២៣:២០]

**ស៖** បាទ អរគុណលោកស្រី។ សូមលោកស្រីជួយបញ្ជាក់ថា តើលោកស្រី និងក្រុមគ្រួសាររបស់លោកស្រីត្រូវបានពួកខ្មែរក្រហមឆែកឆេរខ្លួនប្រាណក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុង ឬនៅ

ក្រៅទីក្រុងដែរឬទេបាទ?

**ឆ៖** នៅពេលចេញពីផ្ទះ ហើយយើងចេញទៅតាមផ្លូវមុន្នីវង្សទៅខាងត្បូងតាមទិសតាខ្មៅ គឺមិនមានការឆែកឆេរអីទេ។ នៅពេលចេញតាមផ្លូវមានទាហាន ក៏ប៉ុន្តែនៅពេលចេញពីតាខ្មៅនោះមានប៉ុស្តិ៍យាមមួយ ចេញពីតាខ្មៅទៅមានប៉ុស្តិ៍យាម ហើយគេឆែកឆេរយើង គេដក លើកអីវ៉ាន់ចេញទាំងអស់ ចេញពីឡានមើលឯកសារយើងអីទាំងអស់ ហើយពេលនោះហើយ ខ្ញុំបង្ហាញបណ្ណកុងស៊ុលបណ្ណលិខិតឆ្លងដែន ហើយខ្ញុំប្រាប់គេថា ខ្ញុំជនជាតិបារាំង ឲ្យខ្ញុំទៅស្ថានទូតបារាំងមក ខ្ញុំអង្វរគេ ហើយគេយកទាំងអស់ គេកម្ទេចចោលទាំងអស់ កញ្ចប់អីវ៉ាន់ ឯកសាររបស់ខ្ញុំទាំងអស់នោះ។

**ស៖** សូមអរគុណ។ តើពួកខ្មែរក្រហមមានប្រតិកម្មយ៉ាងដូចម្តេចនៅពេលដែលពួកគេដឹងថាអ្នកស្រី និងកូនរបស់អ្នកស្រី គឺជាជនជាតិបារាំងនោះបាទ?

[១៦:២៥:០៥]

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អាហ្វុងសូ កុំអាលទាន់ឆ្លើយបាទ។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម លោកប្រធាន ហើយលោកស្រីសាក្សី។ ខ្ញុំសូមអភ័យទោស ដែលខ្ញុំជំទាស់។ ឥឡូវនេះគឺថា មានសំណួរ -- បួនជាងហើយគឺថា សំណួរដដែល ហើយគឺថា មិនចាំបាច់សួរពីរដង បីដង គឺពិនិត្យមើលសំណួរតារាងសំណួរឃើញសួររួចមកហើយ បើសួរហេតុអ្វីគឺថា ដើម្បីសន្សំពេលនៅថ្ងៃនេះ យើងមិនបានដឹងអ្វីៗថ្មីទេ គឺថា អាចធ្វើឲ្យសាក្សីកាន់តែមានជំងឺបាក់ស្បាតធ្ងន់ទៅៗតាមទម្ងន់នៃសំណួរបាទ -- ដើមបណ្តឹងរដ្ឋប្បវេណី សូមអភ័យទោសបាទ។

[១៦:២៥:៥៦]

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។ សំណួរនេះគឺ គ្រាន់តែខ្ញុំចង់ដឹងបញ្ជាក់បន្ថែម ប៉ុន្តែបើសិនជាមិនយល់ទេ ឯកឧត្តម -- លោកប្រធានមិនយល់ទាស់ទេ ខ្ញុំសូមបង្វែរសំណួរមួយទៀត ដែលមានសារៈសំខាន់ទាក់ទងទៅនឹងសំណួរមួយទៀតនេះ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** សំណួរសូមសួរថា លោកស្រីតើនៅក្នុងរបបខ្មែរក្រហម លោកស្រីបានឃើញថា នៅពេលនោះមានការចាយលុយនៅក្នុងរបបខ្មែរក្រហមដែរឬទេ? ហើយលោកស្រីបានជួយមេដឹកនាំណាខ្លះនៅពេលដែលលោកស្រីជម្លៀសទៅក្នុងតំបន់ផ្សេងៗនោះបាទ?

**លោកស្រី ដេនីស អាហ្វុងស្វូ៖**

**ឆ៖** អត់ទេ។ នៅពេលទៅដល់កោះទឹកវិលហ្នឹង គឺគេលុបការចាយលុយកាក់ហើយ អត់មានការចាយលុយទេ។ គឺថា យើងដោះដូរគ្នា យករបស់របរទៅដោះដូរគ្នា អត់មានលុយ ចរាចរលុយកាក់អីទេ។

**ស៖** តើនៅកោះទឹកវិល ដែលលោកស្រីទៅដល់នោះ ទីនោះលោកស្រីត្រូវបានគេបង្ខំឲ្យធ្វើការជាទម្ងន់នៅទីនោះ តើការងារនោះ លោកស្រីដឹងថាដាក់បញ្ជាមកពីថ្នាក់ណាដែរ? ហើយលោកស្រីធ្លាប់បានជួបជាមួយនឹងមេដឹកនាំណាដែរឬទេ នៅក្នុងពេលដែលលោកស្រីស្នាក់នៅរស់នៅទឹកកោះវិលនោះ?

[១៦:២៧:៣៤]

**ឆ៖** បញ្ជាគឺចេញមកពីអង្គការ។ អង្គការនិយាយថា ចាប់ពីថ្ងៃនេះទៅ អ្នកឯងត្រូវតែធ្វើការ ក្មេង កូនក៏ធ្វើការដែរ មិនត្រូវរៀនសូត្រអីទេ មិនចាំបាច់លេង មិនចាំបាច់រៀនអីទេ គឺ-- ហើយកូនរបស់ខ្ញុំហ្នឹងមានតុក្កតាមួយដែលជាអំណោយបុណ្យណូអែលរបស់ស្ថានទូតបារាំងនោះ កូនខ្ញុំកាន់តុក្កតាហ្នឹង ហើយពួកវាទាញតុក្កតាហ្នឹងចេញ ហើយគប់ចោលទៅដី គ្រវាត់ចោល ហើយប្រាប់ថា អត់មានលេងតុក្កតាអីទៀតទេចាប់ពីថ្ងៃនេះទៅ ចាប់ពីថ្ងៃនេះតទៅហាមលេងដាច់ខាត។

**ស៖** បាទ អរគុណ។ តើលោកស្រីដែលបានជួបលោក អៀង សារី, លោក ខៀវ សំផន, លោក នួន ជា, ឬក៏លោកស្រី អៀង ធីរិទ្ធ ដែរឬទេនៅពេលដែលលោកស្រីស្នាក់នៅ រស់នៅ ធ្វើការនៅជំរំកោះទឹកវិលនោះបាទ?

[១៦:២៨:៤០]

**ឆ៖** ខ្ញុំមិនដែលទាំងឮឈ្មោះ មេដឹកនាំទាំងអស់ហ្នឹងផង មិននិយាយដល់ការជួបផង គ្រាន់តែឈ្មោះនោះក៏មិនដែលឮផង។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំគឺចង់សួរថា រាល់ពេលដែលគេអញ្ជើញលោកស្រីទៅចូលរួមប្រជុំ តើលោកស្រីជួបជាមួយនឹងអ្នកជាប្រធានអង្គប្រជុំហ្នឹងជានរណា? ហើយគាត់ជា

ថ្នាក់ណាដែរ? ហើយគាត់បាននិយាយអ្វីខ្លះនៅពេលអង្គប្រជុំនោះបាទ?

**ឆ៖** ប្រធានបទគឺដដែលៗ ដំបូងគឺថាសូត្របញ្ញោរបស់អង្គការ បន្ទាប់មកយើងនិយាយដដែលៗ ថា យើងត្រូវតែធ្វើនេះធ្វើនោះ យើងត្រូវតែគោរព យើងមិនត្រូវល្មើសនឹងអង្គការឡើយ គេផ្តល់កម្មវិធី ឲ្យយើងធ្វើការសម្រាប់ថ្ងៃបន្ទាប់។ ប្រសិនបើយើងប្រព្រឹត្តកំហុសនោះ យើងត្រូវតែស្វ័យទិតៀនខ្លួនឯង នៅចំពោះមុខអ្នកផ្សេងៗទៀតនៅចំពោះមុខអង្គប្រជុំ។

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំសូមអរគុណលោកស្រី ដោយសារពេលវេលាអត់មាន ហើយពេលវេលាមានកម្រិត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រី ដែលបានចូលរួមចំណែកក្នុងការផ្តល់នូវចម្លើយយ៉ាងល្អ។ ហើយទាក់ទិននឹងសក្ខីកម្មនៅក្នុងថ្ងៃ គឺខ្ញុំគិតថា មានសារៈសំខាន់ដែលចូលរួមក្នុងការស្វែងរកការពិតនៅសាលាក្តីខ្មែរក្រហមនេះ។ សូមជូនពរឲ្យលោកស្រីជួបតែសំណាងល្អ និងទទួលបានជោគជ័យក្នុងជីវិតការងារបាទ។

លោកប្រធាន ខ្ញុំសូមអរគុណ ហើយបញ្ចប់ការសួររបស់ខ្ញុំបាទ។ សូមអរគុណ។

[១៦:៣០:២៣]

**ប្រធានអង្គជំនុំ៖**

បាទ កិច្ចដំណើរការសវនាការនៅថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើ --

*(ចៅក្រមពិភាក្សាគ្នា)*

បាទ ឥឡូវនេះ មានបញ្ហាបន្តិចថា អង្គជំនុំជម្រះក៏ចង់ដឹងដែរ ដោយសារបច្ចេកទេសក្នុងការធ្វើនីតិវិធីសវនាការហ្នឹង តាមប្រព័ន្ធសោតទស្សន៍ បញ្ហា-- ដើម្បីជាក់ច្បាស់ហ្នឹងអង្គជំនុំជម្រះសូមសួរទៅភាគីមេធាវីការពារក្តី ថាតើក្រុមមេធាវីនីមួយៗហ្នឹងមានសំណួរត្រូវសួរដល់លោកស្រី អាហ្វុងសូ ដេនីស ដែរឬទេ? ហើយប្រសិនបើមានសំណួរនោះ ប្រហែលជាចំណាយពេលវេលាប្រហែលជាប៉ុន្មានដែរ? ផ្តើមពីមេធាវីការពារក្តីលោក នួន ជា មុន បាទ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមើលកំណត់ហេតុថ្ងៃនេះរបស់ខ្ញុំ ហើយនិងមើលប្រតិចារឹក ខ្ញុំគិតថា ខ្ញុំត្រូវការប្រហែលមួយម៉ោងនៃការសួរសំណួរនៅពេលថ្ងៃល្ងាចស្អែក។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ គិតមកដល់ពេលនេះ យើងខ្ញុំមិនមានសំណួរសួរអ្នកស្រី អាហ្វុងសូ ទេ ប៉ុន្តែក្នុងករណីដែលលោក ក្រុមមេធាវីលោក នួន ជា សួរហើយ យើងខ្ញុំអាចពិចារណាថា នឹងមានសំណួរបន្ថែម ឬសំណួរបញ្ជាក់ឬអត់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណបាទ។ ចុះលោកមេធាវី ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន?

[១៦:៣២:២៧]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សម្រាប់ក្រុមយើងខ្ញុំ ឥឡូវនេះមិនទាន់មានសំណួរអ្វីទេ ក៏ប៉ុន្តែយើងនឹងពិនិត្យមើលនីតិវិធីបន្តទៀត បើសិនជាមានសំណួរយើងខ្ញុំរៀបជូន។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ មានពត៌មានច្បាស់លាស់ហើយ។ បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១៣ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ នៅវេលាព្រឹក និងនៅរសៀលបន្តធ្វើសវនាការស្តាប់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណី អាហ្វុងសូ ដេនីស តាមមធ្យោបាយសោតទស្សន៍ ដែលត្រូវសួរដេញដោលដោយក្រុមមេធាវីការពារក្តី។ សូមភាគី និងសាធារណជនជ្រាប។

លោកស្រី អាហ្វុងសូ ដេនីស ការស្តាប់សក្ខីកម្មរបស់លោកស្រីក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មលោកស្រី នៅរសៀលថ្ងៃស្អែកទៀត ដោយចាប់ផ្តើមធ្វើសវនាការនៅពេលម៉ោងដូចថ្ងៃនេះដែរ ហើយអង្គជំនុំជម្រះកោះអញ្ជើញមកកាន់កន្លែង ដែលលោកស្រីអង្គុយផ្តល់សក្ខីកម្មនោះ ដើម្បីបន្តផ្តល់សក្ខីកម្មនៅរសៀលថ្ងៃស្អែក ថ្ងៃ

ព្រហស្បតិ៍ ទី១៣ ខែធ្នូ ឆ្នាំ២០១២ ទៀត។ ហើយសវនាការសម្រាប់ថ្ងៃនេះ សម្រាកត្រឹមនេះ។ លោកស្រី អាហ្វុងសូ អង្គជំនុំជម្រះ សូមអរគុណលោកស្រី និងមេធាវី ជូល្យាន រីវ៉េ។

**លោកស្រី ដេនីស អាហ្វុងសូ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងអ្នកបច្ចេកទេសខាងសោតទស្សន៍ក្នុងការរៀបចំប្រព័ន្ធសោតទស្សន៍ សម្រាប់ធ្វើសវនាការនៅរសៀលថ្ងៃស្អែកទៀត និងសម្រាប់កិច្ចការនៅថ្ងៃស្អែក នៅពេលរសៀលទេ។ ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់កន្លែងសាលសវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក អៀង សារី ឱ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួន ដែលនៅពីក្រោយបន្ទប់សវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍ ដែលមានរៀបចំសម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:៣៥ នាទី)*